**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Oct-2015, 14:01
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ៖** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

**ភាគីដាក់ឯកសារ៖** សហព្រះរាជអាជ្ញា

**ដាក់ជូន៖** អង្គជំនុំជម្រះតុលាការកំពូល

**ភាសាដើម៖** អង់គ្លេស

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះតុលាការកំពូល៖** សាធារណៈ/Public

**ឋានៈនៃចំណាត់ថ្នាក់ឯកសារ៖**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖**

**ឈ្មោះមន្ត្រីកត់ត្រា៖**

**ហត្ថលេខា៖**

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី ៦ របស់ នួន ជា សុំឲ្យមានការពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទិននឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១**

---

**ដាក់ដោយ៖**

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**ផ្ញើជូន៖**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម A. KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម C.N. JAYASINGHE

**ជនជាប់ចោទ៖**

នួន ជា

ខៀវ សំផន

**មេធាវីការពារក្តី៖**

សុន អរុណ

ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele MUMBA

Victor KOPPE
គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

**<u>ចម្លងជូន៖</u>**

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្ដីផ្ដើម

1. សហព្រះរាជអាជ្ញា តទៅនេះ សូមឆ្លើយតបទៅនឹងសំណើលើកទី ៦ របស់ នួន ជា ស្នើសុំឲ្យពិចារណា និងទទួលយកភស្តុតាងបន្ថែមលើបណ្ដឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១[1] ("សំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម")។ នួន ជា ស្នើសុំតុលាការឲ្យទទួលយកឯកសារ ២២ បន្ថែមទៀត និងស្នើសុំឲ្យកោះហៅសាក្សីពីរនាក់ទៀតលើបណ្ដឹងសាទុក្ខ។ សហព្រះរាជអាជ្ញសូមអះអាងថា នួន ជា មិនបានបង្ហាញនូវទម្ងន់ភស្តុតាងដែលបានមកពីឯកសារណាមួយក្នុងចំណោមឯកសារទាំងនេះ ឬពីសាក្សីណាម្នាក់ដែលបានស្នើឡើង និងបានបញ្ជាក់ថាភស្តុតាង និងសាក្សីទាំងនោះអាចជាកត្តាកំណត់នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ អនុលោមតាមអត្ថន័យនៃវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង។ ម្យ៉ាងវិញទៀត សំណើរបស់ នួន ជា ក៏មិនបានផ្ដល់ប្រយោជន៍យុត្តិធម៌អ្វីដែលតម្រូវឲ្យទទួលយក ស្របតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងនោះទេ។ អង្គជំនុំជម្រះគប្បីបដិសេធចោលទាំងស្រុងចំពោះសំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម។

2. សំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែមនេះ ស្ថិតនៅក្រៅវង្វង់នៃចំណាត់ថ្នាក់ឯកសារ ដែលអាចទទួលយកបានលើបណ្ដឹងសាទុក្ខ ដូចមានកំណត់ក្នុងវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រពាក់ព័ន្ធ។ ឯកសារដែលបានស្នើឡើងទាំងនេះ គ្មានពាក់ព័ន្ធគ្នាទៅនឹងបទឧក្រិដ្ឋ ដែលតុលាការបានផ្ដន្ទាទោស នួន ជា នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ សោះឡើយ។

3. ដូចអ្វីដែលនឹងពន្យល់បន្ថែមនៅខាងក្រោមនេះ ឯកសារជាច្រើនដែលជាកម្មវត្ថុនៃសំណើនេះ សុទ្ធតែជាឯកសារដែលរកបាននៅមុន និង/ឬនៅក្នុងពេលកំពុងជំនុំជម្រះក្ដីក្នុងសំណុំរឿង ០០២/០១។ ដូច្នេះ ឯកសារទាំងនេះមិនមែនជាភស្តុតាង"ថ្មី"សោះឡើយ។ ជាងនេះទៅទៀត ក្នុងដំណើរនៃការដាក់ឯកសារទាំងនេះ នួន ជា ជាញឹកញាប់ផ្ដល់ព័ត៌មាននាំឲ្យអង្គជំនុំជម្រះមានការភាន់ច្រឡំ ពាក់ព័ន្ធនឹងខ្លឹមសាររបស់ឯកសារ និងបានលុបចោលនូវភស្តុតាងផ្ទុយ ដែលបានមកពីសាក្សីដដែលនេះ។ ទឡ្ហីករណ៍របស់ នួន ជា មានលក្ខណៈស្មាន ឧបមា និងអត្ថបដិរូប។

---

[1] ឯកសារ F2/8 សំណើលើកទី ៦ របស់ នួន ជា ស្នើសុំឲ្យមានការពិចារណា និង ទទួលយកភស្តុតាងបន្ថែម ទាក់ទិននឹងបណ្ដឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ ("សំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម") (ត្រូវបានជូនដំណឹងជាភាសាខ្មែរ នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥)។

4. ទោះបីជាយ៉ាងនេះក្តី សំខាន់ជាងនេះទៀត បើទោះបីជាឯកសារទាំងនេះពិតទៅតាមអ្វីដែល នួន ជា ចង់បាន ក៏វាគ្មានឥទ្ធិពលអ្វីទាំងអស់ទៅលើសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ទេ។ ដូច្នេះ សំណើលើកទី ៦ សុំដាក់ភ័ស្តុតាងបន្ថែម ជាសំណើឥតបានការ និងគ្មានន័យអ្វីទាំងអស់ ក្រៅតែពីពន្យារការចេញសាលក្រមស្ថាបពរនៅក្នុងសំណុំរឿង ០០២/០១ តែប៉ុណ្ណោះ។

5. នួន ជា ដឹងខ្លួនឯងច្បាស់ ដែលខំចំណាយពេល ដើម្បីប្រកែកថា សំណើលើកទី ៦ ឲ្យទទួលយកភ័ស្តុតាងបន្ថែមនេះ មិនមែនជា "ទ្រឹស្តីឃុបឃិតឆ្គួតលីលាអុកឡុករំខាន ដែលបង្កើតឡើងដើម្បីឲ្យមានបញ្ហាច្របូកច្របល់ និងចៀសវាងបញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌ"នោះទេ[2]។ ទោះបី នួន ជា មានជំនឿថា "វៀតណាម រួមទាំងក្រុមប្រឆាំងផ្ទៃក្នុងបក្សកុម្មុនីស្តកម្ពុជា បានដើរតួនាទីសំខាន់ចាំបាច់"[3] ក៏ដោយ ក៏គាត់មិនបានបង្ហាញឲ្យឃើញថា វៀតណាម ឬទំនាស់ក្នុងបក្សពិតជាមានតួនាទីណាមួយនៅក្នុងបទឧក្រិដ្ឋ ដែលតុលាការបានផ្តន្ទាទោសគាត់ក្នុងសំណុំរឿង ០០២/០១។ បើ នួន ជា ចង់បង្ហាញយុត្តិកម្មដើម្បីឲ្យអង្គជំនុំជម្រះព្រមទទួលយកភ័ស្តុតាងថ្មីលើបណ្តឹងសាទុក្ខ ដែលត្រូវឆ្លងការជំនុំជម្រះក្តីអស់រយៈពេលយ៉ាងយូរ (ដែលការជំនុំជម្រះក្តីនេះធ្វើឡើង បន្ទាប់ពីមានការស៊ើបអង្កេតយ៉ាងច្រើន ដោយក្នុងនោះមានការចូលរួមពី នួន ជា ផងដែរ) នួន ជា ត្រូវតែស្វែងរកអង្គហេតុពិតដែលអាចឆ្លងផុតការត្រួតពិនិត្យ ដើម្បីយកមកអះអាងគាំទ្រជាលក្ខណៈឃុបឃិតរបស់គាត់ និងបង្ហាញពីភាពពាក់ព័ន្ធរបស់វាទៅនឹងការទទួលខុសត្រូវរបស់គាត់ចំពោះបទឧក្រិដ្ឋ ដែលតុលាការបានផ្តន្ទាទោសគាត់។ អង្គហេតុពិតទាំងនោះ គាត់មិនបានរកឃើញសោះឡើយ។

6. នួន ជា ស្វែងរកការអាណិតអាសូរ ដោយសំអាងទៅលើសម្តីឥតខ្លឹមសារ ដែលគាត់បានថ្លែងពាក់ព័ន្ធនឹង "ការទទួលខុសត្រូវផ្នែកសីលធម៌"របស់គាត់[4]។ ទោះជាយ៉ាងណាក្តី អ.វ.ត.ក ជាតុលាការ។ នួន ជា ដឹងច្បាស់ណាស់ថា តុលាការនេះមិនសម្រេចក្តីផ្អែកលើការទទួលខុសត្រូវផ្នែកសីលធម៌ទេ។ តុលាការនេះសម្រេចក្តី ដោយផ្អែកលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ហើយក្នុងន័យនេះ នួន ជា ពិតជាបានដឹងយ៉ាងច្បាស់អំពីជំហររបស់គាត់។ នួន ជា បានថ្លែងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ច

[2] ឯកសារ F2/8 សំណើលើកទី ៦ សុំដាក់ភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១៧។

[3] ឯកសារ F2/8 សំណើលើកទី ៦ សុំដាក់ភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១៧។

[4] ឯកសារ F2/8 សំណើលើកទី ៦ សុំដាក់ភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១៧។

ពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១ ថា "តាមរយៈសវនាការនេះ វាបានបញ្ជាក់យ៉ាងច្បាស់ ថា ខ្ញុំមិនមានការជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តិបទល្មើសដូចលោក លោកស្រីសហព្រះរាជអាជ្ញាចោទប្រកាន់នោះទេ។ និយាយឲ្យខ្លីទៅ ខ្ញុំមិនមានទោសអ្វីទាក់ទងនឹងការចោទប្រកាន់ដូចបានលើកឡើងនោះទេ"[5]។

7. ប៉ុន្តែ កាលពីជាងមួយឆ្នាំកន្លងទៅ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញផ្ទុយពីនេះ (បើតាមការយល់ឃើញរបស់សហព្រះរាអាជ្ញា អង្គជំនុំជម្រះសម្រេចត្រឹមត្រូវ)។ ដូច្នេះ សហព្រះរាជអាជ្ញា សូមស្នើដោយក្តីគោរព សុំឲ្យអង្គជំនុំជម្រះបដិសេធភ្លាមៗទៅលើសំណើ ដែលមានលក្ខណៈអូសបន្លាយពេលវេលា ក្នុងចេតនាធ្វើឲ្យអង្គជំនុំជម្រះមិនអាចចេញសាលក្រមស្តីពីភាពមានពិរុទ្ធ ឬភាពគ្មានពិរុទ្ធផ្នែកព្រហ្មទណ្ឌរបស់ នួន ជា នេះ។

## II- ប្រវត្តិនីតិវិធី

8. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមរបស់ខ្លួន ក្នុងសំណុំរឿង ០០២/០១[6] ដោយបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ ការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើឃាតមនុស្ស) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមានការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)។ ការរកឃើញពិរុទ្ធភាពនេះផ្អែកលើបទចោទនៅក្នុងដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១ និង ២) និង ការសម្លាប់អតីតមន្ត្រីសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។

9. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ នួន ជា បានដាក់សេចក្តីជូនដំណឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[7] និងនៅថ្ងៃទី ២៩ ខែ ធ្នូ នួន ជា បានដាក់សារណាបណ្តឹងសាទុក្ខ

---

[5] ឯកសារ **E1/237.1 F2/8** ប្រតិចារិកសវនាការ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ត្រង់នាទី ០៩:០៥:៣៧។

[6] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។

[7] ឯកសារ **E313/1/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលសក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។

របស់គាត់ ដែលភ្ជាប់ជាមួយនឹងសំណើសុំកោះហៅសាក្សីបន្ថែមចំនួន ៥ នាក់[8]។ សហព្រះរាអាជ្ញាបាន ដាក់សារណាតបវិញ នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥[9]។ ចាប់តាំងពីដាក់សារណាបណ្តឹងសាទុក្ខ និង នៅមុនដាក់សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម នួន ជា បានដាក់សំណើចំនួន ៥ បន្ថែមទៀត សុំឱ្យទទួលយកភស្តុតាងបន្ថែម[10]។

10. នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ នួន ជា ដាក់សំណើសុំបន្ថែមទំព័រ ចំនួន ៣០ ទំព័រ សម្រាប់សរសេរសំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែមរបស់គាត់[11]។ នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ អង្គជំនុំជម្រះព្រមអនុញ្ញាតតាមសំណើរបស់ នួន ជា[12]។ ក្រោយមក នួន ជា បានដាក់សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម ដោយដាក់សំណើជាភាសាអង់គ្លេសសិនប៉ុណ្ណោះ នៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ និងនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ ទើបគាត់ដាក់សំណើជាភាសាខ្មែរ[13]។

---

[8] ឯកសារ **F16** បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៤។

[9] ឯកសារ **F17/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥។

[10] ឯកសារ **F2** សំណើសុំឱ្យទទួលយក និង ពិចារណាលើភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤។ ឯកសារ **F2/1** សំណើលើកទី ២ ស្នើសុំពិចារណាភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤។ ឯកសារ **F2/4** សំណើលើកទី ២ ស្នើសុំឱ្យទទួលយក និង ពិចារណាភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ ឯកសារ **F2/6** សំណើលើកទី ៤ របស់ នួន ជា ស្នើសុំពិចារណាភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥។ ឯកសារ **F2/7** សំណើទីប្រាំរបស់ នួន ជា សុំឱ្យពិចារណា និងទទួលយកភស្តុតាងបន្ថែម ពាក់ព័ន្ធបណ្តឹងសាទុក្ខប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥។

[11] ឯកសារ **F27** សំណើបន្ទាន់របស់ នួន ជា ស្នើសុំចំនួនទំព័របន្ថែមសម្រាប់សំណើលើកទី ៦ របស់ខ្លួន សុំឱ្យទទួលយកភស្តុតាងបន្ថែមសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥។

[12] ឯកសារ **F27/1** សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំចំនួនទំព័របន្ថែមសម្រាប់សំណើលើកទី ៦ ស្នើសុំឱ្យទទួលយកភស្តុតាងបន្ថែម ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥។

[13] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម។

11. នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាបានដាក់សំណើទៅអង្គជំនុំជម្រះតុលាការកំពូល សុំបន្ថែមទំព័រចំនួន ១៥ ទំព័រ សម្រាប់សារណាតបទៅនឹងសំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែមរបស់ នួន ជា[14] និង នៅថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតសំណើនេះ[15]។

## III- ច្បាប់ជាធរមាន

12. នួន ជា ព្យាយាមសុំឱ្យទទួលយកភស្តុតាង ដែលមាននៅក្នុងសំណើរលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម អនុលោមតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង និង/ឬ វិធាន ១០៤(១)នៃវិធានផ្ទៃក្នុង[16]។ ក្នុងការអនុវត្តតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូល បានកំណត់នូវបទដ្ឋានដែលមានបីលក្ខខណ្ឌ ដែលតម្រូវឱ្យភាគីដែលស្នើសុំ ត្រូវបង្ហាញឱ្យឃើញថា ភស្តុតាងថ្មីដែលត្រូវបានស្នើលើបណ្តឹងសាទុក្ខនោះ (១) មិនអាចរកបានក្នុងពេលសវនាការ បើទោះបីមានកិច្ចខិតខំប្រឹងប្រែងក្តី (២) អាចជាកត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការដែលកំពុងរងបណ្តឹងសាទុក្ខ និង(៣) ទាក់ទងទៅនឹងការយល់ឃើញជាក់លាក់អំពីអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង[17]។ ពាក់ព័ន្ធនឹងលក្ខខណ្ឌទី ៣ គួរកត់សម្គាល់ជាសំខាន់ថា តាមន័យសម្រាយ ពាក្យថាទាក់ទង គឺទាល់តែទាក់ទងទៅនឹងអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង មិនមែនទាក់ទងទៅនឹងទឡ្ហីករណ៍របស់ភាគីលើបណ្តឹងសាទុក្ខនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលបានគូសបញ្ជាក់ថា ការបង្ហាញដែលថាភស្តុតាងមិនអាចរកបានក្នុងពេលកំពុងជំនុំជម្រះ ទោះបីជាមានការយកចិត្តទុកដាក់ត្រឹមត្រូវហើយក៏ដោយក្តី គឺជា“លក្ខខណ្ឌសំខាន់ណាស់ ដើម្បីចៀសវាងកុំឱ្យមានការប្រើប្រាស់

[14] ឯកសារ **F2/8/2** សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំទំព័របន្ថែម និង សុំដាក់ឯកសារតែមួយភាសា ដើម្បីឆ្លើយតបទៅសំណើលើកទី ៦ របស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងបន្ថែម ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥។

[15] ឯកសារ **F2/8/2/1** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំទំព័របន្ថែម សម្រាប់ចម្លើយតបទៅនឹងសំណើលើកទី ៦ របស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងបន្ថែម ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥។

[16] កថាខណ្ឌ ១៤៩ នៃសំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម សរសេរថា “នៅក្នុងក្របខណ្ឌ អ.វ.ត.ក ការទទួលយកភស្តុតាងថ្មីក្នុងពេលធ្វើបណ្តឹងសាទុក្ខ ត្រូវអនុវត្តតាមវិធាន ១០៤(១) និង ១០៧(១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក”។ ការយោងវិធាន ១០៧(១) ទំនងជាមានកំហុសឆ្គង ដោយសារតែវិធាននេះ អនុវត្តចំពោះពេលវេលាកំណត់សម្រាប់បណ្តឹងសាទុក្ខភ្លាមៗ។

[17] ឯកសារ **F2/5** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥ (“សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការសុំកោះហៅសាក្សី”) ត្រង់កថាខណ្ឌ ១៦។

យុត្តិសាស្ត្រនៃការតវ៉ា ដែលពុំមានប្រសិទ្ធភាព និងជាការរំខាន”[18]។ អង្គជំនុំជម្រះតុលាការកំពូលបាន គូសបញ្ជាក់ថា កាលបរិច្ឆេទដែលពាក់ព័ន្ធចំពោះភាពមិនអាចរកបាននៃភ័ស្តុតាងក្នុងពេលកំពុង សវនាការ អនុលោមតាមវិធាន ១០៨(៧) គឺថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ដែលជាថ្ងៃនៃសេចក្តី សន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១[19]។

13. វិធាននេះកំណត់បទដ្ឋានខ្ពស់មួយ សម្រាប់ទទួលយកភ័ស្តុតាងថ្មីលើបណ្តឹងសាទុក្ខ។ ភ័ស្តុតាងថ្មីនោះ មិនមែនត្រឹមតែមានភាពពាក់ព័ន្ធជាងមុនប៉ុណ្ណោះទេ វាត្រូវតែមានទម្ងន់ និងភាពសំខាន់ ដែលអាច ជា “កត្តាកំណត់ ដើម្បីឈានទៅធ្វើសម្រេចសេចក្តីក្នុងពេលសវនាការ”។ បទដ្ឋានខ្ពស់ដូច្នេះ មាន សារៈសំខាន់យ៉ាងខ្លាំង ដើម្បីការពារកុំឱ្យបណ្តឹងសាទុក្ខបណ្តាលឱ្យមានការជំនុំជម្រះជាលើកទីពីរ ដែលអូសបន្លាយកិច្ចដំណើរការនីតិវិធីឥតប្រយោជន៍ និងជម្រុញឱ្យមានការដោះស្រាយបណ្តឹងដែល ឥតបានការ”[20]។ វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងចែងថា រាល់ភ័ស្តុតាងដែលអនុញ្ញាតឱ្យទទួលយក បានតាមវិធាននេះ ត្រូវបំពេញគ្រប់លក្ខខណ្ឌនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង និងហេតុដូចនេះ ភ័ស្តុតាងនោះ មិនត្រូវ “មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា” ឬ“មិនសមស្របសម្រាប់បញ្ជាក់ អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង” ឬ “មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍”។ អង្គជំនុំជម្រះតុលាការកំពូលបានគូសបញ្ជាក់ថា វិធាននានាដែលគ្រប់គ្រងភាព ទទួលយកបាននៃភ័ស្តុតាង ដែលមានចែងទូទៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អនុវត្តចំពោះការ ពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលចំពោះការស្វែងរក និងការគ្រប់គ្រងភ័ស្តុតាង ដែលមាន នៅចំពោះមុខអង្គជំនុំជម្រះ[21]។

---

[18] ឯកសារ **F2/5** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការសុំកោះហៅសាក្សី ត្រង់កថាខណ្ឌ ១៦។

[19] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការសុំកោះហៅសាក្សី ត្រង់កថាខណ្ឌ ៦៧។

[20] *ព្រះរាជអាជ្ញា ទល់នឹង Kupreškić និង អ្នកផ្សេងទៀត* IT-95-16-A, សេចក្តីសម្រេចលើសំណើរបស់ Drago Josipović, Zoran Kupreškić និង Vlatko Kupreškić សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម អនុលោមតាមវិធាន ១១៥ និង សុំសេចក្តីជូនដំណឹងតាមផ្លូវតុលាការ អនុលោមតាមវិធាន ៨៤(ខ) ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០១ ត្រង់កថាខណ្ឌ ៣។

[21] ឯកសារ **F2/4/3** សេចក្តីសម្រេចបណ្តោះអាសន្នលើផ្នែកខ្លះនៃសំណើលើកទី ១ របស់ នួន ជា សុំឱ្យទទួលយក និង ពិចារណាទៅលើភ័ស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ត្រង់កថាខណ្ឌ ១៦។

14. អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញផងដែរថា អង្គជំនុំជម្រះមានអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន អនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ក្នុងការទទួលយកភ័ស្តុតាងថ្មី "កាលណាប្រយោជន៍យុត្តិធម៌តម្រូវ បន្ទាប់ពីបានពិចារណាទៅលើកាលៈទេសៈជាក់លាក់នៃករណីនោះរួចមក"[22]។ "ក្នុងការសម្រេចដូច្នេះ អង្គជំនុំជម្រះនឹងពិចារណាថាតើភ័ស្តុតាងនោះអាចនាំទៅរកការបង្ហាញការពិតដែរឬយ៉ាងណា"[23]។ សហព្រះរាជអាជ្ញាសូមអះអាងថា "ប្រយោជន៍យុត្តិធម៌" និង "កាលៈទេសៈជាក់លាក់នៃករណីមួយ" គឺចៀសមិនផុតពីការពិចារណាលើកត្តាទាំងបី ដែលអង្គជំនុំជម្រះតុលាការកំពូលបានកំណត់ថា ពាក់ព័ន្ធទៅនឹងការពិចារណាលើភ័ស្តុតាងថ្មីអនុលោមតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង។ លើសពីនេះទៅទៀត វាជាការធ្វើឲ្យខូចប្រយោជន៍ទៅវិញទេ កាលណាប្រើឆន្ទានុសិទ្ធិនេះ ឲ្យផ្ទុយពីគោលបំណងនៃលក្ខខណ្ឌសម្រាប់បទដ្ឋានខ្ពស់ ក្នុងការទទួលយកភ័ស្តុតាងថ្មី ដូចមានចែងក្នុងវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ឧទាហរណ៍ ការយកករណីលើកលែងមកជំនួសច្បាប់ដែលមាន។ ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានរកឃើញថា៖

> ការទទួលយកភ័ស្តុតាង ត្រូវធ្វើឡើងឲ្យស្របតាម"ប្រយោជន៍យុត្តិធម៌" ប្រសិនបើភ័ស្តុតាងនោះពាក់ព័ន្ធទៅនឹងបញ្ហាជាក់ស្តែង ប្រសិនបើភ័ស្តុតាងនោះគួរឲ្យជឿទុកចិត្ត និង ប្រសិនបើភ័ស្តុតាងនោះមានសារៈសំខាន់ ក្នុងការជួយកុំឲ្យសម្រេចខុសលើពិរុទ្ធភាព ឬការកំណត់ទោស ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានបកស្រាយលក្ខណៈវិនិច្ឆ័យខាងក្រោយនោះ ដោយចង់មានន័យថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងអាចរកភ័ស្តុតាងនោះនៅមុននេះ ខ្លួនអាចសម្រេចសេចក្តីផ្សេងពីនេះ"[24]។

15. ភាគីស្នើមានបន្ទុកក្នុងការបង្ហាញថា អង្គជំនុំជម្រះគប្បីទទួលយកភ័ស្តុតាងថ្មីលើបណ្តឹងសាទុក្ខ[25]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានរកឃើញថា "ម្ចាស់សំណើមានបន្ទុកក្នុងការ

---

[22] ឯកសារ **F2/5** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការសុំកោះហៅសាក្សី ត្រង់កថាខណ្ឌ ១៧។

[23] ឯកសារ **F2/5** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការសុំកោះហៅសាក្សី ត្រង់កថាខណ្ឌ ១៧។

[24] *ព្រះរាជអាជ្ញា ទល់នឹង Kupreskic និង អ្នកផ្សេងទៀត* IT-95-16-A, សេចក្តីសម្រេចលើការទទួលយកភ័ស្តុតាងបន្ថែម បន្ទាប់ពីសវនាការ កាលពីថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០១ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៦។

[25] ឯកសារ **F2/5** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការសុំកោះហៅសាក្សី ត្រង់កថាខណ្ឌ ១៦។ *ព្រះរាជអាជ្ញា ទល់នឹង Kvocka និង អ្នកផ្សេងទៀត*, IT-98-30/1-A, សេចក្តីសម្រេចលើសំណើសុំឲ្យទទួលស្គាល់ភ័ស្តុតាងបន្ថែមរបស់ម្ចាស់បណ្តឹង

កំណត់ឱ្យបានច្បាស់លាស់នូវសំអាងហេតុជាក់លាក់នៃអង្គហេតុ ដែលអង្គជំនុំជម្រះសាលាដំបូងបាន រកឃើញរួចហើយ ពាក់ព័ន្ធនឹងភ័ស្តុតាងថ្មីដែលបានស្នើនោះ និងត្រូវកំណត់ឱ្យបានច្បាស់លាស់ គ្រប់គ្រាន់នូវផលប៉ះពាល់នៃភ័ស្តុតាងបន្ថែម ដែលអាចមានទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ សាលាដំបូង”[26]។ ក្នុងករណីដែលភាគីម្ចាស់សំណើ មិនអាចបង្ហាញចំណុចខាងលើបាន អង្គជំនុំជម្រះ នេះអាចសម្រេចបដិសេធសំណើនោះភ្លាមៗ[27]។

16. ទោះបី នៅក្រោយពេលភ័ស្តុតាងថ្មី ត្រូវបានទទួលយកលើបណ្តឹងសាទុក្ខយ៉ាងណាក៏ដោយ ក៏បទដ្ឋាន ត្រួតពិនិត្យទូទៅលើបណ្តឹងសាទុក្ខនៅតែអនុវត្តដដែល។ ដូច្នេះ ភ័ស្តុតាងដែលស្នើសុំឱ្យទទួលស្គាល់ បន្ថែមនោះ ត្រូវតែមានទម្ងន់ខ្លាំង ដូចគ្នាទៅនឹងភ័ស្តុតាងដទៃទៀត ដែលត្រូវបានដាក់នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងបញ្ហានោះ និងត្រូវតែក្លាយជាបញ្ហាដ៏សំខាន់មួយក្នុងសាលក្រម ដែលបើអត់មានវា អង្គជំនុំជម្រះពិតជាមិនអាចសម្រេចសាលក្រមមួយបាន។

## IV- ចម្លើយតប

17. នួន ជា ស្នើសុំឱ្យទទួលយកឯកសារចំនួន ២២ និងកោះហៅសាក្សីចំនួនពីររូប។ នួន ជា មិនបាន បំពេញបន្ទុករបស់ខ្លួនក្នុងការបង្ហាញថា ឯកសារណាមួយដែលខ្លួនបានស្នើសុំឱ្យទទួលយកនោះ បំពេញទៅតាមបទដ្ឋានសម្រាប់ការទទួលយកភ័ស្តុតាងថ្មីលើបណ្តឹងសាទុក្ខ ឬផ្តល់យុត្តិកម្មក្នុងកោះ ហៅសាក្សីទាំងពីរនោះទេ។ សហព្រះរាជអាជ្ញានឹងឆ្លើយតបទៅឯកសារនីមួយៗដូចខាងក្រោម។ ប៉ុន្តែ ជាបឋម ជាការចាំបាច់ សហព្រះរាជអាជ្ញាត្រូវឆ្លើយតបទៅនឹងចំណុចសំខាន់ៗមួយចំនួនសិន។

---

សាទុក្ខ អនុលោមតាមវិធាន ១១៥ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៤ (កត់សម្គាល់ថា “ម្ចាស់បណ្តឹងសាទុក្ខ Prcac មិនបានបញ្ជាញ ឱ្យឃើញថា [ភ័ស្តុតាង] នោះអាចជាមូលដ្ឋានក្នុងការសម្រេចមួយ ដើម្បីឈានទៅដល់ការសម្រេចសេចក្តីនៅពេលជំនុំជម្រះនោះ ឡើយ”)។

[26] *ព្រះរាជអាជ្ញា ទល់នឹង D. Milosevic,* IT -98-29/1-A, "សេចក្តីសម្រេចលើសំណើលើកទី ៣ របស់ Dragomir Milosevic ស្នើសុំបង្ហាញភ័ស្តុតាងបន្ថែម", ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៩ ត្រង់កថាខណ្ឌ ១១។

[27] *ព្រះរាជអាជ្ញា ទល់នឹង D. Milosevic,* IT -98-29/1-A, "សេចក្តីសម្រេចលើសំណើលើកទី ៣ របស់ Dragomir Milosevic ស្នើសុំបង្ហាញភ័ស្តុតាងបន្ថែម", ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៩ ត្រង់កថាខណ្ឌ ១១។

### *ក. ការប៉ុនប៉ងរបស់ នួន ជា ក្នុងការចង់តាក់តែងប្រវត្តិសាស្ត្រខ្មែរក្រហមឡើងវិញ ទៅតាមចំណង់របស់គាត់ មិនទទួលបានជោគជ័យ*

18. ស្ទើរតែពាក់កណ្តាលនៃសារណារបស់ខ្លួន នួន ជា ផ្តោតទៅលើប្រធានបទតែមួយគឺ "ក្បាលនិងកន្ទុយក្រពើ" ដែលមានភាពពាក់ព័ន្ធតិចតួចទៅនឹងសំណើសុំទទួលយកភ័ស្តុតាងថ្មី ឬការស្នើសុំកោះហៅសាក្សីបន្ថែមរបស់គាត់នោះទេ។ ផ្ទុយទៅវិញ សារណានោះ គឺជាការប៉ុនប៉ងរបស់គាត់ ដើម្បីដាក់បញ្ចូលទៅក្នុងសំណុំឯកសារសាធារណៈនូវចំណារប្រវត្តិសាស្ត្រទៅតាមការចង់បាន និង បែបកាឡៃការពិតរបស់គាត់ ក្នុងគោលបំណងដោះសារឲ្យរបបរបស់គាត់ រួចផុតពីបទឧក្រិដ្ឋទាំងឡាយ។ អ្វីដែលគួរឲ្យសង្ស័យ គឺអង្គហេតុនៃប្រវត្តិសាស្ត្រ ដែលដកស្រង់នៅក្នុងសារណារបស់គាត់ ដោយសំអាងលើភ័ស្តុតាង ដែលបានមកពីសារឃោសនាដែលមិនគួរឲ្យទុកចិត្តរបស់ខ្មែរក្រហមខ្លួនឯង[28] និងដកស្រង់យកភ័ស្តុតាងដែលមានក្នុង "ចម្លើយសារភាព"ពី ស-២១[29]។ ឧទាហរណ៍នៃការកាឡៃការពិត គឺការអះអាងជាគោលរបស់ នួន ជា ដែលថា "យើងដឹងថា ផែនការទាំងនេះជាផែនការពិតដោយវាកើតឡើងដូច្នេះមែន។ សោ ភឹម ពិតជាប៉ុនប៉ងធ្វើរដ្ឋប្រហារមែន"[30]។ ការអះអាងនោះ គឺគ្មានចុះលេខជើងទំព័រ និងគ្មានឯកសារយោង ដើម្បីគាំទ្រអ្វីទាំងអស់។ ប្រភពផ្សេងទៀតដែលដកស្រង់ក្នុងផ្នែកនេះ គឺនិយាយជាន់កែងខ្លួនឯង។ សូម្បីតែមនុស្សរបស់គាត់ ក៏ត្រូវបានបោសសម្អាតដោយកងកម្លាំងមជ្ឈិម។ សោ ភឹម មិនជឿថា គាត់ជាមុខសញ្ញារបស់ ប៉ុល ពត និង នួន ជា និងចាកចេញទៅភ្នំពេញដោយមានអង្គរក្សតែ ៦ នាក់ប៉ុណ្ណោះ។ សោ ភឹម ត្រូវបានឡោមព័ទ្ធ និង បាញ់ដាក់ដោយកងកម្លាំងមជ្ឈិម។ គាត់បានធ្វើអត្តឃាត។ បន្ទាប់មក ដូចអ្វីដែល នួន ជា អះអាងក្នុងសារណាគាត់ថាជា

---

[28] ដើម្បីបង្ហាញអំពីអត្ថិភាពនៃការឃុបឃិតបែបរវើរវាយរបស់ខ្មែរក្រហម សារណានោះដកស្រង់ពាក្យឃោសនារបស់បក្សកុម្មុនីស្តកម្ពុជាចំនួន ៤ លើក— សេចក្តីប្រកាសព័ត៌មានដែលគួរឲ្យអស់សំណើច ដែលមានរាយនាមកម្មាភិបាល ដែលត្រូវបានបោសសម្អាតអស់ និង ស៊ឺន ង៉ុក មិញ ដែលជាមេដឹកនាំរបស់បក្ស ប៉ុល ពល និង នួន ជា ដែលបានស្លាប់នៅប្រទេសចិន ក្នុងឆ្នាំ ១៩៧២។ ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់លេខជើងទំព័រ 110, 112, 114 និង 211។ *សូមមើលផងដែរ* ដូចក្នុងឯកសារខាងលើ ត្រង់លេខជើងទំព័រ 99 ដែលដកស្រង់ "Press Communiqué របស់អ្នកនាំពាក្យក្រសួងឃោសនាការ និង ព័ត៌មាននៃកម្ពុជាប្រជាធិបតេយ្យ ស្តីពីការកម្ទេចផែនការថ្មីនៃការធ្វើរដ្ឋប្រហារ ដែលបង្កឡើងដោយសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងគោលបំណងទម្លាក់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ" ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៧៨។

[29] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៤៥។

[30] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ២៥។

"វិធីសាស្ត្រអនុវត្តវិធានការ"[31] របស់ ប៉ុល ពត និង នួន ជា ចំពោះខ្មាំង ពេលនោះប្រពន្ធ និងកូនរបស់ សោ ភឹម ត្រូវបានសម្លាប់"[32]។

19. សំខាន់ជាងនេះទៅទៀតនោះ ឧបមាថាការអះអាងបែបខ្វះការទុកចិត្តទាំងអស់របស់ នួន ជា ពិតដូច គាត់ថាមែន ហើយការដឹកនាំដែលសាហាវព្រៃផ្សៃឥតមេត្តារបស់ខ្មែរក្រហម ត្រូវបានហែកហួរដោយ ជម្លោះផ្ទៃក្នុង និងការឃុបឃិតគ្នាក្បត់យ៉ាងណាក្តី ក៏ភ័ស្តុតាងនេះគ្មានឥទ្ធិពលអ្វីទៅលើបទចោទផ្នែក ព្រហ្មទណ្ឌដែលជាកម្មវត្ថុក្នុងករណីនេះនោះឡើយ។ នួន ជា មិនបានប៉ុនប៉ងអះអាងបញ្ជាក់ថា អំពើ អមនុស្សធម៌ក្នុងការផ្លាស់ទីលំនៅដោយបង្ខំ ដំណាក់កាលទី ១ និង ២ មិនមែនជាគោលនយោបាយ របស់មជ្ឈិមនោះទេ។ ជាការពិត កាលពីមុន គាត់បានទទួលស្គាល់ថា គាត់គាំទ្រគោលនយោបាយ នោះ[33]។ ម្យ៉ាងទៀត នៅក្នុងផ្នែកនេះ គាត់ក៏មិនបានលើកឡើងអំពីគោលនយោបាយរបស់មជ្ឈិម ក្នុង ការកំណត់យកជាគោលដៅលើអ្នករដ្ឋការ លន់ នល់ និង រដ្ឋការជាន់ខ្ពស់របស់ លន់ នល់ នៅទូទាំង ប្រទេសកម្ពុជានោះដែរ ដែលគោលនយោបាយទាំងនោះ ជាកម្មវត្ថុនៃបណ្តឹងសាទុក្ខនេះឯង។ គោលបំណងរបស់ នួន ជា គឺគ្មានអ្វីក្រៅពីចង់បង្ហាញឱ្យឃើញថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានកុប្បកម្មប្រឆាំងតែប៉ុណ្ណោះឯង។ ទោះជាយ៉ាងនេះក្តី សូម្បីតែ នួន ជា ខ្លួនឯងផ្ទាល់ក៏មិនបាន អះអាងបញ្ជាក់ថា មានបទឧក្រិដ្ឋណាមួយ ដែលតុលាការបានរកឃើញថា គាត់មានពិរុទ្ធក្នុង សំណុំរឿង ០០២/០១ ត្រូវបានប្រព្រឹត្តឡើងជាផ្នែកមួយនៃកុប្បកម្មប្រឆាំងនេះនោះទេ។

20. គ្មានអ្វីជារឿងគួរឱ្យភ្ញាក់ផ្អើលទេ នៅពេលដែលមានមនុស្សក្រោកតវ៉ាប្រឆាំងនឹងរបបផ្តាច់ការមួយ ដែលយកពួកគេជាមុខសញ្ញាក្នុងការសម្លាប់ បំផ្លិចបំផ្លាញសាសនា និងជីវិតគ្រួសាររបស់ពួកគេ និង

---

[31] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៥១។

[32] ឯកសារ **E3/1593** Kiernan, របបប៉ុល ពត ទំព័រ 397-400, ត្រង់ ENG 01150205-01150207។

[33] *សូមមើលឧទាហរណ៍* ឯកសារ **E1/237.1** ប្រតិចារិក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ត្រង់នាទី 10.39.16 ("និយាយឱ្យខ្លី បក្ស កុម្មុនីស្តកម្ពុជាមានមូលហេតុច្បាស់លាស់ សម្រាប់ការជម្លៀសប្រជាជន។ ការជម្លៀសនេះ គឺធ្វើឡើងដើម្បីធានាសុវត្ថិភាពរបស់ ប្រជាជន និង ដើម្បីរំដោះពួកគេឱ្យរួចផុតពីអំពើទាសភាព និង អយុត្តិធម៌")។ ឯកសារ **E1/14.1** ប្រតិចារិក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ត្រង់នាទី 15.28.03 ("កិច្ចប្រជុំនោះបានសម្រេចជាឯកច្ឆន្ទដូចតទៅ៖ ទី ១ ក្នុងករណី ភ្នំពេញត្រូវបានរំដោះ យើងត្រូវជម្លៀស ប្រជាជនចេញពីក្រុងភ្នំពេញ និង ទីប្រជុំជនជាបណ្តោះអាសន្នសិន ដើម្បីវិភាគស្ថានការណ៍មួយរយៈ ជាពិសេស ដើម្បីវិភាគ អាកប្បកិរិយារបស់វៀតណាម")។

ធ្វើឱ្យពួកគេរងទុក្ខវេទនា និងមានការភ័យខ្លាច។ ជាការពិត មានប្រជាជនខ្មែរជាច្រើនបានក្រោកតវ៉ាប្រឆាំងរបប ប៉ុល ពត តាមដែលពួកគេអាចធ្វើបាន។ ប៉ុន្តែ ការប៉ុនប៉ងរបស់ នួន ជា ដើម្បីទម្លាក់កំហុសទៅលើការតវ៉ាប្រឆាំងបទឧក្រិដ្ឋរបស់គាត់ ថាជាអំពើឧក្រិដ្ឋ គឺពិតជាគ្មានអង្គហេតុណាមួយគាំទ្រជំហរដូច្នេះ នៅក្នុងសំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែមនេះទាល់តែសោះ។

21. ការប៉ុនប៉ងរបស់ នួន ជា ដើម្បីបង្ហាញអំពីភាពពាក់ព័ន្ធនៃកម្មវត្ថុរបស់ភ័ស្តុតាងក្នុងសំណើនេះ គឺពោរពេញទៅដោយការស្មាន និងការបំភាន់ការពិត។ ឧទាហរណ៍ នួន ជា ព្យាយាមចង់ពឹងផ្អែកលើភ័ស្តុតាងរបស់ ទាត់ ធឿន (Toat Thouen ) ដើម្បីគាំទ្រទ្រឹស្តីដែលមានការឃុបឃិតរបស់គាត់[34] ទោះបីបើតាមសម្តីរបស់ នួន ជា គាត់ថា ទាត់ ធឿន "ជាសាក្សីដ៏ស័ក្តិសមបំផុតមួយរូប ដើម្បីធ្វើតេស្តជំហរការពារក្តីដ៏សំខាន់ជាទូទៅរបស់ នួន ជា ក្នុងផ្នែកទាំងពីរនៃសំណុំរឿង ០០២"[35] ដែលសាក្សីរូបនេះបានផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះ ពាក់ព័ន្ធទៅនឹងផែនការបះបោរទាក់ទិននឹង រស់ ញឹម សោ ភឹម និង អ្នកដទៃទៀតនោះ គាត់ "មិនអាចនិយាយបានថា វាត្រូវ ឬអត់នោះទេ"[36]។ ជាថ្មីម្តងទៀត នួន ជា ពឹងផ្អែកលើភ័ស្តុតាងរបស់ ទាត់ ធឿន ដើម្បីគាំទ្រការអះអាងរបស់គាត់ ដែលថា អាវុធត្រូវបានប្រមូល និងទុកដាក់ ដើម្បីជួយដល់ការបះបោរនោះ[37] ទោះបី ទាត់ ធឿន បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះថា គោលបំណងបែបនេះ គឺគ្មានទេ៖

> [មេធាវីការពារក្តី នួន ជា]៖ តើនោះជាបំណងតាំងពីដំបូងមែនទេ? ក្នុងការលាក់អាវុធទាំងអស់នេះ ដើម្បីឱ្យ ញឹម អ្នកឯង និង អ្នកដទៃទៀត អាចចាប់ផ្តើមការបះបោរប្រដាប់អាវុធប្រឆាំង ប៉ុល ពត?
>
> [សាក្សី SCW -5]: ពុំមានហេតុផលដូច្នេះនោះទេ[38]។

---

[34] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៣២, ៣៨។

[35] ឯកសារ **F2/6** សំណើលើកទី ៤ របស់ នួន ជា ស្នើសុំឱ្យពិចារណាលើភ័ស្តុតាងបន្ថែម ទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥ ត្រង់កថាខណ្ឌ ២៤ ( មានគូសបញ្ជាក់បន្ថែមលើសពីទម្រង់ដើម)។

[36] ឯកសារ **F1/3.1** ប្រតិចារិក ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ ត្រង់នាទី 11.03.04។

[37] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៣៨។

[38] ឯកសារ **F1/3.1** ប្រតិចារិក ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ ត្រង់នាទី 10.48.07។

...

[សាក្សី SCW -5]: ពីដំបូងឡើយ អាវុធទាំងនោះ មិនមែនយកមកស្តុកទុកដោយសម្ងាត់ ដើម្បីចាប់ផ្តើមការបះបោរប្រឆាំង ប៉ុល ពត នោះទេ[39]។

22. ភាគច្រើននៃសាច់រឿងរបស់ នួន ជា គឺគ្មានសំអាងអង្គហេតុពិតអ្វីទាល់តែសោះ។ ឧទាហរណ៍ គាត់អះអាងដោយគ្មានភ័ស្តុតាងថា "ការផ្ទុះគ្រាប់នៅសៀមរាប ត្រូវបានសម្របសម្រួលដោយ កុយ ធួន ដែលជាលេខាភូមិភាគឧត្តរ រួមជាមួយ សុត ដែលជាលេខាតំបន់១០៦ ..."[40]។ ត្រង់កន្លែងខ្លះទៀត គាត់គិតថាជាការត្រឹមត្រូវក្នុងការ ដែលគាត់អាចផ្តល់នូវការយល់ឃើញតាមចំណាប់ចិត្តរបស់ខ្លួន ពាក់ព័ន្ធនឹងរឿងហេតុផ្សេងៗ ដោយគ្មានដកស្រង់ឯកសារយោង និងដោយឥតអៀនខ្មាស់៖

មេធាវីការពារក្តីជឿថា ការពន្យល់ដែលអាចមានចំពោះរឿងនេះគឺថា បក្សពលករកម្ពុជាបានសម្រេចថា មេដឹកនាំថ្នាក់ភូមិភាគគួរធ្វើសកម្មភាពទៅតាមការផ្តួចផ្តើមរបស់ខ្លួនជាមុន និងឆ្លៀតឱកាសនានាដែលពួកគេមាន ក្នុងការបង្កឲ្យមានការរំជើបរំជួល ការច្របូកច្របល់ និងការបះបោរផ្ទៃក្នុងប្រទេស។ តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងការទាយទុកជាមុនអំពីលទ្ធភាពនៃការបរាជ័យចំពោះការប៉ុនប៉ងទាំងនេះ បន្ទាប់មកភូមិភាគនឹងរៀបចំការសម្របសម្រួល និងបង្កើនការខិតខំប្រឹងប្រែងរបស់ខ្លួន។ មេធាវីការពារក្តីយល់ឃើញថា ទីបំផុតមហាផែនការនេះគឺជា "ផែនការ ក" របស់វៀតណាម...។ សំខាន់បំផុតនោះគឺថា មេធាវីការពារក្តីយល់ឃើញថា "ផែនការ ក" អាចអនុវត្តបាន តែនៅពេលវៀតណាមផ្តល់ភ្លើងខៀវប៉ុណ្ណោះ[41]។

សូមបញ្ជាក់ឲ្យច្បាស់ថា នួន ជា មិនបានបញ្ចូលសូម្បីតែឯកសារយោងមួយ ដើម្បីគាំទ្រការអះអាងណាមួយនៅក្នុងកថាខណ្ឌទាំងមូលនោះ។

---

[39] ឯកសារ **F1/3.1** ប្រតិចារិក ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ ត្រង់នាទី 10.56.01។

[40] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៤៤។

[41] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៤៦។

23. ការស្មាន និងការបន្តនិទានរឿងបែបនេះ នៅតែបន្តទៅផ្នែកផ្សេងទៀត ដោយ នួន ជា អះអាងថា "ចំណុចលម្អិតមួយចំនួននៃផែនការ ក ជាស្រមោល និងមានតិចតួច"[42]។ ទោះជាប៉ុណ្ណឹងហើយក្តី ក៏គាត់នៅតែមិនឈប់ និងថែមទាំងបន្តអះអាងនៅក្នុងកថាខណ្ឌដដែលទៀតថា "មេធាវីការពារក្តីយល់ឃើញថា ផែនការទាំងនេះ ដែលផែនការនីមួយៗមានគោលបំណងធ្វើការបង្កើតការវាយប្រហារដោយវិធីផ្សេងៗគ្នា ទំនងជាមានបំណងបង្កើតការវាយប្រហារជាទ្រង់ទ្រាយធំ និងពេញលេញ និង មានជាប្រព័ន្ធ ដែលឡោមព័ទ្ធ និងផ្តួលរំលំ ប៉ុល ពត និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដូចទៅនឹងដង្កៀមួយដែរ"[43]។ ជាថ្មីម្តងទៀត គាត់មិនបានដកស្រង់ឯកសារយោងអ្វីទាំងអស់ ដើម្បីគាំទ្រការយល់ឃើញទាំងនេះ។ មិនតែប៉ុណ្ណោះ គាត់បែរជាអះអាង វាពិតជាមិនយុត្តិធម៌ចំពោះគាត់ទេដែល "មានកើតចេញនូវបរិយាកាសចម្រូងចម្រាស់ និងការឃុបឃិតគ្នា"[44] ដែលហ៊ុមព័ទ្ធទឡ្ហីករណ៍របស់មេធាវីការពារក្តី។

## *ខ. នួន ជា ពឹងផ្អែកលើភស្តុតាងដែលតុលាការមិនបានទទួលយកត្រឹមត្រូវ ឬភស្តុតាងដែលមិនបានស្នើសុំឲ្យទទួលយកត្រឹមត្រូវ*

24. ដោយសារតែការប៉ុនប៉ងគាំទ្រប្រវត្តិសាស្ត្រខ្មែរក្រហមតាមបែបសេរីនិយមរបស់គាត់ នួន ជា ពឹងផ្អែកលើឯកសារភស្តុតាងជាច្រើន ដែលតុលាការមិនបានទទួលយក និងឯកសារទាំងនោះពុំមានក្នុងសំណុំរឿង។ មិនតែប៉ុណ្ណោះ គាត់មិនបានស្វះស្វែងសុំឲ្យតុលាការទទួលយកភស្តុតាងទាំងនោះនៅក្នុងតំណាក់កាលនៃសំណុំរឿង ០០២/០១ នោះទេ[45]។ គាត់មិនបានជម្រាបដំណឹងឲ្យអង្គជំនុំជម្រះនេះបានដឹង ឬគាត់មិនបានព្យាយាមពន្យល់អំពីមូលហេតុអ្វីទាំងអស់។ ឯកសារទាំងនេះ រួមមានអត្ថបទកាសែត[46] ជំពូកដកស្រង់ចេញពីសៀវភៅ[47] និក្ខេបបទ[48] ឯកសារសន្និសីទ[49] របាយការណ៍អង្គការឃ្លាំ

---

[42] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៤៧។

[43] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៤៧។

[44] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ២១។

[45] *សូមមើល* ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម ត្រង់លេខជើងទំព័រ 61, 63, 70, 71, 72, 76 82, 83, 84, 95, 97, 122, 129, 143, 148, 152, 154, 155, 181, 182, 183, 198, 199, 216, 222, 231 243, 247, 248, 257។

[46] ឯកសារ **F2/8.1.26** ឯកសារភ្ជាប់មកជាមួយលេខ ២៦៖ គុច ណារ៉ែន, 'នាយករដ្ឋមន្ត្រីបង្គាប់ឲ្យចាប់ខ្លួនសមាជិកព្រឹទ្ធសភាដោយសារអត្ថបទផ្សាយតាមហ្វេសប៊ុក', កាសែត Cambodian Daily, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៥, ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ

មើលសិទ្ធិមនុស្ស[50] កិច្ចពិភាក្សាដេញដោលរបស់សភាសហរដ្ឋអាមេរិក[51] និងឯកសារដែលគ្មានការបកប្រែ[52]។

---

២០១៥ (លេខដើងទំព័រ 76)។ ឯកសារ **F2/8.1.24** ឯកសារភ្ជាប់មកជាមួយលេខ ២៤៖ Nayan Chanda, 'កាលវិភាគសម្រាប់ការចូលគ្រប់គ្រងមួយ នៃទស្សនាវដ្តី Far Eastern Economic Review, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៧៩, ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥, (លេខដើងទំព័រ 63, 72, 222, 243, 247, 248)។ ឯកសារ **F2/8.1.29** ឯកសារភ្ជាប់មកជាមួយលេខ ២៩៖ Anthony Paul, 'Plot Details Filter Through', Far Eastern Economic Review, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៧៨, ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ (លេខដើងទំព័រ 143, 148, 152, 155, 182, 183, 198, 199)។ ឯកសារ **F2/8.1.30** ឯកសារភ្ជាប់មកជាមួយលេខ ៣០៖ James Fenton, 'Cambodia: Communism Alters Lifestyle', Washington Past, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៤ (លេខដើងទំព័រ 181)។ ឯកសារ **F2/8.1.32** ឯកសារភ្ជាប់មកជាមួយលេខ ៣២៖ Nayan Chanda, 'Cambodia: Fifteen Days that Shook Asia', ផ្សាយក្នុងទស្សនាវដ្តី Far Eastern Economic Review, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៧៩, ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ (លេខដើងទំព័រ 257)។

[47] ឯកសារ **F2/8.1.23** ឯកសារភ្ជាប់មកជាមួយលេខ ២៣៖ Hoang Van Hoan, A Drop in the Ocean: Hoang Van Hoan's Revolutionary Reminiscences 1988 (សម្រង់អត្ថបទ), ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ (លេខដើងទំព័រ 70, 82, 231)។ ឯកសារ **F2/8.1.28** ឯកសារភ្ជាប់មកជាមួយលេខ ២៨៖ Margaret Slocomb, សាធារណរដ្ឋប្រជាមានិតកម្ពុជា, 1979-1989៖ បដិវត្តក្រោយ ប៉ុល ពត, 2003 (សម្រង់អត្ថបទ), ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ (លេខដើងទំព័រ 95, 97, 122)។ ឯកសារ **F2/8.1.31** ឯកសារភ្ជាប់មកជាមួយលេខ ៣១៖ Huang Hua, 'បញ្ហាជាមួយឥណ្ឌូចិន, Albania and Yugoslavia', in King C. Chen (ed.), China and the Three Worlds, 1979 (extract), ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ (លេខចុងទំព័រ 216)។

[48] ឯកសារ **F2/8.1.25** ឯកសារភ្ជាប់មកជាមួយលេខ ២៥៖ Jon James Alexiou, 'គោលនយោបាយបរទេសរបស់សាធារណរដ្ឋប្រជាមានិតចិនចំពោះសាធារណរដ្ឋសង្គមនិយមវៀតណាម, 1975-1979' 1982 (សម្រង់អត្ថបទ), ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ (លេខចុងទំព័រ 71, 234)។

[49] ឯកសារ **F2/8.1.22** ឯកសារភ្ជាប់មកជាមួយលេខ ២២៖ Christian Oesterheld 'សង្គមនិយមអាល្លឺម៉ង់ខាងកើត និង បដិវត្តខ្មែរក្រហម៖ Insights from the GCR's Diplomatic Archives', Vienna 10th International Academic Conference, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៤, កថាខណ្ឌ 559-547, ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ (លេខចុងទំព័រ 61)។

[50] ឯកសារ **E347.3** អង្គការឃ្លាំមើលសិទ្ធិមនុស្ស, *៣០ ឆ្នាំក្រោមការគ្រប់គ្រងរបស់ ហ៊ុន សែន៖ អំពើហិង្សា, ការបង្រ្កាប, និង អំពើពុករលួយនៅប្រទេសកម្ពុជា, ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៥* (*លេខចុងទំព័រ* 129) ។

[51] ឯកសារ **F2/8.1.27** ឯកសារភ្ជាប់មកជាមួយលេខ ២៧៖ គោលនយោបាយរបស់សហរដ្ឋអាមេរិច ចំពោះឥណ្ឌូចិនចាប់តាំងពីវៀតណាមចូលកាន់កាប់ប្រទេសកម្ពុជា៖ សវនាការនៅចំពោះមុខអនុគណៈកម្មាធិការស្តីពីកិច្ចការអាស៊ី និង ប៉ាស៊ីហ្វិក នៃគណៈកម្មាធិការកិច្ចការបរទេស, សភាតំណាងរាស្ត្រ, 15, 21, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៨១ (សម្រង់អត្ថបទ), ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ (លេខដើងទំព័រ 83, 84)។

25. ឯកសារទាំងអស់ខាងលើនេះសុទ្ធតែអាចរកបានក្នុងពេលជំនុំជម្រះ លើកលែងតែឯកសារចំនួនបី[53] ប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី នួន ជា មិនបានស្វះស្វែងសុំដាក់វានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ឡើយ។ ជាងនេះទៅទៀត គាត់មិនបានស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកឯកសារទាំងនេះ នៅក្នុងសំណើទាំង ៦ លើក ដែលសុំឱ្យទទួលយកភស្តុតាងបន្ថែម ដែលគាត់បានដាក់លើបណ្តឹងសាទុក្ខកន្លងមកនោះទេ។ តាមពិត ភាគច្រើននៃឯកសារទាំងនេះ មិនត្រឹមតែអាចរកបានក្នុងពេលជំនុំជម្រះប៉ុណ្ណោះទេ ក្នុងពេលកំពុងស៊ើបអង្កេតក៏អាចរកវាបានផងដែរ គឺឯកសារទាំងនេះមានតាំងពីទសវត្សន៍ឆ្នាំ ១៩៨០ មកម្ល៉េះ។ ច្បាស់ណាស់ នួន ជា មិនបានដាក់សំណើឱ្យទាន់ពេលវេលាក្នុងពេលកំពុងស៊ើបអង្កេត ឬក្នុងពេលជំនុំជម្រះ ដើម្បីស្នើសុំឱ្យទទួលស្គាល់ឯកសារទាំងនេះ ហើយឥឡូវនេះ គាត់កំពុងប៉ុនប៉ងប៉ះប៉ូវនូវភាពបរាជ័យ និងការខកពេលរបស់គាត់ដោយស្វាត់ៗលើបណ្តឹងសាទុក្ខនេះ។

26. មិនតែប៉ុណ្ណោះ នៅពេលដែលគាត់ពឹងផ្អែកលើឯកសារដែលគ្មានក្នុងសំណុំរឿងទាំងនេះ នួន ជា បង្ហាញដោយមិនត្រឹមត្រូវម្តងហើយម្តងទៀត ទាំងខ្លឹមសារ និងបរិបទនៃសំណើរបស់គាត់។ ឧទាហរណ៍ នួន ជា ពឹងផ្អែកលើនិក្ខេបបទ ជាឯកសារគាំទ្រគោលតែមួយមុខសម្រាប់ការអះអាងបញ្ជាក់ថា វៀតណាម "បានបញ្ចូលពួកផ្តាច់ខ្លួន និងជនភៀសខ្លួនកម្ពុជា"[54] រួមគ្នាបង្កើតរណសិរ្សយោធាមួយ ដែលចាប់ផ្តើមនៅរដូវក្តៅក្នុងឆ្នាំ ១៩៨៧។ សេចក្តីយោងទៅរកទំព័រដែលបានដកស្រង់នៃនិក្ខេបបទនោះ គ្មានបង្ហាញភស្តុតាងដូច្នេះនោះទេ។ ផ្ទុយទៅវិញ ម្ចាស់និក្ខេបបទគ្រាន់តែគូសបញ្ជាក់ថា នៅចុងឆ្នាំ ១៩៧៧

---

[52] ឯកសារ **F2/8.1.21** ឯកសារភ្ជាប់មកជាមួយលេខ ២១៖ 'Tweed Karner der Staten – Generaal', no. 587, 1976-1977, កថាខណ្ឌ 1171-1172, ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ (លេខជើងទំព័រ 61)។

[53] ឯកសារ **F2/8.1.22** ឯកសារភ្ជាប់មកជាមួយលេខ ២២៖ Christian Oesterheld 'សង្គមនិយមអាល្លឺម៉ង់ខាងកើត និង បដិវត្តន៍ខ្មែរក្រហម៖ Insights from the GCR's Diplomatic Archives', Vienna 10th International Academic Conference, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ 559-547, ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥។ **E347.3** អង្គការឃ្លាំមើលសិទ្ធិមនុស្ស, *៣០ ឆ្នាំក្រោមការគ្រប់គ្រងរបស់ ហ៊ុន សែន៖ អំពើហិង្សា, ការបង្ក្រាប, និង អំពើពុករលួយនៅប្រទេសកម្ពុជា,ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៥។* ឯកសារ **F2/8.1.26** ឯកសារភ្ជាប់មកជាមួយលេខ ២៦៖ 'នាយករដ្ឋមន្ត្រីបង្គាប់ឱ្យចាប់ខ្លួនសមាជិកព្រឹទ្ធសភា ដោយសារអត្ថបទផ្សាយតាមហ្វេសប៊ុក', កាសែត Cambodian Daily, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៥, ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ (លេខជើងទំព័រ 76)។

[54] ឯកសារ **F2/8** សំណើលើកទី ៦ សុំដាក់ភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ២៥ លេខជើងទំព័រ 71, 234។

“វៀតណាមបានដកចេញពីប្រទេសកម្ពុជា ដោយនាំយកជនភៀសខ្លួនខ្មែរជាច្រើនទៅជាមួយផង”[55]។ ចំណុចនេះមិនត្រឹមតែកើតឡើងនៅមុខកាលវិភាគដែល នួន ជា បានអះអាងរហូតដល់ទៅ ៦ ខែប៉ុណ្ណោះទេ គ្មានត្រង់ណាមួយដែលសរសេរថា ជនភៀសខ្លួន ជាផ្នែកមួយនៃក្រុមឃោឋាណាមួយនោះទេ។

27. ជាអកុសល ការបំភាន់ការពិតនេះ មិនមែនជាករណីតែឯកឯងមួយ ពាក់ព័ន្ធនឹងឯកសារដែលគ្មានក្នុងសំណុំរឿងនោះទេ។ នួន ជា បំភាន់ប្រភពមួយម្តងទៀត នៅក្នុងការដកស្រង់បន្ទាប់មួយទៀត ពោលគឺឯកសារយោងរបស់ នួន ជា សម្រាប់គាំទ្រការអះអាងថា រណសិរ្សកងទ័ពត្រូវបានបង្កើតឡើងដោយវៀតណាម ពីចំណោមជនភៀសខ្លួន គឺបង្កើតឡើងក្នុងចេតនា “ចូលរួមក្នុងការឈ្លានពាន ហើយបន្ទាប់មកបង្កើតរដ្ឋាភិបាលអាយ៉ងថ្មីមួយនៅភ្នំពេញ ដែលត្រួតត្រាដោយវៀតណាម”[56]។ អត្ថបទដែលបានដកស្រង់នោះ គ្មានបានសរសេរដូច្នេះនោះទេ។ អត្ថបទនោះ គ្រាន់តែបង្ហាញអំពីពាក្យចចាមអារ៉ាមពី “ជនកុម្មុនីស្តកម្ពុជាដែលបានហ្វឹកហ្វឺននៅហាណូយ”ម្នាក់នៅក្នុងជំរំជនភៀសខ្លួននៅវៀតណាម “ពិភាក្សាអំពីបញ្ហានៃរដ្ឋាភិបាលថ្មីនៅកម្ពុជា”[57]។

***គ. សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងថ្មី បង្ហាញឱ្យឃើញនូវការកំណត់គោលដៅថ្មីមួយ ក្នុងការប៉ុនប៉ងប្រែក្លាយបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឱ្យទៅជាការជំនុំជម្រះថ្មីសន្លាងមួយទៀត***

28. នួន ជា ទំនងជាសង្ឃឹមថា គាត់អាចប្រែក្លាយបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឱ្យទៅជាការជំនុំជម្រះថ្មីសន្លាងមួយ ដែលនៅពេលនោះគាត់នឹងមានឱកាសជាលើកទីពីរ ដើម្បីបន្ទុចបង្អាក់សវនាការ ដែលគាត់យល់ឃើញថា ជាវិធីសាស្ត្រការពារក្តីត្រឹមត្រូវរបស់គាត់ ដោយបង្វែងការយកចិត្តទុកដាក់ពីប្រតិចារឹកប្រហែល ២៥.០០០ ទំព័រ និងឯកសាររាប់ពាន់ទំព័រដែលមានក្នុងកំណត់ហេតុនៃសំណុំរឿង ០០២/០១ រួចជាស្រេច ដែលឯកសារទាំងអស់នោះ ជាភ័ស្តុតាងបញ្ជាក់អំពីពិរុទ្ធភាព

---

[55] ឯកសារ **F2/8.1.25** Jon James Alexiou, ‘គោលនយោបាយបរទេសរបស់សាធារណរដ្ឋប្រជាមានិតចិនចំពោះសាធារណរដ្ឋសង្គមនិយមវៀតណាម, 1975-1979’ 1982 (សម្រង់អត្ថបទអត្ថបទ), ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ កថាខណ្ឌ ៩២។

[56] ឯកសារ **F2/8** សំណើលើកទី ៦ សុំដាក់ភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ២៥។

[57] ឯកសារ **F2/8.1.24** Nayan Chanda, ‘កាលវិភាគសម្រាប់ការចូលគ្រប់គ្រងមួយ នៃទស្សនាវដ្តី Far Eastern Economic Review, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៧៩, ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ៣៤។

របស់គាត់។ សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែមរបស់គាត់ គឺជាការឈានមួយជំហានទៅមុខទៀត ដើម្បីសម្រេចគោលដៅនោះ។ ភាគច្រើននៃសំណើសុំឱ្យទទួលយកភស្តុតាងបន្ថែមរបស់ នួន ជា គឺគ្មានអ្វីក្រៅពីការប៉ុនប៉ងឱ្យទទួលយកភស្តុតាង ដែលធ្វើឱ្យចុះខ្សោយភាពរឹងមាំរបស់ភស្តុតាង និងអង្គហេតុដែលជាកម្មវត្ថុក្នុងសាលក្រមនៃសំណុំរឿង ០០២/០១ តែប៉ុណ្ណោះ។

29. នួន ជា បានស្វះស្វែងបង្ហាញភស្តុតាងលើបណ្តឹងសាទុក្ខ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ នេះរួចមកហើយ។ ឧទាហរណ៍ ភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុដែលថា រស់ ញឹម ត្រូវបានចាប់ខ្លួន និងសម្លាប់ក្នុងឆ្នាំ ១៩៧៨ ឬថា កងកម្លាំងភូមិភាគនិរតី ត្រូវបានប្រើដើម្បីបោសសម្អាតក្រុមនៅភូមិភាគពាយ័ព្យ។ ប៉ុន្តែ សហព្រះរាជអាជ្ញាបានគូសបញ្ជាក់រួចមកហើយថា "ពុំមានចំនួនព័ត៌មានបន្ថែមនៅលើប្រធានបទណាមួយនៃប្រធានបទពាក់ព័ន្ធទាំងនេះ អាចនឹងធ្វើឱ្យមានការផ្លាស់ប្តូរចំពោះសាលក្រមឡើយ"[58]។ នួន ជា មិនត្រឹមតែស្នើសុំឱ្យទទួលយកភស្តុតាងថ្មីលើបណ្តឹងសាទុក្ខ ដោយសំអាងថា វាពាក់ព័ន្ធគ្នាដោយផ្ទាល់ទៅនឹងសាលក្រមសំណុំរឿង ០០២/០១ ប៉ុណ្ណោះទេ ប៉ុន្តែ គាត់អះអាងថា ភស្តុតាងនោះជាប់ពាក់ព័ន្ធគ្នាទៅនឹងភស្តុតាងថ្មីដទៃទៀត ដែលត្រូវបានទទួលយករួចហើយ ឬដែលគាត់កំពុងស្វះស្វែងស្នើសុំឱ្យទទួលយក[59]។ សហព្រះរាជាអាជ្ញាបានគូសបញ្ជាក់ថា "ការណ៍នេះគឺបានដើរដល់កំណាត់ផ្លូវមួយវែងឆ្ងាយហួសពីបទដ្ឋានតឹងរឹងកម្រិតខ្ពស់ សម្រាប់ភស្តុតាងថ្មីលើបណ្តឹងសាទុក្ខ ដែលអង្គជំនុំជម្រះនេះបានដាក់ត្រឹមត្រូវហើយ"[60]។ ទន្ទឹមនឹងនេះ នៅពេលអង្គជំនុំជម្រះនេះបានអនុញ្ញាតតាមសំណើរបស់ នួន ជា ដើម្បីស្តាប់សាក្សីបន្ថែមលើបណ្តឹងសាទុក្ខ នួន ជា បែរជា

---

[58] ឯកសារ **F2/7/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើលើកទី ៥ របស់ នួន ជា សុំឱ្យពិចារណា និង ទទួលយកភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥ កថាខណ្ឌ ១០។

[59] ឯកសារ **F2/7/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើលើកទី ៥ របស់ នួន ជា សុំឱ្យពិចារណា និង ទទួលយកភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥ កថាខណ្ឌ ១១។

[60] ឯកសារ **F2/7/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើលើកទី ៥ របស់ នួន ជា សុំឱ្យពិចារណា និង ទទួលយកភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥ កថាខណ្ឌ ១១។

ធ្វើឲ្យខូចឱកាស ដោយស្នើសុំឲ្យមានការស៊ើបសង្កេតវែងអន្លាយបន្ថែមពាក់ព័ន្ធនឹងសាក្សីម្នាក់ ដែលបានមកធ្វើសក្ខីកម្មរួចហើយទៅវិញ[61]។

30. នៅក្នុងសំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម នួន ជា លែងអះអាងថា ភ័ស្តុតាងអ្វីមួយដែលគាត់ស្នើឲ្យទទួលយកនោះ មានភាពជាប់ពាក់ព័ន្ធ ឬមានទម្ងន់គ្រប់គ្រាន់ក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរសាលក្រមក្នុងសំណុំរឿង ០០២/០១ នោះទៀតហើយ។ ផ្ទុយទៅវិញ គាត់ប្តូរមកអះអាងថា "ភ័ស្តុតាងបន្ថែមទាំងនេះ រួមគ្នាអាចជាមូលដ្ឋានក្នុងការសម្រេចមួយនៅក្នុងផ្នែកសំខាន់នៃសំអាងហេតុក្នុងសាលក្រម..."[62]។ ដូច្នេះ នួន ជា នឹងនៅតែមិនសំចៃក្នុងសារណារបស់ខ្លួន ក្នុងការប៉ុនប៉ងអនុវត្តតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងប្រភេទនៃភ័ស្តុតាងថ្មី ដែលមានលក្ខណៈចង្អៀតក្នុងការអនុញ្ញាតឲ្យទទួលយកលើបណ្តឹងសាទុក្ខ។

31. លើសពីនេះទៅទៀត នួន ជា អះអាងនៅក្នុងសំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែមថា លក្ខខណ្ឌកំណត់សម្រាប់ទទួលយកភ័ស្តុតាងនៅ អ.វ.ត.ក ដែលមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងមិនគួរយកមកអនុវត្តបានក្នុងពេលឥឡូវ ខណៈដែលគាត់កំពុងស្នើសុំបង្ហាញភ័ស្តុតាងថ្មីលើបណ្តឹងសាទុក្ខនោះទេ។ នួន ជា លើកឡើងថា ទោះបីអង្គជំនុំជម្រះនេះរកឃើញថា ភ័ស្តុតាងនោះមិនអាចទទួលយកបានតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងយ៉ាងណាក៏ដោយ "ក៏អង្គជំនុំជម្រះនៅតែអាចទទួលយកភ័ស្តុតាងនោះតាមវិធាន ១០៤(១) ដើម្បីជាប្រយោជន៍យុត្តិធម៌"[63]បានផងដែរ។ ទោះបីអង្គជំនុំជម្រះរកឃើញថា វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យអង្គជំនុំជម្រះទទួលយកភ័ស្តុតាងដែលមិនបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងយ៉ាងណាក្តី ក៏អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមានការលើកលែងចំពោះបទដ្ឋានអប្បបរមា សម្រាប់ការទទួលយក

[61] ឯកសារ **F28** សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរទៅលើព្រឹត្តិការណ៍នានា ដែលពិពណ៌នានៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ សំ សិទ្ធី ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥។

[62] ឯកសារ **F2/8** សំណើលើកទី ៦ សុំដាក់ភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១១៥។

[63] ឯកសារ **F2/8** សំណើលើកទី ៦ សុំដាក់ភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១៥៧។

ភ័ស្តុតាង ដូចដែលមានចែងក្នុងវិធាន ៨៧(៣) នោះដែរ ហើយអង្គជំនុំជម្រះនេះបានទទួលស្គាល់ដូច្នេះរួចមកហើយ[64]។

### *ឃ. សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែមរបស់ នួន ជា គឺជាការប៉ុនប៉ងដែលច្បាប់មិនអនុញ្ញាត ដើម្បីគាំទ្របន្ថែមទៅលើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់គាត់*

32. សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ធ្វើហួសពីការគ្រាន់តែដាក់សំណើសុំឲ្យទទួលស្គាល់ភ័ស្តុតាងថ្មី។ បន្ថែមលើប្រវត្តិសាស្ត្របែបរវើរវាយដែលមានរៀបរាប់រួចហើយ សំណើនោះមានរួមបញ្ចូលសារណាស្តីពីទស្សនៈរបស់ នួន ជា ចំពោះបន្ទុកភ័ស្តុតាង[65] ការនិយាយច្រំដែលមិនឈប់ឈរពាក់ព័ន្ធនឹង "ភាពចម្រូងចម្រាស់ និង ការឃុបឃិតគ្នាពាក់ព័ន្ធនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តី[66] ទស្សនៈស្តីពីទំនាក់ទំនងកម្ពុជាជាមួយនឹងវៀតណាម រយៈពេលជាង ១.០០០ ឆ្នាំកន្លងមក[67] និងការពិភាក្សាអំពីការឈ្លានពានរបស់រុស្ស៊ីទៅលើប្រទេស អ៊ុយក្រែន នៅឆ្នាំ ២០១៤[68]។

33. នួន ជា បានស្នើសុំ[69] និងអង្គជំនុំជម្រះបានអនុញ្ញាតតាមសំណើ[70] ដែលសុំអនុញ្ញាតបន្ថែម ៣០ ទំព័រទៀត ដើម្បីសរសេរសំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែមនោះ។ ក្នុងការដាក់សំណើនេះ នួន ជា បានធានាអះអាងនៅចំពោះអង្គជំនុំជម្រះថា "មេធាវីការពារក្តីបានព្យាយាមសង្ខេបក្នុងពេលធ្វើពង្រាងសំណើ" និង "រហូតមកដល់ពេលនេះ គ្រាន់តែការសង្ខេបផ្នែកដែលពាក់ព័ន្ធបំផុតសម្រាប់

---

[64] ឯកសារ F2/4/3 សេចក្តីសម្រេចបណ្តោះអាសន្នលើផ្នែកខ្លះនៃសំណើលើកទីមួយរបស់ នួន ជា សុំឲ្យទទួលយក និង ពិចារណាទៅលើភ័ស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ត្រង់កថាខណ្ឌ ១៦។

[65] ឯកសារ F2/8 សំណើលើកទី ៦ សុំដាក់ភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១៨។

[66] ឯកសារ F2/8 សំណើលើកទី ៦ សុំដាក់ភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ២១។

[67] ឯកសារ F2/8 សំណើលើកទី ៦ សុំដាក់ភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ២៦។

[68] ឯកសារ F2/8 សំណើលើកទី ៦ សុំដាក់ភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៥៧។

[69] ឯកសារ F27 សំណើបន្ទាន់របស់ នួន ជា ស្នើសុំចំនួនទំព័របន្ថែមសម្រាប់សំណើលើកទី ៦ របស់ខ្លួនសុំឲ្យទទួលយកភ័ស្តុតាងបន្ថែមសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥។

[70] ឯកសារ F27/1 សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំចំនួនទំព័របន្ថែមសម្រាប់សំណើលើកទី ៦ ស្នើសុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥។

ឯកសារមួយចំនួនប៉ុណ្ណោះ ខ្លួនបានប្រើអស់ ២៥ ទំព័រទៅហើយ។ នៅមានកំណត់ហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារិកសម្រាប់សាក្សីចំនួនប្រាំទៀត មិនទាន់ត្រូវបានសង្ខេបនៅឡើយ”[71]។ សហព្រះរាអាជ្ញាកត់សម្គាល់ថា នៅក្នុងសំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែមនោះ មានមិនលើពី ២០ ទំព័រនោះផង ដែលប្រើសម្រាប់សេចក្តីសង្ខេបនៃឯកសារទាំងអស់ ដែលបានស្នើសុំឱ្យទទួលយក[72] ។ បើតាមចំនួនទំព័រដែលកំណត់ជាទូទៅ ចំនួននេះគឺនៅសល់ ១០ ទំព័រទុកសម្រាប់ “សេចក្តីផ្តើមនៃសវតារនីតិវិធី ការពិភាក្សាអង្គច្បាប់ និងសារណា”[73]។ ស្ទើរតែទាំងអស់នៃទំព័របន្ថែមដែលអង្គជំនុំជម្រះអនុញ្ញាត នួន ជា យកមកប្រើគ្រាន់តែដើម្បីបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមបែបបំភាន់ការពិតតែប៉ុណ្ណោះ។ ទំព័រដែលសល់ពីនោះ នួន ជា ប្រើដើម្បីគាំទ្រ និង បន្ថែមទឡ្ហីករណ៍លើបណ្តឹងឧទ្ធរណ៍របស់គាត់។

34. ដូចអ្វីដែលសហព្រះរាអាជ្ញាបានគូសបញ្ជាក់ និងគិតទុកជាមុនរួចហើយ នៅក្នុងចម្លើយតបទៅនឹងសំណើរបស់ នួន ជា សុំបន្ថែមទំព័រ៖

> ផ្អែកលើសំណើសុំដាក់ភស្តុតាងបន្ថែមចំនួនប្រាំ កាលពីលើកមុន គេអាចព្យាករណ៍បានថា នួន ជា នឹងប្រើសារណាវែងនៅក្នុងសំណើសុំដាក់ភស្តុតាងបន្ថែមលើកទី ៦ ដើម្បីអះអាងថាតើភស្តុតាងបន្ថែមគាំទ្រដល់គោលជំហររបស់គាត់ក្នុងបណ្តឹងសាទុក្ខឬយ៉ាងណា...។ ដោយសារតែមានផ្នែកសំខាន់នៃការដាក់ជូនភស្តុតាងបន្ថែមនីមួយៗទាំងនេះ ត្រូវបានទុកជាពិសេសសម្រាប់អំណះអំណាងបន្ថែមលើបណ្តឹងសាទុក្ខ គឺអាចនឹងមានប្រយោជន៍ក្នុងការដែលសុំបន្ថែមនៅក្នុងបរិបទនៃបណ្តឹងសាទុក្ខទាំងមូល[74]។

---

[71] ឯកសារ **F27** សំណើបន្ទាន់របស់ នួន ជា ស្នើសុំចំនួនទំព័របន្ថែមសម្រាប់សំណើលើកទី ៦ របស់ខ្លួនសុំឱ្យទទួលយកភស្តុតាងបន្ថែមសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ កថាខណ្ឌ ៧។

[72] *សូមមើល* ឯកសារ **F2/8** សំណើលើកទី ៦ សុំដាក់ភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧០-១៤៨។

[73] ឯកសារ **F27** សំណើបន្ទាន់របស់ នួន ជា ស្នើសុំចំនួនទំព័របន្ថែមសម្រាប់សំណើលើកទី ៦ របស់ខ្លួនសុំឱ្យទទួលយកភស្តុតាងបន្ថែមសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ កថាខណ្ឌ ៧។

[74] ឯកសារ **F27/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើ F27 របស់ នួន ជា សុំបន្ថែមចំនួនទំព័រកំណត់ ចុះថ្ងៃទី ១៧ សីហា ឆ្នាំ ២០១៥ កថាខណ្ឌ ៣។

សហព្រះរាជអាជ្ញា នៅពេលនោះកត់សម្គាល់ឃើញថា ដោយរួមទាំង ៦០ ទំព័រនៅក្នុងសំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម នៅពេលនោះ នួន ជា បានដាក់សារណាប្រហែល ១៣៥ ទំព័រ ពាក់ព័ន្ធនឹងសំណើសុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ដែលក្នុងនោះមួយភាគធំ គឺគ្រាន់តែជាទឡ្ហីករណ៍បន្ថែមដើម្បីគាំទ្របណ្តឹងសាទុក្ខតែប៉ុណ្ណោះ[75]។

35. បន្ទាប់ពីដាក់សំណើនោះរួច នួន ជា បានដាក់សំណើសុំស៊ើបអង្កេតសាក្សី សំ សិទ្ធី ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនេះរួចមកហើយ ទៅតាមការស្នើសុំរបស់ នួន ជា[76]។ ឯកសារដែលដាក់នោះមានសរសេរ ១៦ ទំព័របន្ថែម ដើម្បីប៉ុនប៉ងរៀបរាប់ក្នុងបណ្តឹងសាទុក្ខអំពីភ័ស្តុតាងអវិជ្ជមានរបស់ សំ សិទ្ធី ដោយបន្លំថាជាសំណើរបស់អ្នកស៊ើបអង្កេត។ ដូច្នេះ បើគ្រាន់តែតាមរយៈការដាក់សំណើទាំងអស់នេះតែមួយមុខ ដែលនេះមិនទាន់រាប់បញ្ចូលសំណើទាំងអស់ដែល នួន ជា បានដាក់ ពាក់ព័ន្ធនឹងភ័ស្តុតាងថ្មីលើបណ្តឹងសាទុក្ខ គាត់បានដាក់ទឡ្ហីករណ៍ដែលមានកម្រាស់ ១៥០ ទំព័រ ចាប់តាំងពីគាត់ដាក់សារណាបណ្តឹងសាទុក្ខរបស់គាត់រួចមក។ ចំនួនទំព័រនេះ គឺលើសពី ៧០ ភាគរយនៃចំនួន ២១០ ទំព័រ ដែលអង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា ដាក់ឯកសារ សម្រាប់ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាំងមូលរបស់គាត់។ ចំនួនទំព័រនេះ គឺលើសពី ៥០ ភាគរយ នៃចំនួន ២៧០ ទំព័រដែលកំណត់ឲ្យ នួន ជា សម្រាប់សរសេរសារណាបណ្តឹងសាទុក្ខទាំងមូល នៅក្រោយពេលអង្គជំនុំជម្រះអនុញ្ញាតតាមសំណើសុំទំព័របន្ថែមរបស់គាត់។ ការអនុញ្ញាតឲ្យ នួន ជា ធ្វើដូច្នេះបាន គឺជាការធ្វើឲ្យប៉ះពាល់ដល់ភាពស្មើគ្នារវាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី ពាក់ព័ន្ធនឹងទឡ្ហីករណ៍បណ្តឹងសាទុក្ខ ដែលការណ៍នេះ មិនត្រឹមតែអនុញ្ញាតឲ្យ នួន ជា បន្ថែម និងគាំទ្រទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់គាត់ និងដាក់ឯកសារយឺតពេលកំណត់ និងច្រើនលើសទំព័រដែលអនុញ្ញាតប៉ុណ្ណោះទេ ប៉ុន្តែការធ្វើតាមព្រឹត្តិហេតុដូច្នេះ គឺធ្វើឲ្យការឆ្លើយតបទៅកាន់ចម្លើយតបរបស់សហព្រះរាជអាជ្ញា ខ្វះលក្ខណៈស្របច្បាប់។

36. ទោះជាយ៉ាងនេះក្តី ទោះបីជាមានទឡ្ហីករណ៍បន្ថែមលើបណ្តឹងសាទុក្ខយ៉ាងវែងអន្លាយនៅក្នុងសំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែមក៏ដោយ ក៏ទឡ្ហីករណ៍បន្ថែមលើបណ្តឹងសាទុក្ខជាច្រើន នៅ

---

[75] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើ F27 របស់ នួន ជា សុំបន្ថែមចំនួនទំព័រកំណត់ ចុះថ្ងៃទី ១៧ សីហា ឆ្នាំ ២០១៥ កថាខណ្ឌ ៤។

[76] ឯកសារ **F28** សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរទៅលើព្រឹត្តិការណ៍នានា ដែលពិពណ៌នានៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ សំ សិទ្ធី ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥។

ក្នុងសំណើសុំឲ្យទទួលស្គាល់ភ័ស្តុតាងបន្ថែមកាលពីមុន និងឯកសារផ្សេងៗទៀតដែល នួន ជា បានដាក់ និងបន្ទាប់ពីពេលវេលាជាង ១ ឆ្នាំ បានកន្លងផុតទៅចាប់តាំងពីសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងបានចេញរួចមក និងបន្ទាប់ពីពេលវេលាស្ទើរតែ ១០ ខែ បានកន្លងផុតទៅចាប់តាំងពី នួន ជា បានដាក់សារណាបណ្តឹងសាទុក្ខដែលមានកម្រាស់ ២៧០ ទំព័រ នួន ជា នៅតែមិនទាន់បានបង្ហាញឲ្យឃើញច្បាស់ ឬជាក់ស្តែងនូវទំនាក់ទំនងរវាងទ្រឹស្តីការពារក្តីរបស់គាត់ ដែលគាត់ស្វះស្វែងចង់បាន និងការរកឃើញថា គាត់មានពិរុទ្ធនៅក្នុងសំណុំរឿង ០០២/០១ នៅឡើយទេ។ សហព្រះរាជអាជ្ញាយល់ស្របតាមទស្សនៈរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលសម្រេចនៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៥ ថា សូម្បីតែ នួន ជា បានដាក់ឯកសារទាំងអស់នោះរួចហើយក្តី ក៏ នួន ជា នៅតែមិនទាន់បាន៖

> លើកឡើងជាក់លាក់អំពីការបញ្ចូលនូវជម្លោះដែលកើតមាននៅក្នុងបក្សកុម្មុនីស្តកម្ពុជា និងសកម្មភាពនានា ក្នុងការផ្តួលរំលំការដឹកនាំរបស់ ប៉ុល ពត និង នួន ជា នៃបក្សកុម្មុនីស្តកម្ពុជា លើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់គាត់ឡើយ ដូចជាលើបញ្ហាថាតើបានធ្វើឲ្យប៉ះពាល់លើសំអាងហេតុណាខ្លះរបស់អង្គជំនុំជម្រះសាលាដំបូង និង មូលហេតុអ្វីខ្លះប្រសិនបើសំអាងហេតុនេះ ត្រូវបានបដិសេធចោលនៅលើបណ្តឹងសាទុក្ខ ហើយថាតើអាចមានមោឃៈពិរុទ្ធភាពរបស់ នួន ជា ទាំងមូល ឬផ្នែកខ្លះ ដែរឬយ៉ាងណា ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មជាក់លាក់ និងទម្រង់នៃការទទួលខុសត្រូវ[77]។

37. ដោយសារ នួន ជា មានឱកាសជាច្រើនរួចហើយ ក្នុងការដែលត្រូវបំពេញទៅតាមលក្ខខណ្ឌនៃបន្ទុកភ័ស្តុតាងរបស់គាត់ពាក់ព័ន្ធនឹងបញ្ហានេះ បើតាមទស្សនៈរបស់សហព្រះរាជអាជ្ញា ចាប់ពីអំណេះតទៅ អង្គជំនុំជម្រះគួរឈប់ពិចារណា លើរាល់សំណើសុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ដែល នួន ជា បានដាក់រហូតមកដល់ពេលនេះ (រួមទាំងសំណើទៅថ្ងៃខាងមុខ ដែលមានបំណងដដែលនេះផងដែរ)។ ទោះជាយ៉ាងនេះក្តី ទោះបីជា នួន ជា មានលទ្ធភាពអាចកែតម្រូវបរាជ័យរបស់គាត់បានក៏ដោយ ក៏ទ្រឹស្តីការពារក្តីរបស់គាត់ នៅតែបរាជ័យផ្នែកអង្គសេចក្តីដដែល។

### *ង. ការទទួលយកភ័ស្តុតាងមួយចំនួនទៅតាមការចង់បាន នៅលើបណ្តឹងសាទុក្ខ នាំឲ្យប៉ះពាល់ដល់ទិដ្ឋភាពនៃភាពប្រាកដនិយម*

---

[77] ឯកសារ **F2/4/3/3/6** សេចក្តីសម្រេចស្នើឲ្យដាក់សារណា ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៥ ត្រង់កថាខណ្ឌ ៣។

38. សហព្រះរាអាជ្ញា បង្ខំចិត្តត្រូវគូសបញ្ជាក់សាជាថ្មីនូវចំណុចមួយដែលខ្លួនធ្លាប់បានធ្វើម្តងរួចមកហើយ[78] គឺថា ការទទួលយកភ័ស្តុតាងថ្មីទៅតាមការចង់បានរបស់ភាគីមួយ ដោយសារតែពាក់ព័ន្ធនឹងបញ្ហាបណ្តឹងសាទុក្ខ ពិតជាមិនបានជាប្រយោជន៍យុត្តិធម៌ ឬអាចនាំទៅរកការពិតឃើញនោះទេ ដ្បិតភ័ស្តុតាងថ្មីនោះ បើត្រូវទទួលយកដោយសារតែមូលហេតុដូច្នេះ គឺនឹងនាំឲ្យមានយុត្តិសាស្ត្រមិនល្អមួយដែលប៉ះពាល់ដល់ទិដ្ឋភាពនៃភាពប្រាកដនិយម។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ដើម្បីប្រយោជន៍យុត្តិធម៌ ខ្លួនត្រូវចាប់ផ្តើមដំណើរការនៃការរកឃើញផ្នែកអង្គហេតុជាថ្មី ភាគីទាំងអស់គួរត្រូវបានអនុញ្ញាតឲ្យដាក់ភ័ស្តុតាងបន្ថែម ដែលពាក់ព័ន្ធនឹងបញ្ហានេះ។

39. នៅក្នុងសំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ការបំភាន់ការពិតមានកម្រិតខ្ពស់ ដ្បិតដូចមានបង្ហាញជូនខាងក្រោម នួន ជា មិនត្រឹមតែស្នើសុំឲ្យទទួលយកភ័ស្តុតាងទៅតាមការចង់បានរបស់ខ្លួន ពាក់ព័ន្ធនឹងអង្គហេតុមួយចំនួន និងបញ្ហាខ្លះនៅក្នុងសំណុំរឿង ០០២/០១ ប៉ុណ្ណោះទេ គាត់ថែមទាំងបានស្នើសុំឲ្យអង្គជំនុំជម្រះបដិសេធភ័ស្តុតាងជាក់លាក់មួយចំនួន ដើម្បីធ្វើយ៉ាងណាឲ្យអង្គជំនុំជម្រះទទួលយកតែទស្សនៈរបស់គាត់ និងមិនត្រូវពិចារណាទៅលើបរិបទ ឬ ចំណុចមិនស្របគ្នាណាមួយដែលមាននៅក្នុងភ័ស្តុតាងនោះឡើយ។ នៅមានឧទាហរណ៍ជាច្រើនរាប់មិនអស់ទៀត និងដូចអ្វីដែលមានបញ្ជាក់ជូនខាងក្រោម នួន ជា ស្នើសុំឲ្យទទួលយកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រតិចារឹកសវនាការមួយរបស់ ឡុត សួយ ខណៈដែលខ្លួនមិនបានកត់សម្គាល់ ឬជូនដំណឹងដល់អង្គជំនុំជម្រះនេះ ឲ្យចាប់អារម្មណ៍លើប្រតិចារឹករយៈពេលពីរថ្ងៃបន្ថែមទៀត ដែលសាក្សី ឡុត សួយ បានធ្វើសក្ខីកម្ម និងកំណត់ហេតុស្តាប់ចម្លើយសាក្សី ឡុត សួយ ដែលធ្វើដោយការិយាល័យសហចៅក្រមស៊ើបអង្កេតផងដែរនោះទេ[79]។

[78] សូមមើល ឯកសារ F2/7/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើលើកទី ៥ របស់ នួន ជា សុំឲ្យពិចារណា និង ទទួលយកភ័ស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥ កថាខណ្ឌ ២៣។ ឯកសារ F2/6/2 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើក ៤ របស់ នួន ជា ស្នើសុំឲ្យពិចារណា និង ទទួលយកភ័ស្តុតាងបន្ថែម ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ២ និង ១៤។

[79] សូមមើលកិច្ចពិភាក្សាអំពីភ័ស្តុតាងដែលមិនស្មោះត្រង់របស់ ឡុត សួយ ឆ្លើយតបទៅនឹងសំណើរបស់ នួន ជា សុំឲ្យទទួលយកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និង ប្រតិចរឹកសវនាការរបស់ ឡុត សួយ។

40. ប្រសិនបើអង្គជំនុំជម្រះនេះ សម្រេចទទួលយកភស្តុតាងបែបនេះ អង្គជំនុំជម្រះត្រូវតែពិចារណាភស្តុតាងថ្មីក្នុងបរិបទនៃកំណត់ហេតុភស្តុតាងទាំងមូល ដើម្បីចៀសវាងការសម្រេចដោយស្វ័យប្រវត្តិណាមួយ ក្នុងការផ្តល់តម្លៃធ្ងន់ជាងទៅលើសក្ខីកម្មដែលអង្គជំនុំជម្រះបានស្តាប់ ឬបែរជាមើលរម្លងភស្តុតាងលើប្រធានបទដូចគ្នា ដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរួចមកហើយដែរនោះ។ លើសពីនេះទៅទៀត សហព្រះរាជអាជ្ញាសូមលើកឡើងថា ប្រសិនបើអង្គជំនុំជម្រះសម្រេចទទួលយកភស្តុតាងថ្មីណាមួយ ជាគោលការណ៍នៃយុត្តិធម៌ជាមូលដ្ឋាន គឺតម្រូវឱ្យភាគីដទៃទៀតត្រូវតែទទួលបានឱកាសសមស្រប ដើម្បីជំទាស់ភស្តុតាងថ្មីនោះ។ វាពិតជារឿងចម្លែក កាលណាដោយផលប្រយោជន៍ស្វែងរកការពិត អង្គជំនុំជម្រះបែរជាទទួលយកភស្តុតាងថ្មីណាមួយ ដែលស្នើសុំដោយភាគីតែម្ខាង ប៉ុន្តែបែរជាបដិសេធភស្តុតាងបន្ថែមពីភាគីម្ខាងទៀត ដែលមានលក្ខណៈពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការរកឃើញនៃអង្គហេតុដូចគ្នា និងដែលផ្ទុយគ្នាទៅនឹងភស្តុតាងថ្មីរបស់ភាគីម្ខាងទៀត ដែលត្រូវបានទទួលយកដោយអង្គជំនុំជម្រះនោះ។ ដោយសារតែមូលហេតុនេះ តុលាការ ICTY, ICTR និង SCSL សុទ្ធតែបានចែងនៅក្នុងវិធានរបស់ខ្លួនដូចគ្នាថា រាល់ភាគីដែលប៉ះពាល់ដោយការទទួលយកភស្តុតាងថ្មី នៅក្នុងដំណាក់កាលនៃនីតិវិធីបណ្តឹងសាទុក្ខ អាចមានសិទ្ធិជំទាស់ភស្តុតាងនោះបាន[80] និងអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បានសម្រេចអនុវត្តតាមគោលការណ៍នេះ នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ខ្លួនផងដែរ[81]។

### *ច. សំណើលើកទី ៦ របស់ នួន ជា សុំឱ្យទទួលយកភស្តុតាងបន្ថែម ធ្វើឱ្យពន្យារការចេញសាលក្រមស្ថាពរក្នុងសំណុំរឿង ០០២/០១*

41. យើងអាចយល់បានថា នួន ជា បានខិតខំទប់ស្កាត់មិនឱ្យចេញសាលក្រមស្ថាពរក្នុងសំណុំរឿង ០០២/០១ ឱ្យកាន់តែយូរតាមដែលអាចធ្វើបាន។ សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែមនេះ មានចេតនាបំពេញទៅតាមគោលបំណងនោះឯង។ សំណើមុនៗទាំងប៉ុន្មានរបស់គាត់ ដែលសុំឱ្យមានធ្វើកិច្ចស៊ើបអង្កេតបន្ថែម លើភស្តុតាងបន្ថែមដែលអង្គជំនុំជម្រះទទួលយករួចមកហើយនោះ ក៏

---

[80] សាលាក្តី ICTY, ICTR និង SCSL សុទ្ធតែបានផ្តល់ទស្សនៈរបស់ខ្លួនចំពោះវិធាន ១១៥ ថាភាគីដែលរងផលប៉ះពាល់ដោយការទទួលយកភស្តុតាងថ្មីនៅក្នុងដំណាក់កាលនៃនីតិវិធីបណ្តឹងសាទុក្ខនេះ អាចបង្ហាញភស្តុតាងជំទាស់បាន។

[81] *សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងការរកឃើញពិរុទ្ធភាពរបស់គាត់*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤, ICC-01/04-01/06-3121-Red, កថាខណ្ឌ ៦៤។

មានបំណងដូចគ្នានេះដែរ[82]។ ប្រសិនបើអង្គជំនុំជម្រះពិចារណា និងសម្រេចលើសំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែមនេះ នោះបុគ្គលិក និងចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល នឹងត្រូវខាតពេលវេលា និងការងារ ដែលត្រូវយកមកប្រើសម្រាប់ពិភាក្សាសម្រេចលើសាលដីកាស្ថាពរ និងសេចក្តីព្រាងរបស់សាលដីកានេះ។ មិនតែប៉ុណ្ណោះ ប្រសិនបើអង្គជំនុំជម្រះព្រមទទួលយកតាមសំណើណាមួយ ដើម្បីស្តាប់សាក្សីបន្ថែមលើបណ្តឹងសាទុក្ខ សវនាការបែបនេះនឹងធ្វើឱ្យអង្គជំនុំជម្រះចំណាយពេលវេលាដោះស្រាយសំណើនេះ ជាជាងបង្ហើយសាលដីកាស្ថាពររបស់ខ្លួន។

42. ដូចបានបញ្ជាក់ជូនខាងលើ កាលណាភាគីម្ចាស់សំណើ ខកខានក្នុងការបំពេញបន្ទុករបស់ខ្លួន ដើម្បីផ្តល់យុត្តិកម្មទៅលើកការស្នើសុំឱ្យទទួលយកភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ អង្គជំនុំជម្រះនេះមានសិទ្ធិបដិសេធសំណើទាំងនេះភ្លាមៗបាន[83]។ ដោយសារតែ នួន ជា បានខកខានត្រង់ប្រការនេះ ដែលពាក់ព័ន្ធនឹងសំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម និងពាក់ព័ន្ធនឹងសំណើសុំឱ្យទទួលយកភស្តុតាងបន្ថែមដទៃទៀត សហព្រះរាអាជ្ញាសូមស្នើដោយក្តីគោរពថា អង្គជំនុំជម្រះនេះគប្បីបដិសេធរាល់សំណើដែលកំពុងរង់ចាំការសម្រេចទាំងនោះ ដើម្បីកុំឱ្យអង្គជំនុំជម្រះខាតធនធានរបស់ខ្លួនក្នុងដោះស្រាយវា ដែលធនធានទាំងនេះអាចមកប្រើដើម្បីផ្តោតទៅលើការចេញសាលដីកាស្ថាពរនៅក្នុងសំណុំរឿង ០០២/០១។ ដូចអ្វីដែលអង្គជំនុំជម្រះនេះ បានទទួលស្គាល់រួចមកហើយនោះគឺ "កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខត្រូវតែបញ្ចប់ក្នុងថិរវេលាដែលសមរម្យ"[84]។

### *ឆ. នួន ជា មិនត្រឹមតែខកខានក្នុងការបំពេញបន្ទុក ដើម្បីបង្ហាញភស្តុតាងថា ដើម្បីគាំទ្រដល់ការទទួលយកឯកសារណាមួយដែលគាត់បានស្នើសុំលើបណ្តឹងសាទុក្ខប៉ុណ្ណោះទេ គាត់ថែមទាំងខកខានក្នុងការបង្ហាញភស្តុតាងគាំទ្រការដែលត្រូវស្តាប់សក្ខីកម្មសាក្សី ដែលបានស្នើឡើងទាំងនោះ*

[82] ឯកសារ **F28** សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរទៅលើព្រឹត្តិការណ៍នានា ដែលពិពណ៌នានៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ សំ សិទ្ធី ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥។

[83] *រដ្ឋអាជ្ញា ទល់នឹង D. Milosevic*, IT -98-29/1-A, "សេចក្តីសម្រេចលើសំណើលើកទី ៣ របស់ Dragomir Milosevic សុំដាក់ភស្តុតាងបន្ថែម" ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៩ កថាខណ្ឌ ១១។

[84] ឯកសារ **F2/4/3** សេចក្តីសម្រេចបណ្តោះអាសន្នលើផ្នែកខ្លះនៃសំណើលើកទី ១ របស់ នួន ជា សុំឱ្យទទួលយក និង ពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ត្រង់កថាខណ្ឌ ១៨។ *សូមមើលផងដែរ* វិធាន ១០៨(៤) នៃវិធានផ្ទៃក្នុង។

43. នៅក្នុងសំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែមនោះ នួន ជា ស្នើសុំឲ្យទទួលយកឯកសារចំនួន ២២ ដើម្បីធ្វើជាភស្តុតាងថ្មី និងសុំឲ្យអង្គជំនុំជម្រះកោះហៅសាក្សី ០២ នាក់ ឲ្យមកផ្តល់សក្ខីកម្ម។ គាត់ស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីលេខ ៥[85] និង ប្រតិចារឹកសវនាការចំនួន ០២ របស់សាក្សី កែវ លឿ ក្នុងសំណុំរឿង ០០២/០២, ប្រតិចារឹកសវនាការចំនួន ០២ របស់សាក្សី សែម ហឿន ក្នុងសំណុំរឿង ០០២/០២, ប្រតិចារឹកសវនាការចំនួន ០១ របស់សាក្សី ឡូត ស្វយ ក្នុងសំណុំរឿង ០០២/០២, សក្ខីកម្មនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមួយច្បាប់សម្រាប់សាក្សីលេខ ៦, ៧, ឡូត ស្វយ និង សាក្សី 2-TCW-918, ប្រវត្តិរូបចំនួន ០៤ ដែលត្រូវបានអះអាងថាបានមកពីបណ្ណាសារដ្ឋាននៃផ្នែកសន្តិសុខជាតិ របស់សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ និងឯកសារទំនងទំនងការទូតចំនួន ០៨ របស់រដ្ឋាភិបាលសហរដ្ឋអាមេរិក (មានចំណងជើងថា សារទូរលេខ ១-៨)។ សហព្រះរាជអាជ្ញានឹងឆ្លើយតបទៅនឹងឯកសារទាំងអស់នេះមួយម្តងៗ និងដាក់ស្នើសាក្សីមួយចំនួនដូចខាងក្រោម។ ប៉ុន្តែ ជាដំបូងនេះ សហព្រះរាជអាជ្ញានឹងធ្វើសេចក្តីសង្កេតបែបទូទៅ និងជាក់ស្តែងខ្លះសិន។

44. ដូចអ្វីដែលនឹងមានបញ្ជាក់ជូនខាងក្រោម សំណើរបស់ នួន ជា ពាក់ព័ន្ធនឹងឯកសារនីមួយៗ គឺសុទ្ធតែមិនបានបង្ហាញឲ្យបានត្រឹមត្រូវចំខ្លឹមសារនៃឯកសារ និងពោរពេញទៅដោយការស្មាន។ លើសពីនេះទៅទៀត គាត់តែងតែស្នើសុំឲ្យអង្គជំនុំជម្រះកុំពិចារណាភស្តុតាងបន្ថែមណាផ្សេងទៀត ដែលមានលក្ខណៈពាក់ព័ន្ធ និងផ្ទុយពីភស្តុតាងដែលគាត់បានស្នើសុំ ដែលផ្តល់ដោយសាក្សីដដែល ទោះបីជាគាត់ស្នើឲ្យអង្គជំនុំជម្រះទទួលស្គាល់ប្រតិចារឹក និងចម្លើយរបស់សាក្សីទាំងនោះក៏ដោយ។

45. គ្មានឯកសារណាមួយរបស់គាត់ បំពេញទៅតាមបទដ្ឋានសម្រាប់ការទទួលយកភស្តុតាងថ្មីលើបណ្តឹងសាទុក្ខនោះទេ ឯកសារទាំងនោះមិនបានបង្ហាញភស្តុតាងថាជា "កត្តាកំណត់មួយ" ដើម្បីចេញសាលក្រមនោះទេ។ ម្យ៉ាងទៀត វាគ្មានផ្តល់ប្រយោជន៍យុត្តិធម៌អ្វីក្នុងការទទួលយកឯកសារទាំងនោះក្នុងតំណាក់កាលនេះទេ។ តាមពិត ភស្តុតាងនេះ គ្មានទំនាក់ទំនងអ្វីទៅនឹងព្រឹត្តិការណ៍ ដែលបានរៀបរាប់នៅក្នុងសាលក្រមក្នុងសំណុំរឿង ០០២/០១។ ម្យ៉ាងទៀត វាជាឯកសារដែលផ្អែកលើតែការ

---

[85] ដើម្បីបញ្ជាក់ឲ្យបានច្បាស់ សហព្រះរាជអាជ្ញាប្រើរហ័សនាមដែល នួន ជា ប្រើក្នុងសំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម។

ស្ថានតែប៉ុណ្ណោះ។ យោងតាមយុត្តាធិការពេលវេលា គ្មានឯកសារណាមួយដែល នួន ជា បាន ស្នើសុំនោះ ពាក់ព័ន្ធទៅនឹងអំឡុងពេលនៃការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ឬការផ្លាស់ទីលំនៅដោយបង្ខំ ដែលជាបទឧក្រិដ្ឋ នួន ជា ត្រូវបានរកឃើញថាមានពិរុទ្ធនៅក្នុងសំណុំរឿង ០០២/០១ នោះទេ។ ដូច្នេះ គ្មានភស្តុតាងរបស់គាត់ណាមួយ អាចជាកត្តាកំណត់ដើម្បីឈានទៅសម្រេចសាលក្រមទេ។ នួន ជា មិនបានចង្អុលបង្ហាញទៅរកភស្តុតាងណាមួយ ពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ។ គាត់មិនបានបង្ហាញអំពីភស្តុតាងដោះបន្ទុកណាមួយ ពាក់ព័ន្ធនឹងគោលនយោបាយ ដែលយកអតីតមន្ត្រី និងទាហាន លន់ នល់ ជាគោលដៅ ឬការផ្លាស់ទីលំនៅដោយបង្ខំនោះទេ។ ទន្ទឹមនឹងនេះ គ្មានភស្តុតាងណាមួយជំទាស់ទៅនឹងការរកឃើញដែលថា វចនាសម្ព័ន្ធអំណាចតាមឋានានុក្រមពិតជាមានប្រាកដ នៅក្នុងអំឡុងពេលដែលកើតព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ដែលជាបទឧក្រិដ្ឋ នួន ជា និង ខៀវ សំផន ត្រូវបានអង្គជំនុំជម្រះរកឃើញថាមានពិរុទ្ធ នៅក្នុងសំណុំរឿង ០០២/០១។

46. នួន ជា មិនបានប៉ុនប៉ងអះអាងថា ឯកសារដែលគាត់ស្នើសុំទាំងអស់ពិតជាអាចបំពេញតាមបទដ្ឋានសម្រាប់ការទទួលយកភស្តុតាងថ្មីលើបណ្តឹងសាទុក្ខ។ ផ្ទុយទៅវិញ ដូចបានបញ្ជាក់ជូនខាងលើ គាត់បែរជាប៉ុនប៉ងអះអាងថា "ឯកសារទាំងនេះរួមបញ្ចូលគ្នា" អាចបង្កើតបានជាកត្តាកំណត់[86] ដោយគាត់យល់ខុសថា ការអះអាងដូច្នេះគឺអាចឲ្យគាត់រួចខ្លួនពីកាតព្វកិច្ចក្នុងបំពេញតាមលក្ខខណ្ឌនៃការបង្ហាញភស្តុតាងណាមួយ។

47. ម្យ៉ាងវិញទៀត ឧបមាថា អង្គជំនុំជម្រះនេះរកឃើញថា នួន ជា បានបង្ហាញភស្តុតាងគ្រប់គ្រាន់ក្នុងបញ្ជាក់អំពីទំនាក់ទំនងគ្នារវាងឯកសារដែលបានស្នើសុំ និងសាលក្រមក្នុងសំណុំរឿង ០០២/០១ ក៏ដោយចុះ ក៏ភស្តុតាងទាំងនោះមិនគ្រប់គ្រាន់ ដែលអាចលុបចោលនូវតម្លៃនៃភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់មាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលបង្ហាញនូវវចនាសម្ព័ន្ធអំណាចតាមឋានានុក្រមរបស់បក្សកុម្មុនិស្តកម្ពុជាបាននោះដែរ។ ពាក់ព័ន្ធនឹងចំណុចនេះផងដែរ សហព្រះរាជអាជ្ញាសូមឲ្យអង្គជំនុំជម្រះពិនិត្យមើលផ្នែកខ្លះនៃចម្លើយតបរបស់ខ្លួន តបនឹងសារណាបណ្តឹងសាទុក្ខរបស់ នួន ជា ដែលបញ្ជាក់អំពីភាពរឹងមាំនៃវចនាសម្ព័ន្ធអំណាចតាមឋានានុក្រមជាទូទៅ និងរវាងភូមិភាគ ពាយ័ព្យ

[86] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១៤។

និងមជ្ឈិម[87]។ តាមពិត សូម្បីសាក្សីមុនៗដែល នួន ជា បានស្នើសុំលើបណ្តឹងសាទុក្ខ និង ដែលអង្គជំនុំជម្រះនេះបានស្តាប់សក្ខីកម្មរួចហើយ ក៏សុទ្ធតែបានបញ្ជាក់ថា រស់ ញឹម បញ្ជូនសារ និងចាប់មនុស្សបញ្ជូនទៅមជ្ឈិមបក្សផងដែរ[88]។

### *i. កំណត់ហេតុស្តាប់ចម្លើយសាក្សី និងសំណើសុំកោះហៅសាក្សីលេខ ៥*

48. សហព្រះរាជអាជ្ញាជំទាស់សំណើរបស់ នួន ជា ដែលសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី[89] ពីសាក្សីលេខ ៥ និងសុំឲ្យកោះហៅគាត់មកផ្តល់សក្ខីកម្ម[90]។

49. កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៥ មិនអាចជាកត្តាកំណត់ក្នុងសាលក្រមបាននោះទេ។ ម្យ៉ាងទៀត ដើម្បីជាប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះមិនត្រូវទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនោះលើបណ្តឹងសាទុក្ខ។ ទីមួយ កំណត់ហេតុស្តាប់ចម្លើយសាក្សីនោះ គ្មានពាក់ព័ន្ធអ្វីទាំងអស់ទៅនឹងការរកឃើញផ្នែកអង្គហេតុ ដែលមាននៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ កំណត់ហេតុនោះគ្មានរៀបរាប់អ្វីបន្តិចពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ ឬការគ្រប់គ្រងដោយប្រសិទ្ធភាពតាមឋានានុក្រមទៅលើភូមិភាគពាយ័ព្យ ឬការផ្លាស់ទីលំនៅដោយបង្ខំ ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១។ លើសពីនេះទៅទៀត ភ័ស្តុតាងដែលបញ្ជាក់អំពីការតស៊ូដ៏ប្តូរផ្តាច់ ដែលរៀបចំឡើងដោយ សោ ភឹម ដើម្បីការពារខ្លួនគាត់នៅចុងឆ្នាំ ១៩៧៨ នោះ គឺមិនអាចធ្វើឲ្យខូចធាតុពិតនៃសំអាងហេតុស្តីពីតួនាទីរបស់ សោ ភឹម ចាប់តាំងពីដើមដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ ឬរបៀបដែលគាត់ខិតខំ និងរាយការណ៍ដោយស្មោះត្រង់ទៅបក្សកុម្មុយនីស្តកម្ពុជា និងធ្វើតាមការណែនាំពីថ្នាក់ដឹកនាំបក្ស[91]នោះទេ។ ភ័ស្តុតាងនោះ រឹត

---

[87] ឯកសារ **F17/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ កថាខណ្ឌ ២៩៣-៣០០, ៥៦៩-៥៧១។

[88] ឯកសារ **F1/3.1** ប្រតិចារិក ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ ត្រង់នាទី 16.11.43។

[89] ឯកសារ **E319/13.3.39** កំណត់ហេតុស្តាប់ចម្លើយសាក្សី [សាក្សីលេខ ៥] ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៣ ("កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៥")។

[90] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧១។

[91] *សូមមើល ឧទាហរណ៍* ឯកសារ **E313** សាលក្រមសាលាដំបូង កថាខណ្ឌ ៧៧៣។ *សូមមើលផងដែរ* កថាខណ្ឌ ៨៧, ៨៩, ១៣៣, ២០៣, ២១៩, ៣០៩, ៧២៦-៧២៧, ៧២៩, ៧៣២-៧៣៣, ៧៣៥, ៧៣៩, ៧៤១, ៧៤៥, ៧៤៩, ៧៦៦, ៧៧៧, ៨០៧-៨០៨, ៨១០។

តែមានផលប៉ះពាល់តិចតួចទៅលើប្រសិទ្ធភាពនៃលក្ខណៈឋានានុក្រមរបស់របបសម្ព័ន្ធខ្មែរក្រហម ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅដោយបង្ខំ និងព្រឹត្តិការណ៍នៅ ទួលពោធិ៍ជ្រៃ នៅក្នុងភូមិភាគពាយ័ព្យ នៅឆ្នាំ ១៩៧៥។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា នៅឆ្នាំ ១៩៧៨ សោ ភឹម ត្រូវបាន "ប្រកាសថាជាខ្មាំងផ្ទៃក្នុងរបស់បក្ស ដែលត្រូវបោសសម្អាត"[92] ដែលការណ៍នេះ រឹតតែបង្ហាញឱ្យឃើញកាន់តែច្បាស់នូវភាពស៊ីសង្វាក់គ្នារបស់កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីទៅនឹងសំអាងហេតុរបស់សាលក្រម ស្តីពីរចនាសម្ព័ន្ធរបស់បក្សកុម្មុនីស្តកម្ពុជា និងតួនាទីរបស់ភូមិភាគ និងការទទួលខុសត្រូវជាលក្ខណៈបុគ្គលរបស់ នួន ជា។

50. ទីពីរ កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីនោះ មិនសមស្រប ដើម្បីបញ្ជាក់អំពីអង្គហេតុដែល នួន ជា ចង់យកមកធ្វើជាសំអាងនោះទេ។ នួន ជា អះអាងថា កំណត់ហេតុស្តាប់ចម្លើយសាក្សីបង្ហាញថា វៀតណាមមានផែនការទម្លាក់របបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការធ្វើរដ្ឋប្រហារ ដែលដឹកនាំដោយ សោ ភឹម[93] និងថា "មានការរៀបចំខ្លះៗអំពីការបះបោរ"[94]។ នេះជាការបំភាន់ស្រស់ៗទៅលើខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី។ កំណត់ហេតុស្តាប់ចម្លើយសាក្សីនោះ ផ្តល់នូវព័ត៌មានអំពីការបះបោរដែលគ្មានឈ្មោះមួយ ដឹកនាំដោយ សោ ភឹម ដែលកើតឡើង "រហ័ស" គឺ កើតឡើងនៅក្រោយពេលកម្លាំងគាត់ "មានការឡោមតាមរយៈយន្តហោះ រថក្រោះ និងថ្មើរជើង" ពីមជ្ឈិម រួចហើយ[95] ហើយថា "សៅ ភឹម គ្រាន់តែប្រមូលកម្លាំងមក ហើយចាប់ផ្តើមតែម្តង"[96]។ ឯកសារនោះផ្តល់នូវភស្តុតាងដែល ប៉ុល ពត ចាត់ទុកភូមិភាគបូព៌ាថាបានចូលដៃជាមួយវៀតណាម ដែលតាមការពិតវាមិនដូច្នេះនោះទេ។ តាមពិត សូម្បីតែនៅក្នុងសម្តីរបស់ នួន ជា ដែលបានដកស្រង់នៅក្នុងសំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម សាក្សីលេខ ៥ បញ្ជាក់ច្បាស់ថា ក្រុមដែលគាត់ចូលរួម គឺដឹកនាំដោយ សោ ភឹម បង្កើតឡើងដោយសារ ប៉ុល ពត "ចាប់ផ្តើមទៅសម្លាប់អ្នកបូព៌ាតែម្តង"

---

[92] ឯកសារ E313 សាលក្រមសាលាដំបូង កថាខណ្ឌ ៣៤០។

[93] ឯកសារ F2/8 សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ២៤-២៥, ៥២-៥៣, ១៥៣។

[94] ឯកសារ F2/8 សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧៣។

[95] ឯកសារ E319/13.3.39 កំណត់ហេតុស្តាប់សម្លើយសាក្សីលេខ ៥ ត្រង់ចម្លើយ ១៥-២៥។

[96] ឯកសារ F2/8 សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧២ ដកស្រង់សម្តីពីក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៥ ត្រង់ចម្លើយ ១៧-១៨។

មិនមែន ប៉ុល ពត បង្កើតឡើងដោយសារ សោ ភឹម នោះទេ[97]។ ដូច្នេះ ចលនានេះគឺបង្កើតឡើង ដើម្បីការពារជីវិតឱ្យរួចពីការសម្លាប់ប៉ុណ្ណោះ មិនមែនដូច នួន ជា អះអាងខុសការពិតប្រាប់អង្គជំនុំជម្រះនេះថា "ជាចលនារុញច្រានមួយពីខាងបូព៌ា ប្រឆាំងនឹងកងកម្លាំងបក្សកុម្មុនីស្តកម្ពុជា" ដែលជាផ្នែកមួយនៃផែនការដែលមានការរៀបចំទុកជាមុននោះទេ[98]។ កំណត់ហេតុស្តាប់ចម្លើយសាក្សីនោះ មិនបាននិយាយអំពីការប៉ុនប៉ងធ្វើ "រដ្ឋប្រហារ" ដូចដែល នួន ជា អះអាងដោយឥតអៀនខ្មាស់នោះទេ[99]។

51. នៅត្រង់ផ្នែកផ្សេងទៀត នួន ជា លើកឡើងដោយប្រយោល ដោយអះអាងថា អាវុធត្រូវបានយកទៅស្តុកទុក ដើម្បីត្រៀមធ្វើចលនាបះបោរ[100]។ បើអានខ្លឹមសារនៃឯកសារនោះ យើងឃើញថា សេចក្តីដកស្រង់នោះសំអាងតែទៅលើការកត់សម្គាល់ដែលថា អាវុធត្រូវបានស្តុកទុកនៅក្នុងឃ្លាំងមួយដោយបក្សកុម្មុនីស្តកម្ពុជា នៅកម្រិតភូមិភាគ[101] ដែលជារបៀបនៃការរៀបចំកម្លាំងយោធាមួយ។ ទន្ទឹមនឹងនេះ នួន ជា យោងទៅ "កម្លាំងក្បត់ ៨.០០០ នាក់នៅភូមិភាគបូព៌ា"[102] ទោះបីគ្មានមូលដ្ឋាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីនោះ សម្រាប់អះអាងបញ្ជាក់ថា ក្រុមនោះជាក្រុមទាហានទាំងអស់ក៏ដោយ[103]។

52. មេធាវីការពារក្តី មិនបានកំណត់សូម្បីតែសំអាងហេតុជាក់លាក់ណាមួយ ក្នុងសាលក្រម ដែលពាក់ព័ន្ធនឹងភស្តុតាងដែលគាត់ស្នើសុំនោះ[104]។ ភាពខ្វះលក្ខណៈជាក់លាក់នេះ មិនអាចប៉ះប៉ូវបាន

[97] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧២ ដកស្រង់សម្តីពីក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៥ ត្រង់ចម្លើយ ១៨។

[98] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៤៨។

[99] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៦៩។

[100] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧៣។

[101] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧២ ដកស្រង់សម្តីពីក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៥ ត្រង់ចម្លើយ ១៩។

[102] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១៥៣។ *សូមមើលផងដែរ* ដូចខាងលើកថាខណ្ឌ ៥៣។

[103] ឯកសារ **E319/13.3.39** កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៥ ត្រង់ចម្លើយ ១៧។

[104] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧១-៧៥។

ដោយផ្អែកមួយនៃសំណើ ដែលអះអាងជាលក្ខណៈទូទៅ ថាបានពិពណ៌នាអំពី "សារៈសំខាន់នៃភ័ស្តុតាងបន្ថែម"[105]។ ការយោងដែលមានលក្ខណៈទូទៅ អំពីភ័ស្តុតាងដើម្បី"គាំទ្រករណីរបស់មេធាវីការពារក្តី" គឺពុំមានលក្ខណៈគ្រប់គ្រាន់ទេ[106]។ ការប៉ុនប៉ងយ៉ាងច្បាស់ក្រឡែត ក្នុងការគេចវេសពីបទដ្ឋានអនុវត្តសម្រាប់ការទទួលយកភ័ស្តុតាងថ្មីលើបណ្តឹងសាទុក្ខបែបនេះ គួរតែអង្គជំនុំជម្រះបដិសេធចោលភ្លាមៗ។

53. ដោយសារតែគ្មានមូលដ្ឋានក្នុងការទទួលយកភ័ស្តុតាងនោះ គ្មានមូលហេតុអ្វីដែលត្រូវកោះហៅសាក្សីលេខ ៥ ដើម្បីមកផ្តល់សក្ខីកម្មលើបណ្តឹងសាទុក្ខនោះទេ។

### *ii. ប្រតិចារឹកក្នុងសំណុំរឿង ២/២ របស់ កែវ លឿ និង សែម ហឿន*

54. សហព្រះរាអាជ្ញាជំទាស់សំណើសុំឱ្យទទួលយកប្រតិចារឹកនៃការធ្វើសក្ខីកម្មផ្ទាល់មាត់របស់សាក្សី កែវ លឿ និង សែម ហឿន ពីសំណុំរឿង ០០២/០២[107]។

55. ប្រតិចារឹកសវនាការនៃសាក្សីទាំងនេះ មិនអាចបំពេញទៅតាមលក្ខខណ្ឌតម្រូវសម្រាប់អនុញ្ញាតឱ្យដាក់ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ លើបណ្តឹងសាទុក្ខបានទេ ដោយសារវាគ្មានផលអ្វីដល់សាលក្រម និងគ្មានបានផលអ្វីដល់ប្រយោជន៍យុត្តិធម៌ឡើយ ប្រសិនបើទទួលយកវា។ ទីមួយ ប្រតិចារឹករបស់សាក្សីទាំងពីរ គ្មានពាក់ព័ន្ធអ្វីទៅនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១។ ភ័ស្តុតាងដ៏តិចតួចបំផុតដែលអះអាងអំពីផែនការរដ្ឋប្រហាររបស់កងវរៈសេនាតូចលេខ ៣១០ ដែលដឹកនាំដោយឈ្មោះ អឿន នៅភូមិភាគឧត្តរនោះ មិនអាចធ្វើឱ្យប៉ះពាល់ដល់តម្លៃនៃសំអាងហេតុនៅក្នុងសាលក្រមសាលាដំបូង ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរបស់បក្សកុម្មុនីស្តកម្ពុជា ឬតួនាទីរបស់ភូមិភាគ ឬ ការទទួលខុសត្រូវជាលក្ខណៈបុគ្គលរបស់ នួន ជា បាននោះឡើយ ហើយវាក៏មិនប៉ះពាល់ដល់សំអាងហេតុដែលថា អឿន បានអនុវត្តគោលនយោបាយរបស់ខ្មែរក្រហមនោះដែរ[108]។

---

[105] ឯកសារ F2/8 សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១៥២-១៥៥។

[106] ឯកសារ F2/8 សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១៥២។

[107] ឯកសារ F2/8 សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧៧,៨៥។

[108] *សូមមើលឧទាហរណ៍* ឯកសារ E313 សាលក្រមសាលាដំបូង កថាខណ្ឌ ៤៧០ លេងជើងទំព័រ ១៣៨២។

56. ប្រតិចារឹកទាំងនោះមានលក្ខណៈច្រំដែល ដូចគ្នាទៅនឹងឯកសារចម្លើយសាក្សីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ដែលមេធាវីការពារក្តីបានទទួលស្គាល់រួចហើយ និងមាននៅក្នុងសំណុំរឿង ០០២/០១[109]។ ហេតុដូច្នេះ ឯកសារទាំងអស់នេះ មានរួចជាស្រេច ដោយអង្គជំនុំជម្រះពិគ្រោះនៅពេលខ្លួនធ្វើសេចក្តីព្រាងសាលក្រម។ នួន ជា អះអាងដោយមានលក្ខណៈបំភាន់ការពិតថា ប្រតិចារឹកនៃសក្ខីកម្មរបស់សាក្សី កែវ លឿ ផ្តល់ "ភ័ស្តុតាងលម្អិតច្រើនជាងនេះ"ស្តីពីផែនការរដ្ឋប្រហារ ដែលលម្អិតដោយកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា[110]។ តាមការពិត ចំណុចសំខាន់នៃសក្ខីកម្មរបស់សាក្សីនោះ ពោលគឺផែនការរដ្ឋប្រហារដែលរងការចោទប្រកាន់នោះ មានការរៀបចំខ្លះ[111] ដោយរួមមានទាំងអាវុធ[112] និង កម្លាំងទ័ព[113] និងសាក្សីនោះត្រូវបានគេឱ្យត្រៀមស្បៀងអាហារ[114] និងគេច្បាស់ថានឹងមានការប្រយុទ្ធគ្នា[115] និងការចាប់មេបញ្ជាការឈ្មោះ អឿន[116] និងថា ចម្លើយសារភាពរបស់ អឿន

---

[109] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧៧, ៨៥។

[110] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧៨។

[111] *សូមប្រៀបធៀប* ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧៩ ["គាត់ និង 'កងពលទាំងមូល' គេឱ្យទៅចូលរួមប្រជុំ [...] ដែល អឿន ប្រាប់ពួកគេថា៖ កងទ័ពស្រួចនឹងត្រូវបញ្ជូនទៅសមរភូមិមុខ"] *និង* ឯកសារ **E3/5658** ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា របស់ឈ្មោះ កែវ លឿ ត្រង់ឯកសារទំព័រ 00863305 ["តាមពិត កម្លាំងត្រូវបានរៀបចំ [...] ខ្ញុំទទួលបញ្ជាឱ្យរៀបចំកម្លាំង [...] គេប្រាប់ឱ្យយើងត្រូវត្រៀមខ្លួន"].

[112] *សូមប្រៀបធៀប* ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧៩ ["ទោះបីគាត់មិនបានឃើញកាំភ្លើងនៅកន្លែងនោះដោយផ្ទាល់ភ្នែកក៏ដោយ គាត់បានឮ អឿន និង "កម្មាភិបាលជាន់ខ្ពស់ដទៃទៀតជជែកគ្នាថាគេដឹកកាំភ្លើងមកហើយ""] *និង* ឯកសារ **E3/5658** ចម្លើយរបស់ កែវ លឿ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ 00863305 ["គេនិយាយថា យើងត្រូវតែត្រៀមកាំភ្លើង"]។

[113] *សូមប្រៀបធៀប* ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ["អឿន ប្រាប់ពួកគេថា 'ទ័ពស្រួចនឹងត្រូវបញ្ជូនទៅសមរភូមិមុខ'"] *និង* ឯកសារ **E3/5658** ចម្លើយរបស់ កែវ លឿ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ 00863305 ["គេនិយាយថា យើងត្រូវតែត្រៀម [...] កម្លាំង"]។

[114] *សូមប្រៀបធៀប* ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧៩, ៨១ ["ចំណែកឯតួនាទីរបស់ ក-៤ ក្នុងផែនការរដ្ឋប្រហារនេះ កែវ លឿ ឆ្លើយថា "យើងជួយវេចខ្ចប់ស្បៀង"] និង ឯកសារ **E3/5658** ចម្លើយរបស់ កែវ លឿ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ 00863305 ["ខ្ញុំរៀបចំបាយទឹក"]។

[115] *សូមប្រៀបធៀប* ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៨២ ["តាមចម្លើយ កែវ លឿ 'មិនមានការបញ្ជាក់ប្រាប់ច្បាស់លាស់ទេ' ថាតើការបះបោរនឹងចាប់ផ្តើមនៅពេលណា"] *និង* ឯកសារ **E3/5658** ចម្លើយរបស់ កែវ

ត្រូវបានចាក់ឲ្យទាហានស្ដាប់ក្នុង"វគ្គរៀនសូត្រ"[117] ទាំងអស់នេះសុទ្ធតែមាននៅក្នុងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួចហើយ។ សម្ភាសន៍របស់ កែវ លឿ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា មិនមែនមានតែ"ព័ត៌មានបន្តិចបន្តួច"[118]នោះទេ គាត់មានភ័ស្តុតាងពាក់ព័ន្ធទាំងអស់ដែល នួន ជា ទើបតែអះអាងឥឡូវនេះ ថាទើបតែមានប្រតិចារឹកនៃសក្ខីកម្មរបស់គាត់។

57. ដូចគ្នានេះដែរ ការចាត់ថ្នាក់ប្រតិចារិករបស់សាក្សី សែម ហឿន ថា"ផ្ដល់ភ័ស្ដុតាងបន្ថែម និង លម្អិត"[119] ជាងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្ដីពីផែនការរដ្ឋប្រហារដែលរងការចោទប្រកាន់ គឺជាការលើកឡើងមិនត្រឹមត្រូវ។ តាមពិត នួន ជា ទទួលស្គាល់ថា នៅពេលធ្វើសក្ខីកម្ម "សែម ហឿន បានបញ្ជាក់អំពីសក្ខីកម្មនៅមជ្ឈមណ្ឌលឯកសារកម្ពុជារបស់គាត់ ពាក់ព័ន្ធនឹងការប៉ុនប៉ងធ្វើរដ្ឋប្រហារនោះ"[120]។ សក្ខីកម្មរបស់សាក្សីនៅមជ្ឈមណ្ឌលឯកសារកម្ពុជា មានចំណុចដូចគ្នាទៅនឹង

---

លឿ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ 00863305 ["គេចាត់ឲ្យខ្ញុំត្រៀមដូច្នេះ ទោះបីមិនដឹងថាការប្រយុទ្ធគ្នានឹងមានឬអត់ក៏ដោយ"]។

[116] *សូមប្រៀបធៀប* ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៨២ ["'ពីរថ្ងៃក្រោយមក អឿន ត្រូវបានចាប់ខ្លួន'"] *និង* ឯកសារ **E3/5658** ចម្លើយរបស់ កែវ លឿ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ 00863288 ["គេនិយាយថាកងពលក្បត់។ ប្រធានកងពល [អឿន] [...] [ត្រូវបានចាប់ខ្លួន"]។

[117] *សូមប្រៀបធៀប* ឯកសារ **F2/8** សំណើលើកទី ៦ សុំសុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៨២ ["ទាហាននៅក្នុងកងពលធំ ត្រូវបានកោះហៅមក 'ប្រជុំរៀនសូត្រ' 'ដែលពេលនោះ គេចាក់ខ្សែអាត់ចម្លើយសារភាពរបស់ [អឿន] ឲ្យស្ដាប់"] *និង* ឯកសារ **E3/5658** ចម្លើយរបស់ កែវ លឿ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័ 00863288 ["ខ្ញុំធ្លាប់បានរៀនសូត្រ ហើយកងពលធំជាអ្នកបណ្ដុះបណ្ដាលខ្ញុំដោយផ្ទាល់ [...] បន្ទាប់ពីគណៈកងពលធំ ដែលមាន តាអឿន តាគីម និង តាយ៉ាន ត្រូវបានចាប់ខ្លួន [...] អ្នកនៅក្នុងកង[កងវរៈសេនាតូច]ខ្ញុំទាំងអស់គ្នា ត្រូវគេហៅឲ្យទៅរៀនសូត្រ [...] នៅពេលយើងចូលដល់ក្នុងសាលា រៀន មានគ្រូឧទ្ទេសនាមចាក់ខ្សែអាត់ឲ្យយើងស្ដាប់។ ខ្សែនោះជាសម្លេងរបស់ តាគីម និង តាអឿន [...] ខ្សែអាត់និយាយអំពីប្រវត្តិរូបរបស់អ្នកទាំងពីរ [...] រហូតដល់ថ្ងៃចាប់ផ្ដើមធ្វើសកម្មភាពក្បត់របស់ពួកគាត់"]។

[118] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧៩។

[119] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៨៦។

[120] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៨៦។ សាក្សីបានបញ្ជាក់ថា ខ្លឹមសារនៃចម្លើយនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានអានឲ្យគាត់ស្ដាប់ឡើងវិញ ក្នុងពេលធ្វើសក្ខីកម្មជាច្រើនដង *សូមមើល* ឯកសារ **E1/319.1** ប្រតិចារិក ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥ (សែម ហឿន) ទំព័រ ៧៨ បន្ទាត់ទី ៥ ទំព័រ ៨២ បន្ទាត់ទី ២១-២២។

សក្ខីកម្មរបស់គាត់ ពោលគឺ ភាពពាក់ព័ន្ធគ្នារបស់សាក្សីទៅនឹង "ខ្សែក្បត់" ក្នុងឆ្នាំ ១៩៧៥[121] និងសាក្សីដឹកជញ្ជូនអាវុធតាមរថយន្តជាខ្សែទៅកាន់ខេត្តកំពង់ចាម តាមបញ្ជារបស់ អឿន[122] និង ការរៀបចំ និងការចូលរួមរបស់កងកម្លាំងកងវរៈសេនាតូច[123] និងការចូលរួមនៃភូមិភាគដទៃទៀតនៅក្នុងផែនការបះបោរប្រឆាំងនេះ[124] និងអត្ថិភាពក្រុម "ខ្មែរស" ដែលរៀបចំឡើងដោយ ឈ្មោះ អឿ[125]។ លើសពីនេះទៅទៀត ព័ត៌មានលម្អិតដែលសំខាន់ពាក់ព័ន្ធនឹងផែនការបះបោរប្រឆាំង ត្រូវបាន នួន ជា ដកស្រង់នៅក្នុងសំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែមរបស់គាត់ ដោយគាត់អះអាងថា បានមកពីឯកសារសក្ខីកម្មរបស់ សែម ហឿន ពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមាននៅក្នុងសំណុំរឿង

---

[121] *សូមប្រៀបធៀប* ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៩២ ["វាចាប់ផ្តើមពីឆ្នាំ ១៩៧៥ ដែលគេចោទថាខ្ញុំជាប់ខ្សែក្បត់ និង គេចោទខ្ញុំតាំងពីឆ្នាំ ១៩៧៥ ដល់ ១៩៧៧"] *និង* ឯកសារ **E3/7516** ចម្លើយរបស់ សែម ហឿន នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ 00876492-00876493 ["ខ្ញុំត្រូវបានគេបញ្ជូនទៅឈរជើងនៅព្រែកញ្ញៅ [...] ដោយសារខ្ញុំជាប្រធានកងវរៈសេនាតូច នៅក្រោមបញ្ជាការរបស់ អឿន។ គេចោទខ្ញុំថាជាខ្សែក្បត់ [...] នៅក្នុងឆ្នាំ ១៩៧៥"]។

[122] *សូមប្រៀបធៀប* ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៩៤-៩៥ ["បើតាមចម្លើយ សែម ហឿន គាត់ធ្វើតាមបញ្ជាពីប្រធានកងពលធំ ៣១០ ឈ្មោះអឿន និង បានដឹកនាំកងអនុសេនាតូច ដែលដឹកអាវុធ ៦ ឡានយកទៅស្តុកទុកនៅកំពង់ចាម"] *និង* ឯកសារ **E3/7516** ចម្លើយរបស់ សែម ហឿន របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ 00876520 ["[អឿន] ប្រគល់កងអនុសេតូចមួយមកឱ្យខ្ញុំ ដើម្បីដឹកនាំ និង ឡាន ៥៥ គ្រឿងដើម្បីដឹកអាវុធយកទៅលាក់ទុកនៅកំពង់ចាម [...] ខ្ញុំពិតជាបានដឹកអាវុធទៅកាន់ខេត្តកំពង់ចាម"]។

[123] *សូមប្រៀបធៀប* ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៩១ ["សែម ហឿន បានពន្យល់ថា 'ក្នុងកិច្ចប្រជុំ គឺហៅគ្រប់វរៈសេនាធំ និង វរៈសេនាតូច"] *និង* ឯកសារ **E3/7516** ចម្លើយរបស់ សែម ហឿន របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ 00876520 ["គេបញ្ជាឱ្យយើងត្រៀមខ្លួន ដើម្បីរង់ចាំបញ្ជា កាលណាវេលានោះមកដល់យើងត្រូវ [...] ប្រយុទ្ធ និង ចូលកាន់កាប់ព្រលានយន្តហោះពោធិ៍ចិនតុង [...] កងវរៈសេនាតូចមួយទៀត ទទួលបញ្ជាឱ្យត្រៀមវាយកម្ទេចស្ថានីយវិទ្យុ។ ប៉ុន្តែ ផែនការនេះត្រូវបែកការណ៍"]។

[124] *សូមប្រៀបធៀប* ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៨៧ ["សែម ហឿន ទំនងជាចង់ប្រាប់ថា ភូមិភាគដទៃទៀតក៏ជាប់ពាក់ព័ន្ធផងដែរ"] *និង* ឯកសារ **E3/7516** ចម្លើយរបស់ សែម ហឿន របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ 00876520 ["នៅពេលមេៗ [របស់ផែនការបះបោរ] ដូចជា អឿន និង ធុច [កុយ ធួន ជាប្រធានភូមិភាគឧត្តរ] ត្រូវបានចាប់ខ្លួនទាំងអស់"]។

[125] *សូមប្រៀបធៀប* ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៩៧ ["សែម ហឿន ឆ្លើយថា គាត់ 'សែម បានឮឈ្មោះ "ខ្មែរស" បន្ទាប់ពី អឿន ត្រូវបានចាប់ខ្លួន"] *និង* ឯកសារ **E3/7516** ចម្លើយ សែម អឿន របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ 00876520 ["អឿន មានមនសិការជាតិនិយមផ្ទាល់ខ្លួនរបស់គាត់ផងដែរ។ គាត់ខំកសាងកម្លាំងផ្ទៃក្នុងមួយឈ្មោះថា "ខ្មែរស" ដើម្បីតស៊ូប្រឆាំងរបបខ្មែរក្រហម"]។

ដែលមេធាវីការពារក្តីបានទទួលស្គាល់ថា "ជាចំណុចជាក់លាក់នៃរដ្ឋប្រហារ ដែលគាត់បានពន្យល់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា"[126]។

58. ទីពីរ ប្រតិចារឹក មិនសមស្របដើម្បីយកមកបញ្ជាក់អង្គហេតុ ទៅតាមការអះអាងរបស់ មេធាវីការពារក្តីបាននោះទេ។ នួន ជា លើកឡើងថា ប្រតិចារឹករបស់សាក្សីទាំងនេះ "ក៏ស៊ីសង្វាក់គ្នា និងបញ្ជាក់ផងដែរទៅលើភ័ស្តុតាងពាក់ព័ន្ធនឹងលក្ខណៈនៃផែនការ ក ក្នុងការផ្តួលរំលំ ប៉ុល ពត នួន ជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យស្របច្បាប់"[127]។ ប៉ុន្តែ ប្រតិចារឹកទាំងនេះ មិនបានគាំទ្រដល់ទឡ្ហីករណ៍នេះជារួមនោះទេ។ សាក្សី កែវ លឿ បានទទួលស្គាល់ថា គាត់មិនបានដឹងគ្រប់គ្រាន់អំពីផែនការធ្វើរដ្ឋប្រហារនេះ[128] ដោយគាត់លើកឡើងថា "ខ្ញុំឃើញឡានទាហានមានដឹកអាវុធ [...] និងពេលខ្ញុំសួរគេ គេព្រមានខ្ញុំកុំឲ្យចេះដឹងរឿងគេ"[129]។ សាក្សី សែម ហឿន នៅពេលសួរថាគាត់មានដឹងថា អឿន ចូលដៃគ្នាជាមួយវៀតណាម ឬអ្នកដទៃទៀតដែរឬយ៉ាងណា គាត់ឆ្លើយថា "ខ្ញុំមិនដឹងថាគាត់មានជាប់ពាក់ព័ន្ធនឹងសកម្មភាពនយោបាយទាំងនោះនៅពេលណាមួយនោះទេ"[130] ហើយ "ខ្ញុំអត់បានដឹងផែនការរបស់ អឿន [...] ខ្ញុំអត់ដឹងថាគាត់មានផែនការក្បត់អង្គការ ឬយ៉ាងណានោះទេ"[131]។

59. នួន ជា បានគូសបញ្ជាក់អំពីប្រតិចារឹករបស់សាក្សី ដែលមេធាវីការពារក្តីអះអាងថាគាំទ្រដល់ជំហររបស់ខ្លួន ប៉ុន្តែបែរជាមិនបានពន្យល់ត្រង់កន្លែងដែលសាក្សីទាំងពីរនិយាយជាន់កែងខ្លួនឯង ពាក់ព័ន្ធនឹងបញ្ហាសំខាន់ៗ[132]។ មេធាវីការពារក្តី ចង់បំភាន់ ដោយស្នើសុំឲ្យទទួលយកប្រតិចរឹកចំនួន ០២ សម្រាប់

---

[126] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៨៨។

[127] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១៥៣។ *សូមមើលផងដែរ* ដូចខាងលើ ត្រង់កថាខណ្ឌ ៣៨, ៣៩, ៤៧។

[128] ឯកសារ **E1/317.1** សក្ខីកម្មរបស់ កែវ លឿ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រទី ៩ បន្ទាត់ទី ២-៣។

[129] ឯកសារ **E1/317.1** សក្ខីកម្មរបស់ កែវ លឿ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រទី ១០ បន្ទាត់ទី ១១-១៣។ *សូមមើល* ទំព័រទី ១០ បន្ទាត់ទី ២៤ [ដោយបានបញ្ជាក់ថា គាត់ "បានឃើញឡានតែមួយគ្រឿងប៉ុណ្ណោះ"]។

[130] ឯកសារ **E1/319.1** សក្ខីកម្មរបស់ សែម ហឿន ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រទី ២១ បន្ទាត់ទី ២៣-២៤។

[131] ឯកសារ **E1/319.1** សក្ខីកម្មរបស់ សែម ហឿន ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រទី ៥៣ បន្ទាត់ទី ២៣ និង ទំព័រទី ៥៤ បន្ទាត់ទី ១។

[132] *សូមមើល ឧទាហរណ៍* ឯកសារ **E1/320.1** សក្ខីកម្មរបស់ សែម ហឿន ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រទី ៣៨ បន្ទាត់ទី ១៨ និង ទំព័រទី ៣៩ បន្ទាត់ទី ២៥។ សូមប្រៀបធៀប ឯកសារ **E1/319.1** សក្ខីកម្មរបស់ សែម ហឿន ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ

សាក្សីនីមួយៗ ដែលតាមការពិត ប្រតិចារឹកទាំងអស់មាន ០៣ សម្រាប់សាក្សីម្នាក់ៗ[133]។ ឧទាហរណ៍នេះជាលក្ខណៈពាក់ព័ន្ធមួយ ដូចនៅក្នុងថ្ងៃដំបូងដែលគាត់ផ្តល់សក្ខីកម្ម (នួន ជា មិនបានស្នើលើចំណុចនេះទេ) សែម ហឿន ឆ្លើយថា ការចាប់ខ្លួន អឿន "កើតឡើងនៅចុងឆ្នាំ ១៩៧៥"[134]។ កាលបរិច្ឆេទនេះ ធ្វើឱ្យប៉ះពាល់ដល់សក្ខីកម្មក្រោយៗមកទៀតរបស់គាត់ ដែលគាត់ថា គាត់បានដឹកជញ្ជូនអាវុធតាមបញ្ជារបស់ អឿន នៅឆ្នាំ ១៩៧៦ និង ១៩៧៧[135] និង ថា អឿន ត្រូវបានចាប់ខ្លួននៅចុងឆ្នាំ ១៩៧៧[136]។ ភាពមិនស៊ីសង្វាក់គ្នាបន្ថែមទៀត ត្រូវបាន នួន ជា ធ្វើមិនដឹងមិនឮ។ នួន ជា លើកឡើងថា "បើតាម សែម ហឿន [...] គាត់ធ្វើតាមបញ្ជាពីមេបញ្ជាការកងពល ៣១០ ឈ្មោះ អឿន និងដឹកនាំកងវរៈសេនាតូចមួយ"[137] ប៉ុន្តែបែរជាមិនបាននិយាយថា សាក្សីនេះក៏បានឆ្លើយដែរថា "គាត់មិនដែលបានទទួលបញ្ជាដោយផ្ទាល់ពីឈ្មោះ អឿន"[138]នេះទេ។

60. ដូចគ្នានេះដែរ នួន ជា ពឹងផ្អែកទាំងស្រុងលើសក្ខីកម្មរបស់សាក្សី កែវ លឿ ពាក់ព័ន្ធនឹងកិច្ចប្រជុំ ដែលនិយាយអំពីផែនការចលនាបះបោរ[139] ទោះបីជាព័ត៌មានដែលសាក្សីនេះបានផ្តល់ មានលក្ខណៈស្រពិចស្រពិលខ្លាំងយ៉ាងណាក៏ដោយ។ សាក្សីបានឆ្លើយថា លើសពីមួយលើក "ខ្ញុំមិនដឹងលម្អិតអំពីកិច្ចប្រជុំនោះទេ។ ខ្ញុំគ្រាន់តែដឹងថា ដូចដែលខ្ញុំនិយាយខាងដើម អំពីការដឹកជញ្ជូនអាវុធ និងពេលខ្ញុំសួរគេ គេព្រមានខ្ញុំកុំឱ្យចេះដឹងរឿងគេ។ ខ្ញុំដឹងតែប៉ុណ្ណឹង"[140]។ លើសពីនេះទៅទៀត នួន ជា ដកស្រង់សាក្សី

---

២០១៥ ទំព័រទី ២៣ បន្ទាត់ទី ៧ និង ឯកសារ **E1/319.1** សក្ខីកម្មរបស់ សែម ហឿន ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រទី ៨១ បន្ទាត់ទី ២-៣។

[133] *សូមមើល* ឯកសារ **E1/315.1** សក្ខីកម្មរបស់ កែវ លឿ ចុះថ្ងៃទី ១២ ខែ មិថិនា ឆ្នាំ ២០១៥។ ឯកសារ **E1/318.1** សក្ខីកម្មរបស់ សែម ហឿន ចុះថ្ងៃទី ១៧ ខែ មិថិនា ឆ្នាំ ២០១៥។

[134] ឯកសារ **E1/318.1** សក្ខីកម្មរបស់ សែម ហឿន ចុះថ្ងៃទី ១៧ ខែ មិថិនា ឆ្នាំ ២០១៥ ទំព័រទី ៩៨ បន្ទាត់ទី ៦-៩។

[135] ឯកសារ **E1/319.1** សក្ខីកម្មរបស់ សែម ហឿន ចុះថ្ងៃទី ២២ ខែ មិថិនា ឆ្នាំ ២០១៥ ទំព័រទី ៧៨ បន្ទាត់ទី ១-៥។ ឯកសារ **E1/320.1** សក្ខីកម្មរបស់ សែម ហឿន ចុះថ្ងៃទី ២៣ ខែ មិថិនា ឆ្នាំ ២០១៥ ទំព័រទី ១៦ បន្ទាត់ទី ១១-១៣។

[136] ឯកសារ **E1/320.1** សក្ខីកម្មរបស់ សែម ហឿន ចុះថ្ងៃទី ២៣ ខែ មិថិនា ឆ្នាំ ២០១៥ ទំព័រទី ៩-១០ បន្ទាត់ទី ១,៤។

[137] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៩៤។

[138] ឯកសារ **E1/319.1** សក្ខីកម្មរបស់ សែម ហឿន ចុះថ្ងៃទី ២២ ខែ មិថិនា ឆ្នាំ ២០១៥ ទំព័រទី ២៣ បន្ទាត់ទី ៧។

[139] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៣១, ៣៩, ៧៩, ៨០, ១៥២។

[140] ឯកសារ **E1/317.1** សក្ខីកម្មរបស់ កែវ លឿ ទំព័រទី ៩ បន្ទាត់ទី ១៤។

កែវ លឿ ដែលឆ្លើយថា "កងទាហានពិការ ក-៤ គេឲ្យជួយរៀបចំស្បៀងអាហារ"[141]។ ប៉ុន្តែ នួន ជា មិនបានលើកឡើងពីចំណុចដែល កែវ លឿ បានឆ្លើយផងដែរថា "ខ្ញុំមិនដឹងអំពីការស្តុកទុកស្បៀងអាហារសម្រាប់ផ្គត់ផ្គង់ទេ" ដែលនេះជាភ័ស្តុតាងដែលខំប្រឹងរម្លេចឡើងដោយក្រុមមេធាវីការពារក្តី នួន ជា នៅក្នុងតុលាការ[142]។

61. ផ្ទុយទៅវិញ មេធាវីការពារក្តីស្នើដោយគ្មានហេតុផលថា សក្ខីកម្មរបស់សាក្សីទាំងនេះ "បង្កើនសារៈសំខាន់នៃភ័ស្តុតាងរបស់ពួកគាត់ ហើយជម្រុញឲ្យមេធាវីការពារក្តីស្នើនូវភ័ស្តុតាងនេះ"[143]។ តាមពិត សារៈសំខាន់នៃភ័ស្តុតាងនេះ នួន ជា អាចរកបានតាំងពីក្នុងអំឡុងពេលជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ មកម្ល៉េះ ប៉ុន្តែមេធាវីការពារក្តីសម្រេចមិនយកវាមកប្រើ។ ការណ៍ដែលព្យាយាមសុំឲ្យទទួលស្គាល់ភ័ស្តុតាងនោះលើបណ្តឹងឧទ្ធរណ៍នៅពេលនេះ គឺជាការយឺតពេលណាស់ទៅហើយ និងម្យ៉ាងទៀត វាគឺជាការប៉ុនប៉ងច្បាស់ក្រឡែតមួយរបស់ នួន ជា ក្នុងការពន្យារដំណើរការបណ្តឹងសាទុក្ខដោយឥតប្រយោជន៍។

62. ជាមួយគ្នានេះផងដែរ នួន ជា មិនបានកំណត់សំអាងហេតុណាមួយនៅក្នុងសាលក្រម ដែលពាក់ព័ន្ធនឹងភ័ស្តុតាងនោះទេ[144]។ ទោះបីភាគីមានសិទ្ធិស្នើសុំឲ្យទទួលយកភ័ស្តុតាងលើបណ្តឹងសាទុក្ខយ៉ាងណាក្តី មិនមែនមានន័យថា វិធានអនុញ្ញាតឲ្យ នួន ជា អះអាងជាលក្ខណៈទូទៅ ក្នុងការមិនយល់ស្របទៅនឹងសំអាងហេតុនៅក្នុងសាលក្រម និងប្រឹងស្នើសុំឲ្យទទួលយកភ័ស្តុតាង ដែលគាត់អះអាងថាគាំទ្រជំហររបស់គាត់ តាមតែអំពើចិត្តបាននោះទេ។ ទាំងភាគី និងអង្គជំនុំជម្រះ សុទ្ធតែមិនតម្រូវឲ្យទស្សន៍ទាយថាតើ "សំអាងហេតុជាក់លាក់ផ្នែកណាខ្លះ" នៅក្នុងសាលក្រមសាលាដំបូង ដែលជាផ្នែកជាក់លាក់ ដែលមេធាវីការពារក្តីស្នើឲ្យទទួលយកភ័ស្តុតាងដើម្បីជំទាស់[145]។

---

[141] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៨១។

[142] ឯកសារ **E1/317.1** សក្ខីកម្មរបស់ កែវ លឿ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រទី ៤ បន្ទាត់ទី ១៤។

[143] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១៥៨។

[144] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៧៦-៩៧។

[145] *សូមមើល* វិធាន ១០៨(៧)។

63. សហព្រះរាជអាជ្ញា កត់សម្គាល់ផងដែរថា សំណុំរឿង ០០២/០១ មានចម្លើយបន្ថែមពីរទៀតរបស់សាក្សី សែម ហឿន[146] ដែលមានក្នុងសំណុំរឿងចាប់តាំងពីជំនុំជម្រះលើសំណុំរឿង ០០២/០១ មកម្ល៉េះ។ ចម្លើយទាំងពីរនេះ មានព័ត៌មានអំពីការចាប់ខ្លួន អឿន និងចម្លើយសារភាពរបស់គាត់[147] ក៏ប៉ុន្តែ នួន ជា មិនបានលើកបញ្ហានេះជូនអង្គជំនុំជម្រះនោះទេ។

### *iii- ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា*

64. នួន ជា ចង់សុំឲ្យទទួលយកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពាក់ព័ន្ធនឹងបុគ្គលបួននាក់ និងប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០២/០២ មួយរបស់បុគ្គលម្នាក់ក្នុងចំណោមទាំងបួននាក់នោះ។ សហព្រះរាជអាជ្ញាសូមជំទាស់សំណើទាំងនោះ។ ឯកសារទាំងបួនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សុទ្ធតែអាចរកបានក្នុងពេលជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ដោយសារឯកសារនោះត្រូវបានដាក់ក្នុងសំណុំរឿងក្នុងខែ ឧសភា និងមិថុនា ឆ្នាំ ២០១១ និងមានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ ដែលជាប្រភពឯកសារអាចរកបានជាសាធារណៈ។ ដូច្នេះ នួន ជា មិនបានអនុវត្តការយកចិត្តទុកដាក់ត្រឹមត្រូវក្នុងការស្នើសុំឲ្យទទួលយកឯកសារទាំងនោះ។

65. ជាការពិត នួន ជា មិនត្រឹមតែបានស្រាវជ្រាវរកឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាប៉ុណ្ណោះទេ កាលនៅក្នុងអំឡុងពេលជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ គាត់ថែមទាំងបានជម្រាបអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ យ៉ាងច្បាស់លាស់ថា គាត់មានបំណងស្នើសុំឲ្យទទួលយកឯកសារចំនួន ២.៣៨៤ ដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា[148]។ គាត់បានកត់សម្គាល់ក្នុងការដាក់ឯកសារ

---

[146] ឯកសារ **E3/5152** ចម្លើយរបស់ សែម ហឿន នៅការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៨។ ឯកសារ **E3/5280** ចម្លើយរបស់ សែម ហឿន នៅការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩។ ចម្លើយទាំងពីរនេះ សុទ្ធតែត្រូវបានយោងនៅក្នុងសាលក្រមសាលាដំបូង។ *សូមមើល ឧទាហរណ៍* ឯកសារ **E313** សាលក្រមសាលាដំបូង កថាខណ្ឌ ៤៦០ លេខជើងទំព័រ ១៣៦៣, កថាខណ្ឌ ៥០៥ លេខជើងទំព័រ ១៥១៤។

[147] *សូមមើល* ឯកសារ **E3/5280** សូមមើលចម្លើយរបស់ សែម ហឿន របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ យោងឯកសារ **E313** សាលក្រមសាលាដំបូង កថាខណ្ឌ ១៤៨ លេខជើងទំព័រ ៤២៩, កថាខណ្ឌ ១៤៩ លេខជើងទំព័រ ៤៣៧, កថាខណ្ឌ ៤៦០ លេខជើងទំព័រ ១៣៦៣។

[148] ឯកសារ **E211** ការជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការស្រាវជ្រាវនៅ DC-Cam ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ ត្រង់កថាខណ្ឌ ១៣ (ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា គាត់មានបំណងចង់"ទាក់ទង DC-Cam ដើម្បីពិនិត្យខ្សែ

នោះថា គាត់“បានប្រាស្រ័យទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជា ច្រើនលើកច្រើនគ្រា និង ថា មជ្ឈមណ្ឌលនេះបានជួយគាំទ្រដល់បញ្ហាជាក់លាក់ដទៃទៀតដែល...”[149]។ អង្គជំនុំជម្រះសាលាដំបូង បានឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងរបស់ នួន ជា ដោយជម្រាបគាត់ថា “នៅពេលដែលខ្លួនមាន ឯកសារដែលស្ថិតនៅក្នុងមជ្ឈដ្ឋានសាធារណៈ ដែលខ្លួនជឿថាជាឯកសារពាក់ព័ន្ធនឹងការវាយតម្លៃ របស់អង្គជំនុំជម្រះ អំពីភាពអាចជឿជាក់បាន ឬតម្លៃជាភស្តុតាងនៃឯកសារនៅចំពោះមុខអង្គជំនុំជម្រះ នោះ មេធាវីមានជម្រើសមួយចំនួន ដោយអនុលោមតាមវិធានផ្ទៃក្នុង... ឧទាហរណ៍... ស្នើសុំការ ទទួលយកឯកសារបន្ថែម ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង”[150]។ម្យ៉ាងទៀត នៅដើមឆ្នាំ ២០០៩ ក្នុងពេលស៊ើបអង្កេតសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹង ភាគីថា “សូមធ្វើការរម្លឹកថា ភាគីនៅតែ*មាន*សិទ្ធិ និងសេរីភាពពេញលេញ ក្នុងការអានគ្រប់ឯកសារ ទាំងអស់ ដែលទទួលបានពីគ្រប់ប្រភពសាធារណៈទាំងអស់ ក្នុងការស្រាវជ្រាវរកភស្តុតាងរបស់ ខ្លួន”[151]។

66. គ្មានភស្តុតាងណាមួយ នៅក្នុងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឬប្រតិចារឹកទាំងនោះ អាច ជាកត្តាកំណត់នៅក្នុងសាលក្រមនោះឡើយ។ ម្យ៉ាងទៀត ដើម្បីប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះមិន ត្រូវទទួលយកវាទេ។ ក្នុងចំណោមឯកសារទាំងនោះ គ្មានឯកសារណាមួយ និយាយយោងទៅរក

---

សង្វាក់នៃការរក្សាទុកឯកសារ និង ភាពពាក់ព័ន្ធនៃឯកសារដែល កសព មានបំណងយកមកសំអាងដូចដែលបានរៀបរាប់ក្នុងឯកសារ E-161.1”។ E161.1 ជាបញ្ជីឯកសារចំនួន ២,៣៨៤ ទទួលបានពី DC-Cam)។

[149] ឯកសារ **E211** ការជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការស្រាវជ្រាវនៅ DC-Cam ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ លេខជើងទំព័រ ១២។

[150] ឯកសារ **E211/2** អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង៖ សេចក្តីជូនដំណឹងរបស់មេធាវីការពារជនជាប់ចោទ នួន ជា មក អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងការស្រាវជ្រាវនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជា (E211), ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២ ត្រង់កថាខណ្ឌ ៤។

[151] **D164/2** ដីកាសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងទុកឯកសាររួម SMD, ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៤។ *សូមមើលផងដែរ* **D365/2/10** សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែម ទៅក្នុង សំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង, ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០។

ព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ការគ្រប់គ្រងតាមឋានានុក្រមដ៏មានប្រសិទ្ធភាពរបស់មជ្ឈិមទៅលើភូមិភាគឧត្តរ នៅពេលមានការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ឬការផ្លាស់ទីលំនៅដោយបង្ខំ ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ នោះទេ។ ផ្អែកលើតែលើមូលហេតុនេះមួយ អង្គជំនុំជម្រះអាចបដិសេធសំណើទាំងនោះបាន។ ម្យ៉ាងទៀត ឯកសារទាំងនោះមិនបានគាំទ្រដល់ការអះអាងរបស់ នួន ជា ក្នុងការស្នើសុំឲ្យទទួលយកនោះទេ។

### ១. ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងសំណើសុំកោះហៅសាក្សីលេខ ៦

67. នួន ជា ស្នើសុំឲ្យទទួលយកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជារបស់សាក្សីលេខ ៦ និងកោះហៅគាត់មកធ្វើជាសាក្សី[152]។ សហព្រះរាអាជ្ញា សូមជំទាស់សំណើទាំងពីរនេះ។ ដូចបានបញ្ជាក់ជូនខាងលើ ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា អាចរកបានក្នុងអំឡុងពេលជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ និងត្រូវបានដាក់ក្នុងសំណុំរឿងនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ប៉ុន្តែ នួន ជា មិនបានស្នើសុំឲ្យទទួលយកវានៅក្នុងពេលនោះ ឬក្នុងពេលណាមួយទៀតក្នុងរយៈពេលបួនឆ្នាំ បន្ទាប់ពីឯកសារនោះមាននៅក្នុងសំណុំរឿង។

68. នួន ជា ស្នើសុំឲ្យទទួលយកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយអះអាងថា “មានព័ត៌មានលម្អិតស្តីពីផែនការក្បត់របស់ភូមិភាគពាយ័ព្យ ដើម្បីប្រឆាំងនឹង ប៉ុល ពត ដែលរៀបចំឡើងដោយមេៗរបស់ [សាក្សីលេខ ៦], តាហ៊ីង លេខាតំបន់ ៥ និង តាវ៉ាល់ ប្រធានកងចល័ត”[153]។ ការអះអាងពាក់ព័ន្ធនឹងភស្តុតាងរបស់សាក្សីលេខ ៦ នេះមិនមែនជាការពិតទេ។ សាក្សីលេខ ៦ មិនបាននិយាយអ្វីពាក់ព័ន្ធនឹង “ផែនការក្បត់” ដែលរៀបចំដោយ “ភូមិភាគពាយ័ព្យ”នោះទេ។ សាក្សីលេខ ៦ ឆ្លើយអះអាងអំពីចម្លើយ និងសកម្មភាពរបស់លេខតំបន់ (តាហ៊ីង)តែម្នាក់ប៉ុណ្ណោះ និងប្រធានកងចល័ត (តាវ៉ាល់)តែម្នាក់ ដែលអ្នកទាំងពីរនេះមិនស្ថិតនៅក្នុងតំបន់នៃភូមិភាគពាយ័ព្យ ជាកន្លែងពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ទួលពោធិ៍ជ្រៃ ក្នុងសំណុំរឿង ០០២/០១ នោះទេ។ គាត់មិនបានផ្តល់ភស្តុតាងពាក់ព័ន្ធនឹងផែនការ “ភូមិភាគពាយ័ព្យ” ជាទូទៅទេ។ ក្នុងការប៉ុនប៉ងទាំងអស់សង្ឃឹមក្នុងការរម្លេចផែនការ “ភូមិភាគពាយ័ព្យ”នេះ នួន ជា ប៉ុនប៉ងបំផុសន័យទូទៅនៅក្នុងចំណុចបី ដែលសាក្សីលេខ ៦ បាន

---

[152] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ៩៩-១០២។

[153] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១០០។

ឆ្លើយពាក់ព័ន្ធនឹង រស់ ញឹម (១) ថាគាត់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ សោ ភឹម (២) ថា គាត់បានចុះទៅមើលការដ្ឋានសំណង់ធំៗនៅក្នុងភូមិភាគគាត់ និង (៣) ថាគាត់បានដឹកទ្រនាប់ជើងមកឲ្យកងចល័តភូមិភាគបូព៌ា[154]។ សកម្មភាពទាំងនេះ ពិបាកនឹងកំណត់ថាជាផែនការក្បត់ណាស់។

69. ដូច្នេះ សាក្សីលេខ ៦ ផ្តល់ភ័ស្តុតាងដែលថា តាហ៊ឹង និង តាវ៉ាល់ នៅក្រោយឆ្នាំ ១៩៧៧[155] មាន "ផែនការ" មិនច្បាស់លាស់មួយ។ ប៉ុន្តែ រាល់ព្រឹត្តិការណ៍ដែលជាកម្មវត្ថុនៃការរកឃើញពិរុទ្ធភាពនៅក្នុងសំណុំរឿង ០០២/០១ សុទ្ធតែកើតឡើងនៅមុនឆ្នាំ ១៩៧៧។

70. សហព្រះរាជអាជ្ញា សូមកត់សម្គាល់បន្ថែមទៀតថា សាក្សីលេខ ៦ ត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេតសម្ភាស និងកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់គាត់មាននៅក្នុងសំណុំរឿងផងដែរ[156] ដែលនេះបញ្ជាក់ការពិតថា នួន ជា ពិតជាមិនស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកឯកសារនេះ។ គ្មានអ្វីគួរឲ្យមន្ទិលបន្តិចសោះថា នួន ជា ពិតជាបានដឹងថា កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់សាក្សីម្នាក់នេះមាននៅក្នុងសំណុំរឿង ក្នុងពេលគាត់ដាក់សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែមនេះ ដោយសារថ្មីៗនេះ គាត់បានស្នើសុំឲ្យកោះហៅបុគ្គលរូបនេះ មកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ និងបានគូសបញ្ជាក់ប្រាប់អង្គជំនុំជម្រះសាលាដំបូងថា "គាត់ទើបតែដឹងថាមានកំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៦ នៅពេលសហព្រះរាជអាជ្ញាបង្ហាញឯកសារនេះ នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥"[157]។ ការណ៍ដែល នួន ជា មិនបានស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីរូបនេះពីពេលមុន គឺរឹតតែជាបញ្ហា ដោយសារកំណត់ហេតុស្តាប់ចម្លើយសាក្សីនេះ បញ្ជាក់ថា គោលបំណងរបស់វា គឺដើម្បីសាកសួរបន្ថែមពាក់ព័ន្ធទៅនឹងបញ្ហា ដែលបានលើកឡើងនៅក្នុងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែល នួន ជា មានបំណងស្នើសុំឲ្យទទួលយកនោះ។ កំណត់ហេតុស្តាប់ចម្លើយសាក្សីនោះ បញ្ជាក់ថា អ្នកស៊ើបអង្កេតបានជូនដំណឹងទៅសាក្សីទី ៦ ថា "គោលបំណងនៃកិច្ចសម្ភាស

---

[154] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១០១។

[155] ឯកសារ **E3/9076** សម្ភាសន៍សាក្សីលេខ ៦ របស់ DC-Cam ឯកសារភាសាអង់គ្លេស ENG ERN 00731157។

[156] ឯកសារ **E319/19.3.18** កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៦។

[157] ឯកសារ **E368** សំណើ នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំស្តាប់សក្ខីកម្មពីសាក្សីម្នាក់ទៀត សម្រាប់វគ្គទីមួយនៃសវនាការសំណុំរឿង ០០២/០១ ស្តីពីទំនប់ត្រពាំងថ្ម ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៥ កថាខណ្ឌ ១៤។

ថ្ងៃនេះ គឺយើងនឹងធ្វើបទសម្ភាសជាមួយលោកដែលទាក់ទិនទៅនឹងចម្លើយរបស់លោកដែលបានផ្តល់ជូនទៅមជ្ឈមណ្ឌលឯកសារកម្ពុជាពីលើកមុន”[158]។

71. ក្រោយពីពិនិត្យមើលកំណត់ហេតុស្តាប់ចម្លើយសាក្សី យើងអាចដឹងច្បាស់ថា ហេតុអ្វីបានជា នួន ជា មិនចង់ឲ្យអង្គជំនុំជម្រះនេះ ទទួលស្គាល់ភ័ស្តុតាងទាំងមូលរបស់សាក្សីរូបនេះ ដែលមាននៅក្នុងសំណុំរឿង។ ភ័ស្តុតាងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីនេះ ធ្វើឲ្យខូចប្រយោជន៍ដល់ការប៉ុនប៉ងរបស់ នួន ជា ក្នុងការអះអាងលើបទសម្ភាសន៍សាក្សីទី ៦ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ នួន ជា ចង់លើកឡើងថា ចម្លើយរបស់សាក្សីទី ៦ របស់មជ្ឈមណ្ឌលឯកសារកម្ពុជាពាក់ព័ន្ធនឹងកិច្ចប្រជុំមួយដែលតាវ៉ាល់និយាយថា “ពួកមិត្តឯងសុទ្ធតែសត្តិ ៣”នោះ គឺជាការត្រៀមសម្រាប់បះបោរ[159]។ កំណត់ស្តាប់ចម្លើយសាក្សីទី ៦ បង្ហាញថា សម្តីសាក្សីលេខ ៦ នៅពេលនោះ គឺមិនមែននិយាយសំដៅលើតាវ៉ាល់ គឺគាត់ចង់និយាយសំដៅតាហ៊ីង[160]។ កំណត់ហេតុស្តាប់ចម្លើយរបស់គាត់បង្ហាញទៀតថា គាត់មិនបានដឹងច្បាស់ មិនដឹងថាពាក្យថា “អ្នកទាំងអស់គ្នានឹងអាចក្លាយទៅជាសត្តិ ៣” ចង់មានន័យថាម៉េចនោះទេ។ សាក្សីទី ៦ អាចត្រឹមតែស្មានថា “គិតថា គាត់និយាយពីការរៀបចំពួកយើងឲ្យទៅជាកងទ័ព ដើម្បីប្រឆាំងនឹងពួកខ្មែរក្រហម”[161]។

72. សំខាន់ជាងនេះទៅទៀត កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៦ ក៏បានឆ្លើយផ្ទុយស្រលះទៅនឹងការអះអាងរបស់ នួន ជា ពាក់ព័ន្ធនឹងចម្លើយសាក្សីលេខ ៦ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដោយពឹងផ្អែកលើផ្នែកខ្លះទៅតាមការចង់បានរបស់ខ្លួន ដែលដកស្រង់ចេញពីចម្លើយរបស់សាក្សីលេខ ៦ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នួន ជា អះអាងថា “ផែនការនោះត្រូវបែកការណ៍ នៅពេលដែលកម្មាភិបាលភូមិភាគនិរតីចូលមកដល់ភូមិភាគពាយ័ព្យ ដែលជាការបញ្ជាក់អំពីការជំនួសកម្មាភិបាលភូមិភាគពាយ័ព្យ ដោយកម្មាភិបាលមកពីភូមិភាគនិរតី គឺដោយសារតែផែនការក្បត់”[162]។ ប៉ុន្តែ កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៦ បង្ហាញថា នៅពេលគេសួរសាក្សីលេខ ៦ អំពីមូលហេតុដែលពួក

---

[158] ឯកសារ **E319/19.3.18** កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៦ ទំព័រទី ៣។

[159] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១០០។

[160] ឯកសារ **E319/19.3.18** កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៦ ត្រង់ចម្លើយទី ៤៩។

[161] ឯកសារ **E319/19.3.18** កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៦ ត្រង់ចម្លើយទី ៤៩។

[162] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម កថាខណ្ឌ ១០២។

ភូមិភាគនិរតីចាប់ខ្លួនកម្មាភិបាលមកពីភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ា គាត់ឆ្លើយថា "ខ្ញុំមិនដឹងអំពីមូលហេតុច្បាស់លាស់ក្នុងការចាប់មនុស្សនៅក្នុងភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យទេ..."[163]។

73. សហព្រះរាជអាជ្ញា ក៏កត់សម្គាល់ឃើញទៀតថា ពាក់ព័ន្ធនឹងបញ្ហានៅភូមិភាគពាយ័ព្យ ដែលមានភាពពាក់ព័ន្ធនឹងពេលវេលា និងប្រធានបទ នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ សាក្សីលេខ ៦ ឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីដូច្នេះថា៖

[អ្នកស៊ើបអង្កេត]៖ នៅពេលដែលខ្មែរក្រហមចូលមកដល់ភូមិលោក ក្នុងខែមេសា ១៩៧៥ តើពួកខ្មែរក្រហមបានធ្វើការសងសឹកជាមួយនឹងអតីតទាហាន លន់ នល់ ដែរទេ?

[សាក្សី ៦]៖ នៅពេលនោះ <u>ពួកខ្មែរក្រហមបានស្រាវជ្រាវរកអតីតអ្នកធ្លាប់ធ្វើទាហាន លន់ នល់ ដែរ</u> ហើយពេលនោះ ក្រុមគ្រួសារមួយចំនួន ដែលមានជាប់ពាក់ព័ន្ធនឹងទាហាន លន់ នល់ គឺមានការភ័យខ្លាចយ៉ាងខ្លាំង។

[អ្នកស៊ើបអង្កេត]៖ តើពួកខ្មែរក្រហមបានសងសឹកជាមួយអតីតទាហាន លន់ នល់ ដែរទេ?

[សាក្សី ៦]៖ ... អ្នកដែលគេជម្លៀសមកពីស្រុកព្រះនេត្រព្រះ បានទទួលរងគ្រោះដោយសារពួកខ្មែរក្រហម។

[អ្នកស៊ើបអង្កេត]៖ <u>តើពួកគេទាំងនោះ ត្រូវបានគេសម្លាប់ចោលដែរទេ?</u>

[សាក្សី ៦]៖ <u>បាទ</u>។ ឧទាហរណ៍ ខ្ញុំបានដឹងថា មនុស្សម្នាក់ដែលជាអតីតប្រធានភូមិប៉ោយសំរោងឈ្មោះ ភើម និងលោក រ៉ី ដែលជាអតីតទាហានសក្តិបី លន់ នល់ ដែលត្រូវបានគេជម្លៀសមកភូមិរបស់ខ្ញុំ ត្រូវបានពួកខ្មែរក្រហមចាប់ខ្លួន និងសម្លាប់នៅទីនេះ។[164]

## ២. ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជារបស់សាក្សីលេខ ៧

[163] ឯកសារ **E319/19.3.18** កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៦ ត្រង់ចម្លើយទី ៥២។

[164] ឯកសារ **E319/19.3.18** កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៦ ត្រង់ចម្លើយទី ៦-៨ (មានគូសបញ្ជាក់បន្ថែម)។

74. នួន ជា ស្នើសុំឱ្យទទួលយកចម្លើយសាក្សីលេខ ៧ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា[165]។ សហព្រះរាជអាជ្ញាសូមជំទាស់នឹងសំណើនេះ។ ដូចបានបញ្ជាក់ជូនខាងលើ ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា អាចរកបានក្នុងអំឡុងពេលជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ និង ត្រូវបានដាក់ក្នុងសំណុំរឿងនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ប៉ុន្តែ នួន ជា មិនបានស្នើសុំឱ្យទទួលយកវានៅក្នុងពេលនោះ ឬក្នុងពេលណាមួយទៀតក្នុងរយៈពេលបួនឆ្នាំ បន្ទាប់ពីឯកសារនោះមាននៅក្នុងសំណុំរឿង។

75. នួន ជា ស្នើសុំឱ្យទទួលយកឯកសារនេះ សម្រាប់ព្រឹត្តិការណ៍ដែលបានចាប់កើតមានឡើងក្នុងឆ្នាំ ១៩៧៧[166] ដែលជាព្រឹត្តិការណ៍កើតនៅក្រោយបញ្ហានៅក្នុងសំណុំរឿង ០០២/០១ ដើម្បីគាំទ្រការលើកឡើងថា មានផែនការក្បត់មួយ។ ប៉ុន្តែ សាក្សីលេខ ៧ ខ្លួនឯងទទួលស្គាល់ថា គាត់ពុំមែនជាប្រភពព័ត៌មានយកជាការបាន ឬគួរឱ្យជឿទុកចិត្តបាន ពាក់ព័ន្ធនឹងបញ្ហានេះនោះទេ។ គាត់គូសបញ្ជាក់ថា "ខ្ញុំមិនបានដឹងច្បាស់ថាផែនការក្បត់ស្អីគេហ្នឹង គឺជាអ្វីនោះទេ"[167]។

76. ជាថ្មីម្តងទៀត នួន ជា មិនបានជូនដំណឹងឱ្យអង្គជំនុំជម្រះបានដឹងថា ភ័ស្តុតាងពីសាក្សីលេខ ៧ ទាំងអស់មាននៅក្នុងសំណុំរឿង។ នួន ជា មិនបានជូនដំណឹងឱ្យអង្គជំនុំជម្រះនេះដឹងថា កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៧ ដែលមានក្នុងសំណុំរឿង ០០២ តាំងពីខែ មីនា ឆ្នាំ ២០១៥ មកម្ល៉េះ និង ដែលតាមសម្តីតាំងពីដើមដំបូងរបស់សាក្សីនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីនេះថា "គឺយោងលើកិច្ចសម្ភាសរបស់សាក្សីដែលបានសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១"[168]។ ក្រោយពីពិនិត្យមើលកំណត់ហេតុស្តាប់ចម្លើយសាក្សីរូបនេះ យើងអាចដឹងច្បាស់ថាហេតុអ្វីបានជា នួន ជា មិនចង់ឱ្យអង្គជំនុំជម្រះនេះ ទទួលស្គាល់ភ័ស្តុតាងសាក្សីរូបនេះ ដោយសារភ័ស្តុតាងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីនេះ ធ្វើឱ្យខូចប្រយោជន៍ដល់ការប៉ុនប៉ងរបស់ នួន ជា ក្នុងការសំអាងលើបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ឧទាហរណ៍ នៅក្នុងសំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម នួន ជា ដកស្រង់ចម្លើយសាក្សីលេខ ៧ របស់មជ្ឈមណ្ឌលឯកសារ

---

[165] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម កថាខណ្ឌ ១០៣-១០៦។

[166] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម កថាខណ្ឌ ១០៤។

[167] ឯកសារ **E3/8991** សម្ភាសន៍របស់សាក្សីលេខ ៦ របស់ DC-Cam ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ត្រង់ទំព័រលេខ ENG 00969893។

[168] ឯកសារ **E319/19.3.46** កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៧ ត្រង់ទំព័រទី ៧។

កម្ពុជាថា សាក្សីលេខ ៧ "មើលការខុសត្រូវមនុស្ស ៣០០ នាក់"[169] ដែលចំណុចនេះ នួន ជា ពិតជាចង់អះអាងអំពីភាពសំខាន់របស់សាក្សីលេខ ៧ នេះ។ ប៉ុន្តែ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៧ សាក្សីនេះបញ្ជាក់ថា "ខ្ញុំគ្រប់គ្រងមនុស្សតែ៣០នាក់ប៉ុណ្ណោះ មិនមែន ៣០០ នាក់ទេ"[170]។

77. សាក្សីលេខ ៧ បញ្ជាក់ក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីផងដែរថា ការណ៍ដែលគាត់យោងចម្លើយគាត់ទៅលើឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពាក់ព័ន្ធនឹងការណ៍ដែល រស់ ញឹម ចូលរួមក្នុង "ផែនការក្បត់ដែលមិនបានជោគជ័យ" ដែល នួន ជា ដកស្រង់នៅក្នុងសំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែមនោះ គឺជាការចោទប្រកាន់ដែលផ្អែកតែទៅលើពាក្យចចាមអារ៉ាម ដែលគាត់បានឮគេថា ក្រោយពេល រស់ ញឹម ត្រូវបានចាប់ខ្លួនដោយកម្មាភិបាលភូមិភាគនិរតី៖

> [អ្នកស៊ើបអង្កេត]៖ នៅទំព័រទី៨ នៃកិច្ចសម្ភាសរបស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា (ERN 00730224) លោកបាននិយាយអំពីឈ្មោះ តា ញឹម ហើយលោកថា តា ញឹម ហ្នឹង ជាមនុស្សក្បត់។ តើលោកអាចបញ្ជាក់អំពីរឿងនេះបន្ថែមបានទេ?
>
> [សាក្សី ៧]៖ តា ញឹម ជាគណៈភូមិភាគពាយ័ព្យ។ នៅពេលដែលពួកនិរតីចូលមក ខ្ញុំឮគេថា គេចោទគាត់ថាជាមនុស្សក្បត់ ហើយគេបានចាប់គាត់យកទៅបាត់រហូត។[171]

78. ទោះជាយ៉ាងនេះក្តី សហព្រះរាជអាជ្ញាកត់សម្គាល់បន្ថែមទៀតថា ពាក់ព័ន្ធនឹងគោលនយោបាយដែលជាបញ្ហានៅក្នុងសំណុំរឿង ០០២/០១ កំណត់ហេតុស្តាប់សម្លើយសាក្សីលេខ ៧ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបញ្ជាក់ភ័ស្តុតាងនៃការអនុវត្តគោលនយោបាយ ដែលយកទាហាន និងអ្នករដ្ឋការនៃរបប លន់ នល់ ធ្វើជាគោលដៅ ដោយបញ្ជាក់ថា "ក្នុងពេល តាវ៉ាល់កាន់ការ អ្នកជម្លៀសជាច្រើន

---

[169] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម កថាខណ្ឌ ១០៤។

[170] ឯកសារ **E319/19.3.46** កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៧ ត្រង់ចម្លើយទី២០។

[171] ឯកសារ **E319/19.3.46** កំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ៧ ត្រង់ចម្លើយទី ២២។

ត្រូវបានសម្លាប់...។ ពួកគេតាមដានរកទាហាន និងអ្នករដ្ឋការស៊ីវិល។ ពួកគេតាមដានប្រវត្តិរូបអ្នកទាំងនោះ" [172]។

## ៣. ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រតិចារឹក ឡូត សួយ

79. នួន ជា ស្នើសុំឱ្យទទួលយកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រតិចារឹកសវនាការសាលាដំបូងក្នុងសំណុំរឿង ០០២/០២ របស់សាក្សី ឡូត សួយ[173]។ សហព្រះរាជអាជ្ញាសូមជំទាស់សំណើទាំងពីរនេះ។ ដូចបានបញ្ជាក់ជូនខាងលើ ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអាចរកបានក្នុងអំឡុងពេលជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ និងត្រូវបានដាក់ក្នុងសំណុំរឿងនៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១១ ប៉ុន្តែ នួន ជា មិនបានស្នើសុំឱ្យទទួលយកវានៅក្នុងពេលនោះ ឬក្នុងពេលណាមួយទៀតក្នុងរយៈពេលបួនឆ្នាំ បន្ទាប់ពីឯកសារនោះមាននៅក្នុងសំណុំរឿង។ ប្រតិចារឹកសវនាការ មិនទាន់ធ្វើរួចរហូតដល់ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥។ ដូច្នេះ ប្រតិចរឹកនេះ មិនអាចរកបាននៅក្នុងអំឡុងពេលជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ទេ។ ទោះជាយ៉ាងនេះក្តី គ្មានឯកសារណាមួយក្នុងឯកសារទាំងពីរនេះ ជាកត្តាកំណត់ក្នុងសាលក្រម ឬមានភ័ស្តុតាងដែលទាមទារឱ្យទទួលយកសម្រាប់ប្រយោជន៍យុត្តិធម៌នោះទេ។

80. ភ័ស្តុតាងរបស់ ឡូត សួយ ត្រូវបានស្នើសុំឱ្យទទួលយក សម្រាប់ព្រឹត្តិការណ៍ដែលចាប់ផ្តើមនៅចុងឆ្នាំ ១៩៧៧ ឬ ដើមឆ្នាំ ១៩៧៨[174] ដែលជាព្រឹត្តិការណ៍កើតឡើងនៅយូរក្រោយបញ្ហាដែលមានក្នុងសំណុំរឿង ០០២/០១។ម្យ៉ាងទៀត ភ័ស្តុតាងនោះ មានលក្ខណៈមិនគ្រប់គ្រាន់។ ដូចអ្វីដែល នួន ជា បានទទួលស្គាល់ ឡូត សួយ មិនបានផ្តល់ភ័ស្តុតាងអ្វីពាក់ព័ន្ធនឹងភាពមិនស្មោះត្រង់ពិតប្រាកដរបស់មេដឹកនាំភូមិភាគពាយ័ព្យនោះទេ។ ផ្ទុយទៅវិញ គាត់ផ្តល់ភ័ស្តុតាងដែលបញ្ជាក់ថា ពួកគេត្រូវបាន"ចោទថា'ក្បត់' និង 'មិនស្មោះត្រង់'"[175]។ ការណ៍ដែល នួន ជា ខកខានក្នុងការវែកញែកអំពីភាព

---

[172] ឯកសារ **E3/8991** សម្ភាសន៍របស់សាក្សីលេខ ៧ របស់ DC-Cam ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រលេខ ENG 00969909។

[173] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១០៧-១០៩។

[174] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១០៨។

[175] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១០៨ (មានគូសបញ្ជាក់បន្ថែម)។

ខុសគ្នារវាងការចោទថាមិនស្មោះត្រង់ និងការមិនស្មោះត្រង់មែនទែន គឺធ្វើឱ្យសំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងរបស់ នួន ជា មានភាពមិនច្បាស់លាស់។ តាមពិត ឡុត សួយ នៅក្នុងប្រតិចារឹកដែល នួន ជា ស្នើសុំឱ្យទទួលយកនោះ និយាយថា គាត់មិនដឹងអំពីមូលដ្ឋានត្រឹមត្រូវណាមួយនៃការចោទថាក្បត់ ពីសំណាក់ពួកភូមិភាគនិរតី ដោយលើកឡើងថា "ពួកគេចោទតាវ៉ាល់ថាក្បត់។ តាមការពិត ការចោទនេះគឺចោទទៅលើក្រុមទាំងមូល គឺទៅលើក្រុមពាយ័ព្យទាំងមូល។ ខ្ញុំមិនយល់ថាតើពួកគេចង់បានន័យថាយ៉ាងម៉េចដែរ នៅពេលពួកគេចោទពួកយើងថាក្បត់ដូច្នេះ។ ចំពោះខ្ញុំ នៅពេលនោះ ខ្ញុំមិនយល់ការចោទនេះទេ។ ខ្ញុំមិនយល់គោលនយោបាយរបស់ក្រុមនិរតីនេះទេ"[176]។ ឡុត សួយ បានឆ្លើយទៀតថា "ខ្ញុំមិនដឹងមូលហេតុអ្វី បានជាក្រុមនិរតីចោទដូច្នេះ"[177]។

81. លើសពីនេះទៅទៀត ភ័ស្តុតាងរបស់ ឡុត សួយ សូម្បីតែមើលពីខាងក្រៅ ក៏អាចឃើញមិនដូចពីអ្វីដែល នួន ជា អះអាងនោះដែរ។ នួន ជា ចង់អះអាងថា ចម្លើយរបស់ ឡុត សួយ ពាក់ព័ន្ធនឹងទាហានដែលចូលព្រៃ គឺទៅដើម្បីត្រៀមធ្វើការបះបោរ[178]។ ប៉ុន្តែ ភ័ស្តុតាងពិតប្រាកដរបស់ ឡុត សួយ បញ្ជាក់ថា ទាហានដែលចូលព្រៃ គឺទៅដោយសារតែមានប្រតិកម្មទៅនឹងការចាប់ខ្លួន និង សម្លាប់មនុស្សពីសំណាក់ពួកភូមិភាគនិរតី មិនមែនដោយសារការបះបោរដែលត្រូវបានបង្ក្រាបដោយពួកភូមិភាគនិរតីនោះទេ...។ នៅពេលការចាប់ខ្លួននៅភូមិភាគបូព៌ាចាប់ផ្តើម តាញឹម យល់សភាពការណ៍ ហេតុដូច្នេះហើយទើបគាត់ប្រាប់ តាហ៊ីង ឱ្យកេណ្ឌទ័ព និងរត់ចូលព្រៃ"[179]។ នៅក្នុងសក្ខីកម្មរបស់គាត់ ឡុត សួយ បញ្ជាក់ជាថ្មីយ៉ាងច្បាស់លាស់ថា ការរត់ខ្លួនចូលព្រៃនេះ គឺធ្វើឡើងដោយសារប្រតិកម្មទៅនឹងការបោសសម្អាត និងជាការប៉ុនប៉ងគេចពីការចាប់ខ្លួន។ គាត់បញ្ជាក់ថា "ពេលដែលចាប់ខ្លួនពួក តាវ៉ាល់ ពួកខ្ញុំអ្នកក្រោមនេះ ក៏នាំគ្នាភ័យ ហើយពិគ្រោះគ្នានឹងរត់ចូលព្រៃ ព្រោះគេចាប់បាន គេយកទៅសម្លាប់

---

[176] ឯកសារ **E1/329.1** ប្រតិចារិក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ត្រង់នាទី 14.15.35។

[177] ឯកសារ **E1/329.1** ប្រតិចារិក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ត្រង់នាទី 14.17.21។

[178] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១០៨-១០៩។

[179] ឯកសារ **E3/9060** សម្ភាសន៍ ឡុត សួយ របស់ DC-Cam ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ត្រង់ទំព័រលេខ ENG 00728739។

ចោល។ បានពួកខ្ញុំប្រុងប្រយ័ត្នខ្លួនមិនឲ្យគេហៅបាន”[180]។ ដើម្បីបញ្ជាក់ឲ្យអស់មន្ទិល ឡូត សួយ បំភ្លឺថា “ខ្ញុំមិនដែលបាននិយាយអ្វីអំពីការបង្កើតចលនាបះបោរនេះទេ”[181]។

82. នួន ជា បំភាន់អង្គជំនុំជម្រះ នៅពេលគាត់លើកឡើងថា ភ័ស្តុតាងរបស់ ឡូត សួយ ថាមេដឹកនាំភូមិភាគពាយ័ព្យត្រូវបានចាប់ខ្លួនដោយកម្មាភិបាលភូមិភាគនិរតី ដោយសារពួកគេ “ត្រូវបានចោទថា ‘ក្បត់’ និង ‘មិនស្មោះត្រង់’ មានដូចជាពួកគេបានបោះពុម្ពក្រដាសប្រាក់ និងបើកប្រាក់ខែ[182]”។ ឡូត សួយ បដិសេធជាពិសេស ក្នុងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជារបស់គាត់ ថាការបោះពុម្ពក្រដាសប្រាក់នោះ គឺជាមូលហេតុដែលនាំឲ្យចាប់ខ្លួន រស់ ញឹម។ ផ្ទុយទៅវិញ គាត់យោងចំណុចនេះទៅនឹងការសម្លាប់អ្នកការទូតចិនម្នាក់នៅភូមិភាគបូព៌ា៖

> [មជ្ឈមណ្ឌលឯកសារកម្ពុជា]៖ ដូច្នេះ តើការចាប់ខ្លួន រស់ ញឹម ជាប់ពាក់ព័ន្ធនឹងការបោះពុម្ពក្រដាសប្រាក់មែនឬទេ?
>
> [ឡូត សួយ]៖ អត់ទេ។
>
> [មជ្ឈមណ្ឌលឯកសារកម្ពុជា]៖ តើមូលហេតុនៃការចាប់ខ្លួននេះ ពាក់ព័ន្ធនឹងការបាញ់សម្លាប់អ្នកការទូតចិនមែនឬទេ?
>
> [ឡូត សួយ]៖ បាទមែន[183]។

83. ដូចគ្នានេះដែរ នួន ជា បំភាន់អង្គជំនុំជម្រះ ដោយលើកឡើងថា ឡូត សួយ ឆ្លើយថា “ក្រុមគាត់បានលាក់អាវុធក្នុងព្រៃភ្នំកូនខ្លែង”[184]។ តាមពិត ឡូត សួយ បានពន្យល់យ៉ាងច្បាស់លាស់ ពេលឆ្លើយទៅនឹងសំណួរពីមេធាវីការពារក្តីរបស់ នួន ជា ខ្លួនឯង នៅក្នុងសក្ខីកម្មរបស់គាត់ថា គ្មានអាវុធយកមក

---

[180] ឯកសារ **E1/329.1** ប្រតិចារិក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ត្រង់នាទី 13.44.10។

[181] ឯកសារ **E1/329.1** ប្រតិចារិក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ត្រង់នាទី 114.24.55។

[182] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១០៨។

[183] ឯកសារ **E3/9060** សម្ភាសន៍ ឡូត សួយ របស់ DC-Cam ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ត្រង់ទំព័រលេខ ENG 00728746។

[184] ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១០៩។

លាក់ទុកក្នុងព្រៃទេ និងអ្វីដែលគាត់និយាយនោះគឺថា ទាហានរត់ចូលព្រៃ ដោយយកកាំភ្លើងទៅតាមខ្លួន៖

> [មេធាវីការពារក្តី នួន ជា]៖ ... តើអ្នកមានចាំឬទេអាវុធប្រភេទអ្វីខ្លះ លាក់ទុកក្នុងព្រៃនោះ?
>
> [ឡុត ស្វយ]៖ ... អត់បានដឹកកប់កាំភ្លើងទេ។ ប៉ុន្តែ គេត្រៀមកម្លាំងទុកនៅក្នុងព្រៃ ដូច្នេះគេទុកអាវុធទាំងនោះក្នុងព្រៃ។ ពេលយើងនិយាយអំពីការលាក់អាវុធ យើងចង់និយាយសំដៅថា ពួកគេលាក់ខ្លួនក្នុងព្រៃ ដោយមានអាវុធនៅជាមួយផង[185]។

84. សក្ខីកម្មរបស់ ឡុត ស្វយ នៅក្នុងអង្គជំនុំជម្រះសាលាដំបូង ផ្ទុយនឹងការលើកឡើងរបស់ នួន ជា ក្នុងចំណុចជាច្រើនផ្សេងទៀត នៅចំពោះមុខអង្គជំនុំជម្រះនេះផងដែរ។ នួន ជា លើកឡើងថា ឡុត ស្វយ ឆ្លើយថា ពួកភូមិភាគពាយ័ព្យបោះពុម្ពក្រដាសប្រាក់ ប៉ុន្តែ ឡុត ស្វយ ឆ្លើយបញ្ជាក់ថា ក្រដាសប្រាក់ដែលគាត់ឃើញ "ត្រូវបានបោះពុម្ពនៅភ្នំពេញ"[186]។ នួន ជា លើកឡើងថា ឡុត ស្វយ ឆ្លើយថា គេបង្ហាញក្រដាសប្រាក់ឲ្យគាត់ឃើញដំបូងនៅ "ចុងឆ្នាំ ១៩៧៧"[187] ប៉ុន្តែ បែរជាមិនបានលើកឡើងផងថា នៅក្នុងប្រតិចារឹកដដែលនោះ ឡុត ស្វយ ឆ្លើយថា គាត់បានឃើញក្រដាសប្រាក់នេះ "នៅប្រហែលពីរខែមុនវៀតណាមចូល"[188] និងថា នៅពេលគាត់ឃើញក្រដាសប្រាក់នោះ "ពួកពាយ័ព្យត្រូវបានចាប់ខ្លួនដោយពួកនិរតីអស់ហើយ និងរឿងក្រដាសប្រាក់នោះត្រូវពួកនិរតីជាអ្នកចាត់ចែង"[189]។ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងម្នាក់បានសួរឲ្យ ឡុត ស្វយ ឆ្លើយបំភ្លឺចម្លើយខាងក្រោម៖

> [អង្គជំនុំជម្រះសាលាដំបូង]៖ ... លោកចង់និយាយថា កម្មាភិបាលភូមិភាគនិរតីហ្នឹងជាអ្នករៀបចំចែកចាយចរាចរលុយ នៅភូមិភាគពាយ័ព្យហ្នឹង ឬ ក៏យ៉ាងម៉េច?

---

185 ឯកសារ **E1/329.1** ប្រតិចារឹក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ត្រង់នាទី 13.52.00។ *សូមមើលផងដែរ* ឯកសារ **E1/330.1** ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ត្រង់នាទី 09.15.08 ("ទឹកដីត្រពាំងថ្មនោះគឺអត់បានធ្វើឃ្លាំងកាំភ្លើងអីទេ គ្រាន់តែកងតំបន់គេដឹកអាវុធ គេមក គេត្រៀមចាំ។ គេត្រៀមកម្លាំអទុកនៅក្នុងព្រៃ គឺអាវុធទាំងអស់នោះ គឺអត់បានដឹកកប់ទេ")។

186 ឯកសារ **E1/329.1** ប្រតិចារឹក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ត្រង់ទំព័រលេខ ENG 01131074។

187 ឯកសារ **F2/8** សំណើលើកទី ៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១០៨។

188 ឯកសារ **E1/329.1** ប្រតិចារឹក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ត្រង់នាទី 10.58.24។

189 ឯកសារ **E1/329.1** ប្រតិចារឹក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ត្រង់នាទី 11.00.50។

[ឡុត សួយ]៖ អាហ្នឹងខ្ញុំដឹងអត់ដល់ដែរ ប៉ុន្តែ ខ្ញុំឮតែគ្នាខ្ញុំនិយាយ គេថាលុយនេះបានមកពីបង។ ខ្ញុំសូមបញ្ជាក់ថា ពេលនោះគឺភូមិភាគពាយ័ព្យអត់មានអ្នកណានៅទេ គេចាប់អស់ហើយ។ មានតែភូមិភាគនិរតីដែលនៅឈរជើងនៅនោះ[190]។

85. ទន្ទឹមនឹងនេះ នួន ជា មិនបានជូនដំណឹងអង្គជំនុំជម្រះនេះថា ឡុត សួយ បានផ្តល់សក្ខីកម្មពីរថ្ងៃផ្សេងទៀត បន្ថែមលើថ្ងៃដែលមានប្រតិចារឹកដែល នួន ជា សុំឱ្យអង្គជំនុំជម្រះទទួលយកលើបណ្តឹងសាទុក្ខ។ បន្ទាប់ពីពិនិត្យមើលប្រតិចារឹកទាំងអស់នោះ យើងឃើញកាន់តែច្បាស់ថា នួន ជា មិនចង់ឱ្យអង្គជំនុំជម្រះនេះយកវាមកពិចារណាទេ។ សក្ខីកម្មរបស់ ឡុត សួយ កាលពីថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥ ផ្តល់នូវផ្នែកតែមួយគត់នៃភស្តុតាងរបស់គាត់ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ និង ដែលគាំទ្រដល់ការអនុវត្តគោលនយោបាយខ្មែរក្រហម ចំពោះការកំណត់គោលដៅអតីតទាហាន និង អ្នករដ្ឋការនៃរបប លន់ នល់ នៅភូមិភាគពាយ័ព្យ។ នៅក្នុងប្រតិចារឹក ឡុត សួយ បញ្ជាក់ថា "នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ជាថ្ងៃរំដោះ បានមកនេះ គឺវាបានចូលក្នុងភូមិឃុំ ក៏បានចម្រាញ់អ្នកណាដែលមានបងប្អូនទាហាន ក៏វាចាប់យកទៅសម្លាប់ចោលអស់"[191]។

86. ជាមួយគ្នានេះដែរ សក្ខីកម្មរបស់ ឡុត សួយ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ដែលមិនត្រូវបាន នួន ជា លើកយកមកជម្រាបអង្គជំនុំជម្រះនេះដែរនោះ រៀបរាប់ថា ពាក់ព័ន្ធនឹងទាហាននៅក្នុងព្រៃដែល នួន ជា បានលើកឡើងនៅក្នុងសក្ខីកម្មរបស់ ឡុត សួយ គាត់មិនដែលបានឃើញពួកគេទេ កាលពីពេលពួកគេនៅក្នុងព្រៃនោះ ដោយសារ "គេមិនអនុញ្ញាតឱ្យយើងចេញចូលកន្លែងគេទេ"[192]។

87. នួន ជា មិនបានជម្រាបឱ្យអង្គជំនុំជម្រះនេះបានដឹងផងទេថា កំណត់ស្តាប់ចម្លើយសាក្សីដែលបានពី ឡុត សួយ មាននៅក្នុងសំណុំរឿង ០០២ តាំងពីខែ មីនា ឆ្នាំ ២០១៥ មកម្ល៉េះ[193]។ នួន ជា បានដឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីរូបនេះយ៉ាងច្បាស់ ដោយសារកំណត់ហេតុនេះ កាលនៅក្នុងអំឡុង

---

[190] ឯកសារ **E1/329.1** ប្រតិចារឹក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ត្រង់នាទី 11.00.50 (មានគូសបញ្ជាក់បន្ថែម)។

[191] ឯកសារ **E1/328.1** ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥ ត្រង់នាទី 13.47.52។ *សូមមើលផងដែរ* ដូចខាងលើ ត្រង់នាទី 14.28.50 ("ឈយនេះជាកងចល័តភូមិ បានគេដកមកនៅកងចល័តតំបន់នោះ ព្រោះគាត់មានជាប់ខ្សែបណ្តាញអតីតទាហាន លន់ នល់ បានគេតាមដានគាត់ ចាប់គាត់យកទៅ")។

[192] ឯកសារ **E1/330.1** ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ត្រង់នាទី 09.10.23។

[193] ឯកសារ **E319/19.3.20** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡុត សួយ។

ពេលធ្វើសវនាការ បានយោងទៅនឹងសក្ខីកម្មរបស់ ឡុត សួយ ដែល នួន ជា ជាអ្នកស្នើសុំឱ្យទទួលយកនៅទីនេះ[194] ដែលមេធាវីការពារក្តីរបស់ នួន ជា ខ្លួនឯងផ្ទាល់ជាអ្នកដាក់បញ្ចូល[195]។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡុត សួយ ផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដោយសារភាពពាក់ព័ន្ធរបស់វាទៅនឹងការអនុវត្តគោលនយោបាយខ្មែរក្រហម ដែលកំណត់យកអតីតទាហាន និងអ្នករដ្ឋការនៃរបប លន់ នល់ ជាគោលដៅ នៅក្នុងភូមិភាគិពាយ័ព្យ ដែលគាត់ផ្តល់ភ័ស្តុតាងថា "នៅពេលដែលពួកខ្មែរក្រហមចូលមកដល់ភូមិភ្លាម ពួកគេបានចាប់មេឃុំ ជំទប់ និងអ្នកពាក់ព័ន្ធនឹងទាហាន លន់ នល់ ឬរដ្ឋការ លន់ នល់ យកទៅសម្លាប់"[196]។

88. នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី ឡុត សួយ គាត់បានពន្យល់ផងដែរថា គាត់ "មិនដឹងអំពីមូលហេតុច្បាស់លាស់ទេ"[197] ពាក់ព័ន្ធនឹងថាតើ "ហេតុអ្វីបានជាពួកកម្មាភិបាលនិរតី ចាប់ពួកពាយ័ព្យអស់ ហើយដាក់កម្មាភិបាលនិរតីមកជំនួសវិញ"។

### ៤. ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជារបស់សាក្សី 2-TCW-918

89. នួន ជា ស្នើសុំឱ្យទទួលយកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជារបស់សាក្សី 2-TCW-918[198]។ សហព្រះរាអាជ្ញាសូមជំទាស់នឹងសំណើនេះ។ ដូចបានជម្រាបជូនខាងលើ ឯកសាររបស់មជ្ឈមណ្ឌលកម្ពុជានេះ អាចរកបាននៅក្នុងអំឡុងពេលជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ដោយសារឯកសារនេះត្រូវបានដាក់នៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១១។ ប៉ុន្តែ នួន ជា មិនបានស្នើសុំឱ្យទទួលយកវានៅក្នុងពេលជំនុំជម្រះនោះទេ ឬក៏មិនស្នើសុំឱ្យទទួលយកវាក្នុងពេលណាមួយ ក្នុងរយៈពេលជាងបួនឆ្នាំចាប់ពីឯកសារនោះមានក្នុងសំណុំរឿង។

---

[194] *សូមមើល ឧទាហរណ៍* ឯកសារ **E1/329.1** ប្រតិចារឹក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ត្រង់នាទី 09.17.07។

[195] *សូមមើល ឧទាហរណ៍* ឯកសារ **E1/329.1** ប្រតិចារឹក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ត្រង់នាទី 11.14.05។

[196] ឯកសារ **E319/19.3.20** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡុត សួយ ត្រង់ចម្លើយទី ១០។

[197] ឯកសារ **E319/19.3.20** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡុត សួយ ត្រង់ចម្លើយទី ៩០។

[198] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១១០-១១២។

90. សូម្បីតែតាមសម្ដី នួន ជា ភស្តុតាងរបស់សាក្សីរូបនេះ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនេះរួច ហើយ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដែលចាប់កើតឡើងនៅចុងឆ្នាំ ១៩៧៦[199] ពោលគឺនៅយ៉ាងយូរក្រោយ ការផ្លាស់ទីលំនៅដោយបង្ខំចេញពីភ្នំពេញ និងការផ្លាស់ទីលំនៅដោយបង្ខំពីភូមិភាគទៅភូមិភាគ។ ព្រឹត្តិការណ៍កើតឡើងជាងមួយឆ្នាំ ក្រោយមានការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។ មិនតែប៉ុណ្ណោះ សក្ខីកម្មរបស់សាក្សីនេះ តាមពិតមិនគាំទ្រជំហរការពារក្ដីរបស់មេធាវីការពារក្ដី នួន ជា នោះទេ។ នួន ជា រៀបរាប់ និងដកស្រង់សក្ខីកម្មរបស់សាក្សីនេះ នៅក្នុងសំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាង បន្ថែមថា គាត់"មានពេលមួយ តាហ៊ីង និង តាវ៉ាល់ ប្រាប់គាត់អំពីគម្រោងការក្បត់ក្នុងការបំពាក់អាវុធ ដល់'កងចល័តទាំងអស់' នៅពេលដែលពួកគាត់ទៅកាប់ដើមកប្បាសនៅភ្នំកងវ៉ា ដាំដើមកប្បាស និងរត់ទៅ'ប្រទេសថៃ'"[200]។ ប៉ុន្តែ នួន ជា ចង់បំភាន់អង្គជំនុំជម្រះ ដោយមិនបានលើកឡើងអំពីចំណុច ដែលថា"សកម្មភាពក្បត់"នឹងខ្មែរក្រហមនេះ ត្រូវបានបង្ក្រាបដោយបុគ្គលម្នាក់ គ្មាននរណាក្រៅពីអ្នក ដែល នួន ជា ខ្លួនឯងអះអាងថា ជាជនក្បត់ម្នាក់ប្រឆាំងពួកខ្មែរក្រហម ដែលរួមមាន រស់ ញឹម និង កូនប្រុស រស់ ញឹម ឈ្មោះតាជាល។ នៅជាប់ក្រោយសម្ដីដែល នួន ជា ដកស្រង់នៅក្នុងសំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែមនោះ សាក្សីបន្តទៀតថា៖

> [2-TCW-918]៖ ... នៅពេល មូល សម្បត្តិ ហៅ តាញឹម និង តាជាល ដឹងផែនការនោះ ពួកគេមើលរម្លងពួកយើង។ ពួកទាំងនេះចង់ចាប់តាវ៉ាល់។
>
> [DC-Cam]៖ អូ! ពិតមែន?
>
> [2-TCW-918]៖ បាទពិតមែន។ មិនមែនកម្មាភិបាលនិរតីទេ។
>
> [DC-Cam]៖ មិនមែនកម្មាភិបាលនិរតីទេ?

---

[199] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១១១។

[200] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១១១ ដកស្រង់ ឯកសារ E3/9094 សម្ភាសន៍ សាក្សី [2-TCW-918] របស់ DC-Cam ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១១ ត្រង់ទំព័រលេខ ENG 00728683។

[2-TCW-918]៖ មិនមែនទេ គឺក្រុមគ្នាឯងហ្នឹងឯង[201]។

91. ក្រោយមកទៀត សាក្សី 2-TCW-918 ត្រូវបានសួរសំណួរអំពីការចាប់តាវ៉ាល់៖

[DC-Cam]៖ ដូច្នេះ អ្នកដែលមកចាប់តាវ៉ាល់ហ្នឹង មកពីក្រុមតាជាល ដែលមានតាញឹម មូល សម្បត្តិ មែនឬទេ?

[2-TCW-918]៖ បាទមែន។ មិនមែនមនុស្សខាងនិរតីទេ។ ប្រហែលពួកនិរតីមកជួយមិនទាន់[202]។

ដូច្នេះ ភ័ស្តុតាងរបស់សាក្សីរូបនេះ ចង់បញ្ជាក់ថា រស់ ញឹម នៅបន្តស្មោះស្ម័គ្របម្រើមជ្ឈិម ដោយស្មោះស្ម័គ្រក្នុងបង្ក្រាបអ្នកណាដែលហ៊ានប្រឆាំងខ្មែរក្រហម ដែលជាព្រឹត្តិការណ៍កើតឡើងយូរក្រោយព្រឹត្តិការណ៍ដែលជាកម្មវត្ថុក្នុងសំណុំរឿង ០០២/០១ នេះទៅទៀត។

92. ដូចគ្នានេះដែរ នួន ជា បំភាន់អង្គជំនុំជម្រះទៀត ពាក់ព័ន្ធនឹងចំណុចផ្សេងមួយទៀត ក្នុងការដែលគាត់ចង់សុំឱ្យទទួលយកឯកសារចម្លើយរបស់សាក្សី ដែលជាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានេះ។ នួន ជា ដកស្រង់សម្តីពីចម្លើយសាក្សីនេះ ពីក្នុងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងអះអាងថា សាក្សីនេះ“បានរៀបរាប់អំពីព្រឹត្តិការណ៍ដែលបានកើតឡើងចំពោះ សោ ភឹម រស់ ញឹម និង ហេង សំរិន នៅពេលវៀតណាមចូល”[203]។ ទោះជាយ៉ាងនេះក្តី ការយោងទៅរកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បញ្ជាក់ឱ្យឃើញច្បាស់ថា សាក្សីរៀបរាប់អំពីអ្វីដែលគាត់ឮពីកម្មាភិបាល

---

[201] ឯកសារ **E3/9094** សម្ភាសន៍សាក្សី [2-TCW-918] របស់ DC-Cam ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១១ ត្រង់ទំព័រលេខ ENG 00728683។

[202] ឯកសារ **E3/9094** សម្ភាសន៍សាក្សី [2-TCW-918] របស់ DC-Cam ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១១ ត្រង់ទំព័រលេខ ENG 00728686។

[203] ឯកសារ **F2/8** សំណើលើកទី ៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ ១១២។

ភូមិភាគនិរតី នៅក្នុងកិច្ចប្រជុំដែលដឹកនាំដោយកម្មាភិបាលភូមិភាគនិរតីឈ្មោះតារិន និង យាយជឹម បន្ទាប់ពីការបោសសម្អាតពួកភូមិភាគពាយ័ព្យរួចមក"[204]។

93. ជាថ្មីម្តងទៀត នួន ជា មិនបានជម្រាបអង្គជំនុំជម្រះនេះ ឲ្យបានជ្រាបអំពីចម្លើយបន្ថែមបីទៀតពីសាក្សីដដែលរូបនេះនោះទេ។ ឯកសារចម្លើយទាំងអស់នោះសុទ្ធតែមាននៅក្នុងសំណុំរឿង[205]។ ក្នុងឯកសារទាំងនេះ 2-TCW-918 បញ្ជាក់ជាច្រើនលើកថា បើតាមគាត់ដឹង "បញ្ជាឲ្យចាប់តា វ៉ាល់ គឺចេញពីតាញឹម" [206]។

### *iv. ឯកសារពីរដ្ឋាភិបាលបរទេស*

94. នួន ជា បានស្នើសុំឲ្យទទួលយកប្រវត្តិរូបចំនួនបួន[207]។ គាត់បានអះអាងថា ប្រវត្តិរូបទាំងអស់នេះ ត្រូវបានដកស្រង់ចេញពី "សំណុំឯកសារផ្លូវការជាសាធារណៈ នៃសេវាសន្តិសុខជាតិ របស់អតីតសាធារណៈប្រជាធិបតេយ្យអាល្លឺម៉ង់" ("ប្រវត្តិរូប Stasi")[208]។ សហព្រះរាជអាជ្ញាជំទាស់ទៅនឹងសំណើទាំងបួន។

95. សំណើរបស់នួន ជា សុំឲ្យទទួលយកប្រវត្តិរូប Stasi មានបញ្ហាច្រើន។ សំណើបានបង្ហាញពីកង្វះការប្រុងប្រយ័ត្នខ្ពស់ និងការគោរពតាមពេលវេលា ការជឿទុកចិត្តមិនច្បាស់លាស់ ហើយមិនអាចបំពេញ

---

[204] ឯកសារ **E3/9094** សម្ភាសន៍សាក្សី [2-TCW-918] របស់ DC-Cam ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១១ ត្រង់ទំព័រលេខ ENG 00728699។

[205] ឯកសារ **E319/12.3.11** កំណត់ហេតុស្តាប់ចម្លើយសាក្សី [2-TCW-918]។ ឯកសារ **E319/19.3.58** កំណត់ហេតុស្តាប់ចម្លើយសាក្សី [2-TCW-918]។ ឯកសារ **E319/19.3.17** កំណត់ហេតុស្តាប់ចម្លើយសាក្សី [2-TCW-918]។

[206] ឯកសារ **E319/12.3.11** កំណត់ហេតុស្តាប់ចម្លើយសាក្សី [2-TCW-918] ត្រង់ចម្លើយទី ៤។ *សូមមើលផងដែរ* ដូចខាងលើ ត្រង់ចម្លើយទី ២៣។

[207] ឯកសារ ឯកសារ F2/8 សំណើលើកទី៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម, កថាខណ្ឌ ១១៤ ដល់១១៧ ("ប្រវត្តិរូបរបស់ អ៊ុក ប៊ុនឈឿន", "ប្រវត្តិរូបរបស់ ហេង សំរិន", "ប្រវត្តិរូបរបស់ ហ៊ុន សែន", "ប្រវត្តិរូបរបស់ ប៉ែន សុវណ្ណ")។

[208] ឯកសារ **E307/5.2.8** 'កម្រងប្រវត្តិរូបសង្ខេបចំនួន ២១ (Kurzbiographies) ដែលធ្វើឡើងដោយក្រសួងសន្តិសុខរដ្ឋ នៃសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់។

បានទាល់តែសោះ នូវលក្ខណៈវិនិច្ឆ័យសំខាន់សម្រាប់ការទទួលយកភស្តុតាងថ្មី នៅដំណាក់កាលបណ្តឹងសាទុក្ខ។

96. សំណើរបស់នួន ជា សុំឲ្យទទួលយកប្រវត្តិរូប Stasi មានភាពយឺតយ៉ាវ យោងតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង។ បើតាមពាក្យសម្តីរបស់ នួន ជា ផ្ទាល់ គាត់ទទួលបានឯកសារទាំងអស់នេះ នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤[209]។ បន្ទាប់មកគាត់ព្យាយាមស្នើសុំឲ្យទទួលយក ធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ ២០១៤[210] ដែលនៅពេលនោះគាត់បានដឹងឮគ្រប់គ្រាន់អំពីខ្លឹមសារនៃឯកសារ ដោយសារគាត់អាចផ្តល់សេចក្តីសង្ខេបនៃឯកសារទាំងនោះ ហើយនឹងបានចង្អុលបង្ហាញផ្នែកនៃដីកាដំណោះស្រាយ ដែលគាត់បានអះអាងថា មានភាពពាក់ព័ន្ធជាមួយឯកសារទាំងនោះ[211]។ នួន ជា មានពេលវេលាសមស្រប ហើយមានឱកាសច្រើនក្នុងការស្នើសុំឲ្យទទួលយកឯកសារទាំងអស់នេះ គឺចាប់តាំងពីខែ កក្កដា ឆ្នាំ ២០១៤ ហើយនៅមុនពេលមានសំណើបច្ចុប្បន្ននេះ នួន ជា បានដាក់សំណើចំនួនប្រាំ ដើម្បីស្នើសុំឲ្យទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែម។

97. បន្ថែមលើនេះ បើយោងតាមនួន ជា ឯកសារទាំងនេះ "អាចរកបានជាសាធារណៈ"[212] ហើយ "ដែលជាធម្មតា សាធារណជនអាចរកមើលបាន នៅមុនការបញ្ចប់ការជំនុំជម្រះ"[213] ប៉ុន្តែ នួន ជា មិនបានព្យាយាមស្នើសុំដាក់ឯកសារទាំងនេះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ទេ។ ដោយសារតែឯកសារទាំងអស់នេះ មិនបានបំពេញតាមលក្ខខណ្ឌតម្រូវ នៃវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ដែលថាឯកសារចាំបាច់ត្រូវតែមិនអាចរកបាននៅពេលជំនុំជម្រះ បើទោះបីជាមានការប្រឹងប្រែងខ្លាំងក៏ដោយ។ ការព្យាយាមស្នើសុំឲ្យទទួលឯកសារទាំងអស់នេះ តែនៅដំណាក់កាលបណ្តឹង

---

[209] ឯកសារ F2/8 សំណើលើកទី៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម, នៅត្រង់ កថាខណ្ឌ ១១៣។

[210] ឯកសារ **E307/5** បញ្ជីឯកសារផ្ទៃក្នុង សម្រាប់សំណុំរឿង ០០២/០២, ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤។

[211] ឯកសារ **E307/5.2** បញ្ជីឯកសារផ្ទៃក្នុង សម្រាប់សំណុំរឿង ០០២/០២, ឧបសម្ព័ន្ធ ក, ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤, លេខចូល ៨។

[212] ឯកសារ F2/8 សំណើលើកទី៦ សុំឲ្យទទួលយកភស្តុតាងបន្ថែម, ត្រង់ កថាខណ្ឌ ១១៣។

[213] ឯកសារ **F2/8** សំណើលើកទី៦របស់ នួន ជា ស្នើសុំឲ្យមានការពិចារណា និងទទួលយកភស្តុតាងបន្ថែមទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១, ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥, កថាខណ្ឌ ១៥៩។

សាទុក្ខ បើទោះបីជាឯកសារទាំងនោះអាចរកបាន នៅដំណាក់កាលជំនុំជម្រះក៏ដោយ គឺជាឧទាហរណ៍គម្រូនៃ "យុទ្ធសាស្ត្របណ្តឹងអប្រសិទ្ធភាព និងរំខាន" ដែលអង្គជំនុំជម្រះនេះបានសម្រេចថា ខ្លួននឹងមិនអនុញ្ញាតឡើយ[214]។ សម្រាប់សំអាងហេតុទាំងអស់នេះ ផលប្រយោជន៍យុត្តិធម៌មិនតម្រូវឱ្យទទួលយកឯកសារទាំងអស់នេះតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងឡើយ ហើយតាមពិតទៅផលប្រយោជន៍យុត្តិធម៌ តម្រូវឱ្យបដិសេធចោលឯកសារទាំងនេះទៅវិញទេ។

98. បន្ថែមលើនេះ ឯកសារទាំងអស់នេះមិនមានលក្ខណៈសមស្រប ដើម្បីបង្ហាញពីការពិត ដែលឯកសារត្រូវបង្ហាញតាមវិធាន ៨៧(៣)(គ) នៃវិធានផ្ទៃក្នុងឡើយ។ ដោយសារតែឯកសារទាំងនេះមិនសមស្រប សម្រាប់ការបង្ហាញការពិតដែលត្រូវបង្ហាញ ឬក៏គួរត្រូវបានផ្តល់ឱ្យនូវទម្ងន់តិចតួច ហើយដោយសារតែខ្លឹមសាររបស់ឯកសារទាំងនេះ (ដោយផ្អែកលើសេចក្តីសង្ខេបរបស់ នួន ជា) មិនបាននិយាយដល់ការសម្រេចលើអង្គហេតុជាក់លាក់ណាមួយ របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារទាំងនេះជារួម ឬតែឯង នឹងមិនអាចក្លាយជាកត្តាសម្រេច ក្នុងការឈានទៅដល់ការសម្រេចលើបណ្តឹងសាទុក្ខតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ហើយផលប្រយោជន៍យុត្តិធម៌ក៏មិនតម្រូវឱ្យទទួលយកឯកសារនេះតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងដែរ។

99. ទីមួយ នួន ជា មិនបានអនុវត្តបន្ទុកការងាររបស់គាត់ ក្នុងការបង្ហាញថាឯកសារទាំងនេះ អាចជឿជាក់បាន និងមានយថាភាពនៅកម្រិតបឋម[215]។ ពាក់ព័ន្ធទៅនឹងប្រភពដើមនៃឯកសារទាំងនេះ នួន ជា បានអះអាងថាឯកសារទាំងនេះត្រូវបាន "ដកស្រង់ចេញពីសំណុំឯកសារផ្លូវការជាសាធារណៈ នៃសេវាសន្តិសុខជាតិ របស់អតីតសាធារណៈប្រជាធិបតេយ្យអាល្លឺម៉ង់"[216] ប៉ុន្តែមិនបានផ្តល់ការពណ៌នាណាមួយអំពីថាតើគាត់ទទួលបានឯកសារទាំងនេះដោយរបៀបណា។ ប៉ុន្តែគាត់បានបញ្ជាក់ថា មេធាវីរបស់គាត់ មិនបានចូលរួមផ្ទាល់ក្នុងការទទួលយកឯកសារទាំងអស់នេះពី "សំណុំឯកសារផ្លូវការជា

---

214 ឯកសារ **F2/5** សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំកោះហៅសាក្សីសម្រាប់បណ្តឹងសាទុក្ខ, ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥, កថាខណ្ឌ ១៦។

215 *សូមមើលជាឧទាហរណ៍* ឯកសារ **E333** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង៖ អង្គជំនុំជម្រះសាលាដំបូងដាក់ឯកសារថ្មីទៅក្នុងសំណុំរឿងតាមគំនិតផ្តួចផ្តើមរបស់ខ្លួន, ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៥, កថាខណ្ឌ ២ (វិធាន ៨៧(៣) ដែលគ្របដណ្តប់លើបទដ្ឋាននៃភាពពាក់ព័ន្ធដំបូង ភាពអាចជឿទុកចិត្តបាន និងយថាភាព)។

216 ឯកសារ F2/8 សំណើលើកទី៦ សុំឱ្យទទួលយកភស្តុតាងបន្ថែម, ត្រង់ កថាខណ្ឌ ១១៣។

សាធារណៈ” ឡើយ ដោយគាត់គ្រាន់តែបានបញ្ជាក់ថា “ឯកសារទាំងនេះត្រូវបានផ្តល់ឱ្យមកមេធាវីការពារក្តីនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤”[217]។ គាត់សម្រេចមិនបង្ហាញថានរណាជាអ្នកផ្តល់ឯកសារទាំងនេះមកគាត់ ហើយក៏មិនបង្ហាញថា តើបុគ្គលម្នាក់នោះទទួលបានឯកសារទាំងនេះដោយរបៀបណាឡើយ។ គាត់ក៏មិនបានដឹងថាតើ ឯកសារទាំងនេះចូលទៅក្នុងបណ្ណាសារដោយរបៀបណាដែរ ដោយគាត់ទាយស្មានថាឯកសារទាំងនេះ “ប្រហែលជាសេវាសន្តិសុខជាតិ បានទទួលពីប្រទេសវៀតណាម”[218]។

100. ទីពីរ នួន ជា ទទួលស្គាល់ថាឯកសារទាំងនេះ “គឺជាសំណៅបកប្រែជាភាសាអាល្លឺម៉ង់ ពីឯកសារទាំងឡាយដែលបានសរសេរឡើង ដំបូងជាភាសាវៀតណាម”[219]។ ប៉ុន្តែគាត់មិនបានផ្តល់ឯកសារច្បាប់ដើមជាភាសាវៀតណាម ហើយគាត់ក៏មិនបានផ្តល់ព័ត៌មានអំពីអ្នកបកប្រែឯកសារនោះពីភាសាវៀតណាមទៅជាភាសាអាល្លឺម៉ង់ (ដោយសន្មតថាឯកសារទាំងនេះត្រូវបានបកប្រែផ្ទាល់ ពីភាសាមួយទៅភាសាមួយទៀត) ព្រមទាំងមិនបានផ្តល់ព័ត៌មានអំពីគុណវុឌ្ឍិរបស់អ្នកបកប្រែឡើយ។ ដោយសារតែគាត់មិនបានផ្តល់ឯកសារជាភាសាដើម ប្រាកដជាមិនអាចធ្វើការវាយតម្លៃថាតើ ការបកប្រែទាំងនេះពិតជាឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ ពីឯកសារដើមដែរឬយ៉ាងណា[220]។

101. ទីបី នួន ជា មិនបានផ្តល់ព័ត៌មានអំពីថាតើ នរណាជាអ្នកកត់ត្រាប្រវត្តិរូបទាំងនេះ នៅក្នុងប្រទេសវៀតណាម ហើយនឹងថាតើពួកគេកត់ត្រាព័ត៌មានទាំងនេះនៅទីណា និងដោយរបៀបណា ឬថាតើដោយសារមូលហេតុអ្វី ឬក្នុងកាលៈទេសៈអ្វី ដែលគេកត់ត្រាឯកសារទាំងអស់នេះ[221]។

---

[217] ឯកសារ F2/8 សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១១៣ (គូសបញ្ជាក់បន្ថែម)។

[218] ឯកសារ F2/8 សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១១៣។

[219] ឯកសារ F2/8 សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១១៣។

[220] *រដ្ឋអាជ្ញា តទល់នឹង Bagosora និងអ្នកដទៃទៀត,* ICTR -98-41-T, អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចលើការទទួលយកកំណត់ត្រា ១៩ នៃសំណុំឯកសារដែលបង្កើតឡើង ពាក់ព័ន្ធការបង្ហាញខ្លួនរបស់សាក្សី Maxwell Nkole, ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៤, កថាខណ្ឌ ៨ (“ភាគីម្ចាស់បណ្តឹងត្រូវផ្តល់បន្ថែមទៀត នូវការបញ្ជាក់ដែលថាឯកសារមានយថាភាព គឺថាឯកសារនោះពិតជាអ្វីដែលភាគីម្ចាស់បណ្តឹងបានអះអាងដូច្នេះមែន”)។

[221] ការកត់សម្គាល់ទាំងអស់នេះ ក៏អាចអនុវត្តបានចំពោះឯកសារទាំងអស់ ដែលពាក់ព័ន្ធសំណើរបស់ នួន ជា សុំឱ្យទទួលយកទៅក្នុងសំណុំរឿង ០០២/០២។ ដោយសារមូលហេតុផ្សេងៗគ្នាជាច្រើន រួមទាំងបទដ្ឋានផ្សេងគ្នាក្នុងការទទួលយកភ័ស្តុតាង នៅពេលជំនុំ

102. ជាចុងក្រោយ ចំពោះខ្លឹមសារនៃឯកសារដែលបានផ្ដល់ឱ្យ នួន ជា បានទទួលស្គាល់ថាឯកសារទាំងនេះពុំមានជា "ភាសាការងារណាមួយនៅ អ.វ.ត.ក" សម្រាប់ភាគី និងសម្រាប់អង្គជំនុំជម្រះនេះ[222]។ ហេតុដូច្នេះសហព្រះរាជអាជ្ញាមិនមានតួនាទីអ្វីក្នុងពេលបច្ចុប្បន្ននេះ ដើម្បីធ្វើការវាយតម្លៃខ្លឹមសារនៃឯកសារទាំងអស់នេះ ព្រមទាំងធ្វើការឆ្លើយតបទៅនឹងឯកសារទាំងអស់នេះទេ។ សហព្រះរាជអាជ្ញាមិនអាចធ្វើការវាយតម្លៃ និងឆ្លើយតប ដោយផ្អែកលើមូលដ្ឋាននៃសេចក្ដីសង្ខេបដែលបានអះអាង និងការដកស្រង់បែបជ្រើសរើស ដែលផ្ដល់ឱ្យដោយ នួន ជា ឡើយ។ ហេតុដូច្នេះ ប្រសិនបើអង្គជំនុំជម្រះមិនជំទាស់ទៅលើឯកសារទាំងនេះ ដោយផ្អែកលើមូលដ្ឋានដទៃទៀតទេ សហព្រះរាជអាជ្ញាសូមរក្សាសិទ្ធិ ក្នុងការឆ្លើយតបទៅនឹងខ្លឹមសារនៃឯកសារទាំងនេះ នៅពេលដែលមានឯកសារបកប្រែជាភាសាផ្លូវការរបស់ អ.វ.ត.ក។

103. ទោះជាយ៉ាងនេះក្ដី បើទោះបីជាត្រឹមតែផ្អែកលើមូលដ្ឋាននៃសេចក្ដីសង្ខេបរបស់ នួន ជា ក៏ឯកសារទាំងអស់នេះនៅតែមិនអាចទទួលយកបាន តាមវិធាន ៨៧(៣) និងវិធាន ៨៧(៤) ព្រោះភ័ស្តុតាងដែលមាននៅក្នុងឯកសារទាំងនោះ មិនមែនជាកត្តាសម្រេចនៅក្នុងសាលក្រមឡើយ ហើយក៏នឹងមិនអាចនាំទៅដល់ការស្វែងរកការពិតបានឡើយ។ មិនមានឯកសារណាមួយក្នុងចំណោមឯកសារទាំងបួន ដែលបានស្នើសុំ បានពិភាក្សាពីទួលពោធិ៍ជ្រៃ ឬការជម្លៀសប្រជាជនដោយបង្ខំ ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ឡើយ ហើយមិនមានឯកសារណាមួយដែលបានផ្ដល់ភ័ស្តុតាងដោះបន្ទុកពាក់ព័ន្ធគោលនយោបាយ កំណត់គោលដៅចំពោះអតីតអ្នករដ្ឋការលន់ នល់ ឬចំពោះការសម្រេចដែលថារចនាសម្ព័ន្ធអំណាចបែបឋានានុក្រម ស្ថិតនៅរឹងមាំក្នុងអំឡុងពេលមានហេតុការណ៍ នៅទួលពោធិ៍ជ្រៃ ដែលជាហេតុការណ៍ដែល នួន ជា និង ខៀវ សំផន ត្រូវបានផ្ដន្ទាទោស។

*v. សាច់រឿងលេខរដ្ឋាភិបាលអាមេរិក*

---

ជម្រះ ធៀបនឹងពេលបណ្ដឹងសាទុក្ខ ទើបសហព្រះរាជអាជ្ញា មិនបានជំទាស់នាពេលកន្លងមក និងមិនជំទាស់នាពេលនោះ ចំពោះការទទួលយកនៅក្នុងពេលសវនាការ បើទោះបីជាសហព្រះរាជអាជ្ញានៅបន្តរង់ចាំ ការបកប្រែឯកសារទាំងនោះទៅជាភាសាផ្លូវការរបស់ អ.វ.ត.ក ដើម្បីវាយតម្លៃទៅលើឯកសារទាំងនោះឱ្យបានពេញលេញ។

[222] ឯកសារ F2/8 សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១១៣។

104. សហព្រះរាជអាជ្ញាសូមជំទាស់ទៅនឹងសំណើ សុំឱ្យទទួលយកសាទូរលេខការទូតរបស់រដ្ឋាភិបាលអាមេរិកចំនួនប្រាំបី ("សាទូរលេខ") ដែលមានកាលបរិច្ឆេទចាប់ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៨[223]។

105. សំណើនេះគួរត្រូវបានបដិសេធ ដោយសារតែសំណើនេះមិនបានបំពេញតាមបទដ្ឋាននៃវិធាន ១០៨(៧) សម្រាប់ការទទួលយកភ័ស្តុតាងថ្មីនៅបណ្តឹងសាទុក្ខ ហើយការនេះក៏មិនមែនដើម្បីប្រយោជន៍យុត្តិធម៌ដែរ ក្នុងការទទួលយកភ័ស្តុតាងថ្មីនេះ។ ទីមួយមេធាវីការពារក្តីទទួលស្គាល់ថា សាទូរលេខមួយចំនួនមានរួចហើយនៅពេលសវនាការ[224]។ ទោះជាយ៉ាងនេះក្តី នួន ជា បានអះអាងដោយបំភាន់ថា សាទូរលេខទាំងនេះត្រូវបាន "ផ្សព្វផ្សាយជាសាធារណៈ" ដោយ Wikileaks ចន្លោះឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៥។ ការអះអាងដោយបំភាន់នេះ មិនបានគិតដល់អង្គហេតុដ៏សំខាន់ដែលថា សាទូរលេខនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈនាពេលកន្លងមក ដោយបណ្ណាសារដ្ឋានជាតិអាមេរិក ដែលក្នុងករណីខ្លះមានតាំងពីប្រាំបួនឆ្នាំមុន។ សាទូរលេខ ១[225] សាទូរលេខ ២[226] សាទូរលេខ ៣[227] សាទូរលេខ ៤[228]

---

223 ឯកសារ F2/8 សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១១៨។

224 ឯកសារ F2/8 សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១៥៩។

225 ប្រៀបធៀប, ឯកសារ F2/8 សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ 119 ដកស្រង់ការផ្សព្វផ្សាយសាទូរលេខ ១ នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ជាមួយបណ្ណាសារដ្ឋានជាតិអាមេរិក ការចូលពិនិត្យនៅក្នុងមូលដ្ឋានទិន្នន័យបណ្ណាសារ ដែលអាចរកបាននៅhttp://aad.archives.gov/aad/createpdf?rid=204792 &dt=2694&dl=2009, ដែលបង្ហាញថា សាទូរលេខ ១ ត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤។

226 ប្រៀបធៀប, ឯកសារ F2/8 សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ 124 ដកស្រង់ការផ្សព្វផ្សាយសាទូរលេខ ២ នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៤ ជាមួយបណ្ណាសារដ្ឋានជាតិអាមេរិក ការចូលពិនិត្យនៅក្នុងមូលដ្ឋានទិន្នន័យបណ្ណាសារ ដែលអាចរកបាននៅ http://aad.archives.gov/aad/createpdf?rid=38728& dt=2694&dl=2009, ដែលបង្ហាញថា សាទូរលេខ ២ ត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤។

227 ប្រៀបធៀប, ឯកសារ F2/8 សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១២៦ ដកស្រង់ការផ្សព្វផ្សាយសាទូរលេខ ៣ នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៤ ជាមួយបណ្ណាសារដ្ឋានជាតិអាមេរិក ការចូលពិនិត្យនៅក្នុងមូលដ្ឋានទិន្នន័យបណ្ណាសារ ដែលអាចរកបាននៅ http://aad.archives.gov/aad/createpdf? rid=228502&dt=2532&dl=1629, ដែលបង្ហាញថា សាទូរលេខ ៣ ត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៩។

228 ប្រៀបធៀប, ឯកសារ F2/8 សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១៣០ ដកស្រង់ការផ្សព្វផ្សាយសាទូរលេខ ៤ នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៤ ជាមួយបណ្ណាសារដ្ឋានជាតិអាមេរិក ការចូលពិនិត្យនៅក្នុងមូលដ្ឋានទិន្នន័យ

សាទូរលេខ ៥[229] សាទូរលេខ ៦[230] សាទូរលេខ ៧[231] និងសាទូរលេខ ៨[232] មានជាសាធារណៈតាំងពីមុនកាលបរិច្ឆេទដែល នួន ជា បានអះអាងទៅទៀត។ សាទូរលេខ ៣, ៦, ៧ និង៨ គឺមានតាំងពីមុនពេលចាប់ផ្តើមសវនាការ ក្នុងសំណុំរឿង ០០២/០១។ សាទូរលេខ ១, ២, ៤ និង៥ គឺមានប្រហែលជាមួយឆ្នាំកន្លះហើយ។ សាទូរលេខដូចជាសាទូលេខទាំងនេះ ដែលអាចរកបានតាមរយៈបណ្ណាសារដ្ឋានជាតិអាមេរិក ត្រូវបានបញ្ជាក់យ៉ាងច្បាស់ នៅក្នុងអំឡុងពេលសំណុំរឿង ០០២/០១[233]។ បន្ថែមលើនេះ ការអះអាងរបស់មេធាវីការពារក្តីដែលថា សម្រេចមិនបង្ហាញសាទូរលេខនៅពេលសវនាការនោះ[234] បានបង្ហាញយ៉ាងជាក់ច្បាស់ថា សំណើនេះគឺមិនអាចជឿជាក់បានឡើយ។

---

បណ្ណាសារ ដែលអាចរកបាននៅ http://aad.archives.gov/aad/createpdf? rid=32142&dt=2694&dl=2009, ដែលបង្ហាញថា សាទូរលេខ៤ ត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤។

[229] ប្រៀបធៀប, ឯកសារ **F2/8** សំណើលើកទី៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១៣៦ ដកស្រង់ការផ្សព្វផ្សាយសាទូរលេខ ៥ នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៤ ជាមួយបណ្ណាសារដ្ឋានជាតិអាមេរិក ការចូលពិនិត្យនៅក្នុងមូលដ្ឋានទិន្នន័យបណ្ណាសារ ដែលអាចរកបាននៅ http://aad.archives.gov/aad/ createpdf?rid=37318&dt=2694&dl=2009, ដែលបង្ហាញថា សាទូរលេខ ៥ ត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤។

[230] ប្រៀបធៀប, ឯកសារ **F2/8** សំណើលើកទី៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១៣៩ ដកស្រង់ការផ្សព្វផ្សាយសាទូរលេខ ៦ នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៣ ជាមួយបណ្ណាសារដ្ឋានជាតិអាមេរិក ការចូលពិនិត្យនៅក្នុងមូលដ្ឋានទិន្នន័យបណ្ណាសារ ដែលអាចរកបាននៅ http://aad.archives.gov/aad/ createpdf?rid=227912&dt=2082&dl=1345, ដែលបង្ហាញថា សាទូរលេខ ៦ ត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៦។

[231] ប្រៀបធៀប, ឯកសារ **F2/8** សំណើលើកទី៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១៤៣ ដកស្រង់ការផ្សព្វផ្សាយសាទូរលេខ ៧ នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៣ ជាមួយបណ្ណាសារដ្ឋានជាតិអាមេរិក ការចូលពិនិត្យនៅក្នុងមូលដ្ឋានទិន្នន័យបណ្ណាសារ ដែលអាចរកបាននៅ http://aad.archives.gov/aad/ createpdf?rid=226437&dt=2082&dl=1345, ដែលបង្ហាញថា សាទូរលេខ ៧ ត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៦។

[232] ប្រៀបធៀប, ឯកសារ **F2/8** សំណើលើកទី៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១៤៦ ដកស្រង់ការផ្សព្វផ្សាយសាទូរលេខ ៨ នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៣ ជាមួយបណ្ណាសារដ្ឋានជាតិអាមេរិក ការចូលពិនិត្យនៅក្នុងមូលដ្ឋានទិន្នន័យបណ្ណាសារ ដែលអាចរកបាននៅ http://aad.archives.gov/aad/ createpdf?rid=226427&dt=2082&dl=1345, ដែលបង្ហាញថា សាទូរលេខ ៨ ត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៦។

[233] សូមមើល ឯកសារ **E282/2/1** សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញលើ សេចក្តីសម្រេចពាក់ព័ន្ធការទទួលយកទូរលេខការទូតសហរដ្ឋអាមេរិក ដែលទើបរកបានថ្មី, ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣។

[234] ឯកសារ **F2/8** សំណើលើកទី៦ សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១៥៩។

106. ទីពីរសាទូរលេខមិនមែនជាកត្តាសម្រេច នៅក្នុងសាលក្រមឡើយ។ ភាគច្រើននៃសាទូរលេខគឺស្ថិតក្រៅវិសាលភាពពេលវេលា នៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[235] ហើយមិនមានសាទូរលេខណាមួយដែលជាប់ពាក់ព័ន្ធ ជាមួយអង្គសេចក្តីរបស់សាលក្រមឡើយ។ សាទូរលេខបី ក្នុងចំណោមសាទូរលេខប្រាំបី ពាក់ព័ន្ធទៅនឹងការប៉ះទង្គិចនៅតាមព្រំដែន រវាងប្រទេសកម្ពុជា និងប្រទេសថៃ[236] សាទូរលេខបីពាក់ព័ន្ធនឹងការគប់គ្រាប់បែកនៅសៀមរាប[237] និងសាទូរលេខមួយពាក់ព័ន្ធការជ្រើសរើស យុទ្ធជនប្រឆាំង នៅក្នុងជំរុំជនភៀសខ្លួនក្នុងប្រទេសថៃ[238]។ មិនមានប្រធានបទណាមួយក្នុងចំណោមនោះ ប៉ះពាល់ដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ តាមពិតទៅពួកគេមិនបានទទួលការបង្ហាញ សូម្បីតែម្តងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ នួន ជា[239] ឬនៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោល នៅពេលសវនាការឡើយ[240]។ សាទូរលេខមួយដែលនួន ជា ផ្តោតជាពិសេសនោះ បានធ្វើការទាយស្មានថា សោ ភឹម បានដឹកនាំការបះបោរប្រឆាំងប៉ុល ពត នៅក្នុងភូមិភាគបូព៌ា ប៉ុន្តែនួន ជា បែរជាមិនបានលើកឡើងថា សាទូរលេខនោះចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៨ គឺពីរខែក្រោយពេលសោ ភឹមស្លាប់[241]។ ដូចបញ្ជាក់ពីខាងលើ ភ័ស្តុតាងបែបនេះពិតជាមិនបាន បន្ថយការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អំពីតួនាទីរបស់ សោ ភឹម ការគោរពដោយស្មោះត្រង់របស់គាត់ ចំពោះការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា និងការកំណត់ចំពោះគាត់ថាជាខ្មាំងផ្ទៃក្នុង

---

[235] ឯកសារ **F2/8** សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១១៩, ១២៤, ១២៦, ១៣០, ១៣៦ យោងទៅរកទូរលេខ ១, ២, ៣, ៤ និង ៥ ដែលទូរលេខទាំងអស់ទាក់ទងហេតុការណ៍ក្នុងឆ្នាំ ១៩៧៨។

[236] ឯកសារ **F2/8** សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១២៤ ដល់ ១៣៨ យោងទៅរកទូរលេខ ២, ៣ និងទូរលេខ ៤។

[237] ទូរលេខ ៦, ៧, ៨។

[238] ឯកសារ **F2/8** សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១៣៦ ដល់១៣៨ យោងទៅរកទូរលេខ ៥។

[239] ឯកសារ **F16** បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងសាលក្រមក្នុងសំណុំរឿង ០០២/០១, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤។

[240] ឯកសារ **E1/232.1** ប្រតិចារឹកកិច្ចដំណើរការនីតិវិធីជំនុំជម្រះ, ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣។ ឯកសារ **E1/233.1** ប្រតិចារឹកកិច្ចដំណើរការនីតិវិធីជំនុំជម្រះ, ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣។ ឯកសារ **E1/237.1** ប្រតិចារឹកកិច្ចដំណើរការនីតិវិធីជំនុំជម្រះ, ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣។

[241] ឯកសារ **F2/8** សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១១៩ ដល់ ១២៣ យោងទៅរកទូរលេខ ១។

នៅក្នុងឆ្នាំ ១៩៧៨ ឡើយ[242]។ ទោះបីជារួម ឬដោយឡែកពីគ្នាក៏ដោយ ក៏សាទូរលេខមិនមានភាពពាក់ព័ន្ធជាមួយការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អំពីរចនាសម្ព័ន្ធឋានានុក្រមរបស់ខ្មែរក្រហម ការផ្លាស់ទីលំនៅដោយបង្ខំ និងហេតុការណ៍នៅទួលពោធិ៍ជ្រៃឡើយ។

107. សាទូរលេខទាំងនេះក៏មិនសមស្រប សម្រាប់បង្ហាញការពិតដែល នួន ជា បានអះអាងថាសាទូរលេខទាំងនោះអាចបង្ហាញឡើយ។ បើទោះបីជាការសម្រេចច្បាស់លាស់ ពាក់ព័ន្ធទៅនឹងការបង្ហាញសាទូរលេខ មិនមានភាពច្បាស់លាស់ក៏ដោយ ប៉ុន្តែវាហាក់ដូចជាថា សាទូរលេខទាំងនោះគឺដើម្បីគាំទ្រដល់ការអះអាង អំពីការបះបោរផ្ទៃក្នុងដែលអាចកើតមាន និងសញ្ញាណនៃផែនការមេរបស់វៀតណាមក្នុងការឈ្លានពានកម្ពុជា[243]។ ប៉ុន្តែសាទូរលេខគឺមិនសមស្របឡើយ ដោយសារតែវាស្ថិតក្រៅអំឡុងពេលវេលាពាក់ព័ន្ធនៃសាលក្រម។ សំណើសុំទទួលយកសាទូរលេខគឺគ្មានខ្លឹមសារ។ ការអះអាងដែលមេធាវីការពារក្តី "យល់ឃើញថាវាគ្មានប្រយោជន៍ឡើយ ក្នុងការស្នើសុំឱ្យទទួលយកសាទូរលេខនានា" នៅពេលជំនុំជម្រះនោះ ដោយសារតែការស្នើសុំឱ្យទទួលយក សាទូរលេខដែលមិនពាក់ព័ន្ធត្រូវបានបដិសេធ គឺជាភ័ស្តុតាងនៃភាពមិនបានការរបស់សំណើ[244]។ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា សាទូរលេខជាក់លាក់ដែលបានដាក់ មិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលយកតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង[245]។ ការទទួលយកមូលហេតុដែលមិនច្បាស់លាស់របស់ នួន ជា គឺមានន័យថាការទទួលយកភ័ស្តុតាងទាំងអស់ មិនចាំបាច់ត្រូវស្ថិតក្រោមការវាយតម្លៃ

---

[242] *សូមមើលជាឧទាហរណ៍* ឯកសារ **E313** សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤០, ៧៧៣។ សូមមើលផងដែរ កថាខណ្ឌ ៨៧, ៨៩, ១៣៣, ២០៣, ២១៩, ៣០៩, ៧២៦-៧២៧, ៧២៩, ៧៣២-៧៣៣, ៧៣៥, ៧៣៩, ៧៤១, ៧៤៥, ៧៤៩, ៧៦៦, ៧៧៧, ៨០៧-៨០៨, ៨១០។

[243] សូមមើលជាឧទាហរណ៍ ឯកសារ **F2/8** សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ៤០, ៤២, ៤៣ និង ៦១។

[244] ឯកសារ **F2/8** សំណើលើកទី៦ សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១៥៩។

[245] សូមមើល ឯកសារ **E282/2** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា និងសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ស្តីពីសារទូរលេខតាមផ្លូវទូត របស់សហរដ្ឋអាមេរិក (E282 និង E282/1, E290 និង E290/1), ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣។ ឯកសារ **E282/2/1/2** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំការពិចារណាឡើងវិញចំពោះ សេចក្តីសម្រេចទាក់ទងនឹងការទទួលយក សារទូរលេខតាមផ្លូវការទូតរបស់សហរដ្ឋអាមេរិក ដែលទើបរកបានថ្មីៗ (ឯកសារ E282/2/1) និងចម្លើយតបរបស់ ខៀវ សំផន (ឯកសារ E282/2/1/1), ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣។

ទៅលើភស្តុតាងនីមួយៗនោះឡើយ គឺគ្រាន់តែវាយតម្លៃទៅលើប្រភេទទូទៅ ដែលភស្តុតាងទាំងនោះស្ថិតនៅក្នុងប៉ុណ្ណោះ។

108. ទីបី ចំពោះផ្នែកដទៃទៀតនៃសំណើ គឺមេធាវីការពារក្ដីមិនបានកំណត់អត្តសញ្ញាណ ពីការសម្រេចជាក់លាក់នៅក្នុងសាលក្រមដែលថា សាទូរលេខបានអះអាងផ្ទុយនោះឡើយ។ ដោយសារតែមិនមានការយោងណាមួយទៅរកសាលក្រមនោះហើយ ទើបអាចសន្មតបានថាភស្តុតាងដែលថា អាចមានលទ្ធភាពនៃបដិវត្តផ្ទៃក្នុង គឺចង់សំដៅទៅលើលក្ខណៈនៃឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា និងតួនាទីរបស់ភូមិភាគ។ ការដែល នួន ជា មិនបានចង្អុលបង្ហាញពីធាតុផ្សំមូលដ្ឋាន ដែលគាត់បានលើកជាបញ្ហា នៅពេលដែលជំទាស់ទៅលើផ្នែកធំរួមនៃសាលក្រមនោះ គឺច្បាស់លាស់ណាស់ថាជាការព្យាយាម ក្នុងការបិទបាំងពីភាពមិនមានមូលដ្ឋានរបស់សំណើ។

## V- សេចក្ដីសន្និដ្ឋាន

109. សម្រាប់សំអាងហេតុដូចបានបញ្ជាក់ពីខាងលើ សហព្រះរាជអាជ្ញាសូមស្នើសុំដោយសេចក្ដីគោរព សូមអង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

១) ច្រានចោលសំណើរបស់ នួន ជា សុំឱ្យទទួលយកឯកសារបន្ថែម នៅក្នុងបណ្ដឹងសាទុក្ខ និង

២) ច្រានចោលសំណើរបស់ នួន ជា សុំឱ្យកោះហៅសាក្សីបន្ថែម សម្រាប់បណ្ដឹងសាទុក្ខ

ដោយសេចក្ដីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៥ | ជា លាង<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | |